ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ២៣-២៤

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

## សេចក្ដីជូនពរឆ្នាំថ្មី

គ្រិស្តសករាជ ១៩៤៣

ថ្ងៃ ១ យ៉ាំងវីយេរ ឆ្នាំ ១៩៤៣ ជាថ្ងៃចូលឆ្នាំថ្មីតាមបែបលោកនិយម ទស្សនាវដ្ដី "កម្ពុជសុរិយា" សូមអានុភាពព្រះត្រៃរ័ត្នដែលជាឧត្ដមសរណៈក្នុងលោក ជួយអភិបាលឧបត្ថម្ភលោក - អ្នកជាវទាំងប៉ុន្មាន សូមឲ្យបានប្រកបដោយសេចក្ដីសុខ - ចំរើន - អាយុយឺនយូរ - និរភ័យ - និរោគគ្រប់ទិវារាត្រីកុំបីឃ្លាតឡើយ ។

កម្ពុជសុរិយា.

## សេចក្ដីជូនដំណឹង

ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពសៀវភៅថ្មីៗ ចេញផ្សាយដូចមានកាយឈ្មោះខាងក្រោមនេះ:

១ - អាឡវកសូត្រ និយាយពីអាឡវកយក្សសួរប្រស្នាព្រះដ៏មានព្រះភាគ ។ ដំឡៃ ១ កាគ ០រ.៧៥ ។

២ - អភិនវភាសិត គឺសុភាសិតបាលី ដែលបានស្រង់យកពីគម្ពីរផ្សេងៗ ហើយប្រែជាពាក្យកាព្យភាសាខ្មែរ ។ ដំឡៃ ១ កាគ ០រ.១៥ ។

៣ - ព្រហ្មចារីយកថា និយាយពីព្រហ្មចារីយធម៌ ១០ ប្រការ មានសីលទានជាដើម ។ ដំឡៃ ៣រ.៤០ ។

៤ - កុម្ភជាតក និយាយពីដើមកំណើតសុរា និងទោសរបស់សុរា ។ ដំឡៃ ១ ភាគ ០រ.៣០ ។

៥ - បិសាចស្នេហា ជារឿងសម័យទំនើបថ្មី សេចក្ដីពិរោះស្ដាប់ ចាប់ចិត្តអ្នកមើល ។ ដំឡៃ ១ ភាគ ០រ.៣៥ ។

៦ - គម្ពីរវិសុទ្ធិមគ្គភាគ ១ បាលីសុទ្ធជាបែបរៀនបាលី សម្រាប់សាលាបាលីជាន់ខ្ពស់ ។ ដំឡៃភាគទី ១ ។ ភាគ ២រ.៩០ ។

៧ - ច្បាប់ផ្សេងៗ ភាគទី ២ គឺច្បាប់រាជនេតិ - ច្បាប់បណ្ដាំបិតា ច្បាប់ហែមហាជន ។ ដំឡៃ ១ ភាគ ០រ.៣០ ។

*

* *

ទស្សនាវដ្ដី "កម្ពុជសុរិយា" ឆ្នាំថ្មី គឺឆ្នាំ ១៩៤៣ នេះ យើងនឹងរៀបចំផ្សំរឿងឲ្យកាន់តែល្អមើលពិរោះស្ដាប់ឡើងទៀត ទាំងខាងគតិលោក ទាំងខាងគតិធម៌ ។ មួយទៀត សូមជូនដំណឹងថា អស់លោកអ្នកប្រាជ្ញជាក្រុមជំនុំព្រះត្រៃបិដក នឹងជួយតែងរឿងការផ្សេងៗ ដែលជាប្រយោជន៍ ទាំងខាងផ្លូវលោក ទាំងខាងផ្លូវធម៌ ទាំងពាក្យកាព្យ ទាំងពាក្យរាយ សម្រាប់ចុះផ្សាយក្នុងកម្ពុជសុរិយានេះដែរ ដូច្នេះ

ទំស្សនាវដ្តីឆ្នាំថ្មីគង់មានរឿងល្អមើល សេចក្តីគិតកាន់តែពិកេះពិសាឡើងទៀតពុំខាន ។ ក្រៅអំពីនេះ យើងនឹងប្រមូលរូបរមដំណាំងផ្សេងៗ ក្នុងលោក ធ្វើជាសេចក្តីសង្ខេបខ្លីៗ ក្នុងមួយខែៗ ដើម្បីឲ្យអស់លោក-អ្នកជាវកម្ពុជសុរិយា បានជ្រាបហេតុភេទក្នុងលោកសព្វថ្ងៃនេះ ដោយឡែកទៀតផង ។

ហេតុនេះ សូមអស់លោក - អ្នកដែលត្រូវការចង់ជួយទំនុកបំរុងអក្សរសាស្ត្រ ទឹងចំណេះចេះដឹងរបស់លោកអ្នកឲ្យបានចំរើនឡើង សូមមេត្តាទៅចុះឈ្មោះជាវតាំងអំពីដើមឆ្នាំនេះឲ្យហើយស្រេចទៅ ដើម្បីឲ្យពុទ្ធសាសនបណ្ឌិត្យលៃលកបោះពុម្ព ឲ្យបានចំនួនគ្រប់គ្រាន់ដល់អ្នកជាវទាំងអស់គ្នា ។

---

# បញ្ជីរឿង


ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌទី ១៣ ព្រះគ្រូវិនយធម្ម ហ៊ី-ជា ក្រុមជំនុំព្រះត្រៃបិដក សំដែង . . . . . . . . . . . . . . . . . . . . . . . . ១

២ — ច្បាប់ផ្សេង ៗ ភាគ ៤ :

១) ច្បាប់មហានេតិ ភជសូស្តី . . . . . . . . . . . . . . . . . . . ១០

២) ល្បើកច្បាប់ក្រិត្យក្រម . . . . . . . . . . . . . . . . . . . ២៧

៣ — ប្រវត្តិពួកឧបាសិកា ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់ :

៥) នាងឧត្តរា - នន្ទមាតា . . . . . . . . . . . . . . . . . . . ៤៥

៦) នាងសុប្បវាសា - កោលិយធីតា . . . . . . . . . . . . . . . . ៤៨

៤ — រឿងព្រះបាទអសោក អ្នកអាចារ្យ ឃឹម - អាន ប្រែនិងរៀបរៀង (តមក) . ៥១

៥ — ពង្សាវតារភេម ស្រង់យកអំពីគោលបារីកផ្សេង ៗ ក្នុងពង្សាវតារលោក (តមកនឹងចប់) . . . . . . . . . . . . . . . . . . . . . . . ៦៦

៦ — ភូមិសាស្ត្រសង្ខេប នៃទ្វីបអូស្ត្រាលី . . . . . . . . . . . . . . . . ៧៣

# TABLE DES MATIÈRES

Pages

1. VIDYUDHAMMADRSANĀ (conférence faite à la Radio Phnôm-Penh), par le Vénérable Préas Krou VINAYADHAMMA HY-CHÉA, membre de la Commission du TRIPITAKA ......... 1

2. CHBAB divers (4ᵉ partie) :

   I. CHBAB MAHANET RĀJASVASTI .......................... 10

   II. LBEUK CHBAB KRIT-KRAM .......................... 27

3. Vies des disciples du BOUDDHA:

   V. La Vie de UTTARĀ NANDAMATA .......................... 45

   VI. La vie de SUPPAVĀSĀ-KOLIYADHITA .......................... 48

4. Légende de l'Empereur AÇOKA de l'Inde antique, par feu l'Achar KIM-ANN (suite) .......................... 50

5. Histoire de Rome. Extraits de divers documents de l'histoire universelle (suite et fin) .......................... 66

6. Géographie sommaire du continent australien .......................... 73

## វិទ្យុធម្មទេសនា  កណ្ឌទី ១៣

## ព្រះគ្រូវិនយធម្ម ហ៊ី-ជា ក្រុមជំនុំព្រះត្រៃបិដក

សំដែងនៅថ្ងៃសុក្រ ១៥ កើតខែជេស្ឋ ឆ្នាំមមីចត្វាស័ក ពុទ្ធសករាជ ២៤៨៥

ត្រូវនឹងថ្ងៃ ២៩ ម៉ៃឆ្នាំ ១៩៤២ ។

វេលានេះ អាត្មាភាពនឹងសំដែងធម្មិកថា ពណ៌នាព្រះសទ្ធម្មដែលជាពាក្យប្រដៅរបស់ព្រះដ៏មានព្រះភាគ តាមអភិលិខិតសម័យ ដែលត្រូវវេនមកដល់អាត្មា ដោយលំដាប់ ដើម្បីជាផ្លូវចំរើនសតិបញ្ញា និងសម្មាបដិបត្តិ នៃពុទ្ធមាមកបរិស័ទទាំងឡាយ ។

ធម៌ទេសនានេះ អធិប្បាយផ្លូវធម៌អែបផ្លូវលោក គឺសេចក្តីជាអ្នកអង់អាច ក្នុងករណីយកិច្ចតូចធំទាំងពួង គឺប្រកបដោយសេចក្តីពិចារណាស្ទង់មើលដោយឧបាយដ៏ប្រពៃ ហើយទើបចាត់ធ្វើដំណើរកិច្ចានុកិច្ចនោះៗ ឲ្យដុះដាលជាផលល្អ តាមដែលត្រូវការរបស់ខ្លួន របស់អ្នកដទៃ រហូតដល់ទៅជាតិ សាសនា មហាក្សត្រ ស្រុកទេសរបស់ខ្លួន ។

សំដែងសមត្ថទេសនា គឺសេចក្តីជាអ្នកអង់អាច . សមត្ថទេសនានេះ មានសេចក្តីទូលាយណាស់ ទើបគួររួបរួមកំណត់ទុកឲ្យនៅក្នុងរង្វង់តាមដែលត្រូវការដូច្នេះគឺ:

១ អាចសមតាមអត្តភាព

២ អាចសមតាមដំណែងមុខការ

៣ អាចសមតាមពួកគណៈ

៤ អាចសមតាមធម៌ ។

សេចក្ដីអធិប្បាយក្នុងសមត្ថទាំង ៤ យ៉ាងនេះគឺ:

១ – ការដែលតាំងខ្លួនបានជាបុគ្គលស្តុកស្តម្ភមាំមួន ឈ្មោះថាអាចសមតាមអត្តភាព; ដោយសេចក្ដីគិតស្គាល់ដំឡៃរបស់ខ្លួនមានដើមថា មានជាតិដូចម្ដេច មានត្រកូលដូចម្ដេច មានភេទដូចម្ដេច មានយសស័ក្តិត្រឹមណា ក៏អាចតាំងខ្លួនឲ្យសមតាមនោះ ចាប់ដើមតាំងតែជាអ្នកសុភាពកបសា តែជាអ្នកអង់អាចក្លាហាន ក្នុងករណីយកិច្ចតូចធំ មិនជាកំផុរៈ ព្យាយាមប្រឹងធ្វើទាល់តែសម្រេចមកបាន ។ មនុស្សដែលទន់ជាបំផុត មិនអាចនឹងតាំងខ្លួនឯងបាន ទើបមិនសមគួរនឹងប្រព្រឹត្តដូច្នោះ សូម្បីក្នុងខណៈធ្វើករណីយកិច្ច ប្រសិនបើមានឧបសគ្គមកដំទាស់ ក៏មិនគួរនឹងរអាចិត្តធុញថប់ចុះចាញ់ងាយៗ គោងប្រឹងប្រយ័ត្នកុំឲ្យខូចការ តាំងចិត្តកំណត់ប៉ុនប៉ងធ្វើរឿយៗទៅកុំឈប់ ធ្វើដំណើរចិត្តឲ្យរកកយក្នុងសេចក្ដីមិនប្រមាទ ហើយថ្នមរក្សាចិត្តនោះទុកទាល់តែអាចដកខ្លួនឲ្យផុតឧបសគ្គនោះជាជាន់ៗ រហូតដល់ជាន់ទីបំផុត ប្រៀបដូចជាងទងដែលៈស្ពាហ៍

ខាត់ជំរះមន្ទិលមាសឲ្យស្អាតបន្តិចម្តងៗ ទាល់តែមាសទៀងពណ៌ក្តីថា គួរប្រើជាគ្រឿងប្រដាប់ដ៏មានដំឡៃ ៗ ដោយន័យនេះ បុគ្គលដែលសុខចិត្តបាញ់ឧបសគ្គផ្សាយៗ ក៏ដូចជាឧបក្រសោបទុក្ខមកទុកក្នុងខ្លួន ទើបសមគួរណាស់ នឹងយកចិត្តទុកដាក់សង្កេតមើលការងាររបស់ខ្លួន ដែលធ្វើសម្រេចហើយ ឬនៅមិនទាន់សម្រេច កាលឃើញថាមានឧបសគ្គមកជំពាស់ ក៏នឹងមិនបានទម្រន់ដាក់ធុរៈអាចិត្តផ្សាយៗ ហើយខំព្យាយាមពុះពារឲ្យធ្លុងផុតទៅបាន ក៏អាចតាំងខ្លួនជាធំបានដោយពិតប្រាកដ ៗ

២ – សេចក្តីអាចសមតាមចំណែកមុខការ មានអធិប្បាយដូច្នេះ មនុស្សយើងពល់រូបរស់នៅបានដោយអាហារ ទើបត្រូវតែស្វែងរកអាហារមកចិញ្ចឹមជីវិត ដោយប្រកបកិច្ចធុរៈតាមបេះដូង នឹងសេចក្តីគាប់ចិត្តរបស់ខ្លួន តែចិត្តរបស់មនុស្សនេះផ្សេងៗគ្នា ហេតុនោះ នឹងប្រកបកិច្ចធុរៈប្រភេទជាមួយគ្នា តែទាំងអស់គ្នាក៏មិនបាន កិច្ចធុរៈទើបមានច្រើនប្រភេទ មនុស្សម្នាក់ៗ នឹងធ្វើឲ្យសព្វគ្រប់ប្រភេទក៏ពុំបាន ទើបតោងចែកមុខគ្នាធ្វើដោយមុខដោយយ៉ាងទៅ ដូចយ៉ាងមុខការបង្ហាត់បង្រៀនប្រៀនប្រដៅ, មុខការពេដការ, មុខការលក់ដូរ, មុខការស្រែចំការ, មុខការចំណែកខ្លួនជាដើម រួមសេចក្តីទៅថាមនុស្សយើងរមែងមានមុខការសម្រាប់ខ្លួនពល់រូប ហេតុនោះ សេចក្តីអាចសមតាមមុខការ ទើបជាកិច្ចដែលត្រូវប្រាថ្នា កាលមានមុខការយ៉ាងណា ក៏អាចចាត់ធ្វើឲ្យសមមុខការយ៉ាងនោះ

បដិបត្តិយ៉ាងណា ដែលអ្នកប្រាជ្ញលោកក៏ប៉ងថា អាចសមតាមមុខការ ក៏គោងបដិបត្តិយ៉ាងនោះ មានដើមថា ជាអ្នកល្អិតល្អ មានសេចក្តីចេះដឹងករណីយកិច្ចតូចធំ ក្នុងមុខក្រសួងរបស់ខ្លួនសព្វគ្រប់ ហើយបដិបត្តិទៀងត្រង់ក្នុងមុខក្រសួង រក្សាមុខការឲ្យរៀបរយជាដរាប មិនបណ្តែតបណ្តោយឲ្យការងារសេសសល់ ទាំងគោងគិតកែខៃដូសដុលបំពេញឲ្យចំ-រើនជឿនទៅមុខជាទីតាំងប្រយ័ត្នរក្សាមិនឲ្យសាបសូន្យថយចុះ ដូច្នេះគួររាប់ថាអាចសមតាមមុខការ ។

ទី ៣– សេចក្តីអាចសមតាមពួកគណៈ មានសេចក្តីអធិប្បាយថា:

មនុស្សយើងនឹងនៅតែម្នាក់ឯងក្នុងលោកនេះមិនបាន ត្រូវតែចងសម្ពន្ធទាក់ទាមគ្នានូវគ្នាទៅវិញទៅមក សេចក្តីសម្ពន្ធនេះឯង បង្គាប់ឲ្យរួមជាពួក តាំងដើមអំពីរួមគ្នាជាគ្រួសារនិមួយៗ ឬក្នុងវង្សញាតិនិមួយៗ ឡើងទៅ ដរាបដល់រួមជាជាតិនិមួយៗ ជាទីបំផុត ក៏តែគ្រួសារវង្សញាតិ ឬជាតិនោះដែលនឹងតាំងនៅមាំមួនអស់កាលជាយូរ ក៏គោងអាស្រ័យបុគ្គលដែលនៅក្នុងពួកព្រមព្រៀងបង្គ្រួបគ្នា ប៉ុនប៉ងបំណងរកសេចក្តីចំរើនមកឲ្យពួក មានគោលដែលបំណងត្រង់ត្រូវគ្នា មានសេចក្តីស្និទ្ធស្នាលស្រឡាញ់រាប់អានគ្នាជាចិត្តមួយ អនុគ្រោះសង្គ្រោះចែកចាយដល់គ្នានូវគ្នាតាមដែលត្រូវការ មានសេចក្តីប្រព្រឹត្តស្មើគ្នា រួមកំឡាំងផងគ្នា ជួយគ្នារក្សា ទំនុកបម្រុងពួករបស់ខ្លួន ឲ្យមើលតួយ៉ាងពួកដែលរុង-

រឿងហើយ គេចាត់ការទំនុកបម្រុងពួករបស់គេឲ្យរុងរឿងដោយវិធីយ៉ាងណាខ្លះ ក៏ជួយគ្នានាំយកវិធីការ (បែបផែន) របស់គេនោះមកប្រៀបធៀបនឹងវិធីការ (បែបផែន) របស់ខ្លួន ឃើញត្រង់ណាដែលជាការល្អនៅខ្វះកង្វះ ក៏ជួយគ្នាទំនុកបម្រុងឲ្យបរិបូណ៌ឡើង ត្រង់ណាដែលស្តុកស្តម្ភមាំមួនហើយ ជួយគ្នាថែរក្សាការនោះឲ្យបានឋិតថេរចិរកាលទៅ ឲ្យមានកិត្តិយសជាអារ្យជាតិ អារ្យជនដូចគេទាំងឡាយ ដោយន័យប៉ុណ្ណោះល្មមឲ្យឃើញថា សេចក្តីអាចសមតាមពួកនេះជារបស់ដែលមនុស្សគ្រប់រូបត្រូវតែប្រាថ្នា ដ្បិតពួកគណៈដែលនឹងចំរើនឡើង នឹងគង់ទ្រង់នៅដដែល ឬនឹងអ័ប្បទុនចុះព្រោះបុគ្គលអ្នកនៅក្នុងពួកនោះឯង ៗ កាលចំរើនរុងរឿងថ្កុំថ្កើងវិសេស មានកេរ្តិ៍ឈ្មោះល្បីខ្ទរ មានសម្បត្តិស្តុកស្តម្ភសមតាមភាព បុគ្គលអ្នកនៅក្នុងពួកក៏ត្រកាលថ្កុំថ្កើងដូច្នេះដែរ ចំណែកខាងសេចក្តីអ័ប្បទុន ក៏គប្បីដឹងដោយន័យនេះ ព្រោះហេតុនោះ កាលរួមនៅក្នុងពួកណាក៏តោងប្រាថ្នារកសេចក្តីអាចឲ្យសមពួកនោះ ៗ

ប្រការមួយទៀត សេចក្តីអាចសមតាមពួកនេះកាលនឹងពោលតាមគោលគន្លងធម៌ រមែងសម្រេចមកពីអង្គសម្បត្តិ ៤ ប្រការ គឺ សេចក្តីឈ្លាសវាងវៃក្នុងហេតុផល ១ សេចក្តីក្លាហានក្នុងផ្លូវដែលគាប់ ១ ស្តាប់អត្ថធម៌ច្រើន ទឹងចងចាំទុកច្រើន ១ បដិបត្តិសមមុខការដោយយ៉ាងល្អ ១

សេចក្តីជាអ្នកមានចិត្តធ្ងន់ មិនរហើចរហាយហេវហាវ ១ គោលធម៌ទាំង ៤ នេះ ជាអង្គសម្បត្តិឲ្យកើតសេចក្តីភាពសមគាមពួក ។

ទី ៤ – សេចក្តីភាពសមគាមធម៌ រីឯសេចក្តីភាពដែលនិយមថាជាឯក ក៏គោរពយកធម៌ជាគោល ដូចពាក្យថាពាជាឯកដូច្នេះ អ្នក-ពោលសំដៅដល់ពាក្យនិយាយដែលមានគោល ដែលអាចឲ្យសម្រេចផលសមតាមសំដី ដូចយ៉ាងពុទ្ធភាសិត ឬសុភាសិតជាដើម ពោលដោយបុគ្គលាធិដ្ឋាន សូមលើកយកទោណព្រាហ្មណ៍ជាឧទាហរណ៍ ដែលពោលទុកក្នុងពុទ្ធប្រវត្តិត្រង់បរិច្ឆេទចែកព្រះសារីរិកធាតុ មានសេចក្តីថា ក្សត្រទាំង ៦ នគរនឹងមហាព្រាហ្មណ៍ម្នាក់បានជ្រាបកិត្តិស័ព្ទថា សម្តេចព្រះដ៏មានព្រះភាគស្តេចបរិនិព្វានទៅសាលវនោទ្យាន ក្នុងក្រុងកុសិនារា-រាជធានីក៏បញ្ជូនទូតឲ្យទៅអញ្ជើញរាជសារនឹងព្រាហ្មណ៍សារ ឲ្យទៅសុំចំណែកព្រះសារីរិកធាតុ ៗ ចំណែកឯក្សត្រទាំងឡាយដែលគ្រប់គ្រងព្រះនគរកុសិនារាទ្រង់ទទឹងទាស់យ៉ាងខ្លាំង មិនព្រមចែកចំណែកព្រះសារីរិក-ធាតុថ្វាយ ការនោះក៏កម្រើកដិតតែនឹងកើតជាសង្គ្រាម កណ្តាលក្រុងកុសិនារា តែគ្រោះជា ដោយគ្រានោះ ទោណព្រាហ្មណ៍ ដែលជាធំចាស់ទុំមានបញ្ញាយោបល់ក្នុងការដែលនឹងសង្រួបសង្រួម ឲ្យត្រូវតាមគតិលោកគតិធម៌មានពាថាជាសុភាសិត ជាទីរឿងទុកចិត្តរបស់ប្រជុំជន អាចនឹងហាមឃាត់ការពារអធិករណ៍នោះឲ្យស្ងប់ទៅដោយសាមគ្គីធម៌ លុះបានពុស្ងួ

ស័ត្រូកំហែងហាននៃមល្លក្សត្រដូច្នោះ ទើបត្រិះរិះឃើញថា វាចាដូច្នោះ មិនជាធម៌ ទើបសំដែងខន្តិវាទៈនិងសាមគ្គីធម៌ស្រួបស្រួម ទាល់តែបានសម្រេចតាមវាចារបស់ខ្លួន គឺបានទទួលដំណែងជាអធិបតីចែកព្រះសារីរិកធាតុ ការឈ្លោះវិវាទរវាងកងទូត ព្រាហ្មណ៍ទូតនឹងមល្លក្សត្រទាំងឡាយក៏ស្ងប់រម្ងាប់ទៅបាន ។ រឿងនេះជាឧទាហរណ៍យ៉ាងទាបនៃពាក្យថា វាចាឯក និងខថាអាចសមតាមធម៌ ទោះបីដូច្នោះ ក៏នៅប្រព្រឹត្តទៅដើម្បីសន្តិសុខក្នុងរវាងប្រជុំជនដូចពោលមកនោះបាន ហេតុនោះ សេចក្តីអាចសមតាមធម៌ ជាគុណដែលត្រូវប្រាថ្នាដោយពិត ដើម្បីជាបន្ទាត់វិនិច្ឆ័យករណីយកិច្ចតូចធំទាំងឡាយ ឲ្យត្រូវតាមគន្លងធម៌ក៏បាន ដើម្បីសន្តិសុខដល់ខ្លួននឹងប្រជុំជនជាច្រើនក៏បាន ។ កាលនឹងពោលដោយធម្មាធិដ្ឋានសំដៅសេចក្តីដោយត្រង់ ក៏គឺអាចសាងសន្សំសុចរិតប្រព្រឹត្តល្អឲ្យមានឡើងបរិបូណ៌ក្នុងត្រៃទ្វារ ។ គុណធម៌ខនេះមាននៅក្នុងអ្នកឯណា រមែងធ្វើអ្នកនោះឲ្យមានសេចក្តីអៀនខ្មាសនឹងខ្លាចសេចក្តីអាក្រក់ទាំងក្នុងទីកំបាំងទាំងក្នុងទីវាល គ្រប់កន្លែង គ្រប់វេលា ដោយយ៉ាងទាប សូម្បីតែបិទទ្វារ ហើយអង្គុយដំកន់លេងល្បែងភ្នាល់ ដែលច្បាប់ហាមក៏មិនហ៊ានលេង ព្រោះមានសេចក្តីអាចសមតាមធម៌នៅក្នុងខ្លួន ខ្ពស់ឡើងទៅ ក៏ជួយជ្រោមជ្រែងចិត្តឲ្យមានកំឡាំងអាចក្លាហានករណីយកិច្ចតូចធំទាំងពួង សមខ្លួន សមមុខការនាទី សមពួកគណៈបានល្អពិត

ទាល់តែអាចរួបរួមសេចក្ដីល្អទាំងក្នុងផ្លូវលោកទាំងក្នុងផ្លូវធម៌ឲ្យមានបរិបូណ៌ឡើង ៗ ឯសេចក្ដីល្អទាំងនោះ កាលមានដូច្នោះហើយ រមែងមិនរេចរឹលអស់ទៅឡើយ ទោះបីត្រូវសត្រូវបៀតបៀន ឬត្រូវអ្នកណានិមួយសង្កត់សង្កិនឲ្យធ្វើសេចក្ដីអាក្រក់ ក៏មិនធ្វើនឹងសម្លាប់បង់ជាប្រាកដ សូម្បីដូច្នេះក៏កុំនឹកឡើយថា អ្នកអាចសមតាមធម៌នឹងព្រមធ្វើសេចក្ដីអាក្រក់ ព្រោះការជួយជីវិតខ្លួនឡើយ វិស័យអ្នកអាចសមតាមធម៌ រមែងឈ្លាសក្នុងឧបាយវិធីយកខ្លួនឲ្យរួចអំពីសេចក្ដីអន្តរាយទាន់មនុស្សទាន់ហេតុការណ៍គ្រប់វេលា តែប្រសិនបើអំណាចលោកគ្របសង្កត់ខ្លាំងហើយ ក៏គោងសុខចិត្តស្លាប់ តែត្រង់សេចក្ដីអាក្រក់ទៀតជាមិនព្រមធ្វើជាដាច់ខាត ដោយអំណាចធម៌ចូលទៅជំរះចិត្តឲ្យផូរផង់ ទើបចិត្តបាត់ងងឹតបានសេចក្ដីភ្លឺព្រោងក្នុងចិត្តថា ទោះបីខ្លួនស្លាប់ក៏នៅល្អជាជាងដែលធ្វើសេចក្ដីអាក្រក់ឲ្យបង់កិត្តិគុណ ព្រោះហេតុនោះ សេចក្ដីជាអ្នកមានចិត្តដាច់ ប្រព្រឹត្តតែសេចក្ដីល្អគ្រប់យ៉ាង មិនព្រមប្រព្រឹត្តសេចក្ដីអាក្រក់ជាដាច់ខាត គួររាប់ថាអាចសមតាមធម៌ដូច្នេះ ៗ

គុណធម៌ខនេះ កាលមាននៅក្នុងបុគ្គលឯណា រមែងធ្វើបុគ្គលនោះឲ្យឧស្សាហ៍ព្យាយាមគត់ធន់ ធ្ងន់ (មិនស្រេចស្រាលហេវហាវ) អង់អាចក្លាហាន មិនខ្ជិលច្រអូសរួញរាក្នុងករណីយកិច្ចតូចធំទាំងពួង អាចញ៉ាំង

កិច្ចការនោះៗ ឲ្យសម្រេចស្រេចទៅបាន ដោយមិនទើសទាក់ជំពាក់រឹម រាមឬស្ញប់ស្ញែងក្នុងកិច្ចនោះ ហេតុនោះ សមគ្គភាពទើបជាគុណត្រូវតែប្រាថ្នាទាំងក្នុងផ្លូវលោកទាំងក្នុងផ្លូវធម៌ បើមានសេចក្ដីអាចហើយ ខាចប៉ូ រឿងការៈធ្ងន់ កុំថាតែធ្ងន់ម្យ៉ាងឡើយ ទោះបីក្រៃក្រលំបាកយ៉ាងណា ក៏គង់មិនផុតវិស័យសមគ្គភាពទៅបាន គង់អាចចាត់ធ្វើសម្រេច រួមសេចក្ដីជ័យជំនះមកទុកក្នុងកណ្ដាប់ដៃទាល់តែបានជាប្រាកដ ដូចបានបរិយាយមកដូច្នេះ ។

---

## ច្បាប់មហាណេតិភជស្ទួស្តិ

### បទកាកគតិ

ហៃបាធម្មបាល បុត្រច្បងសង្សារ ព្រះជនកស្នេហា កូនអើយបាចាំ បណ្តាំនេះណា ឪពុកទុកជា ស្នងអង្គឯក្រោយ ។ នាហៅមន្ត្រី ព្រះបាទនរបតី កូខកុំបាធ្លោយ ចូរបាកក្តី កុំបីបាឲ្យ អប្បយសឯក្រោយ ព្រះជនកឡើយណា ។ បើបាមានច្បាប់ មានមារយាទគាប់ ផ្គត់ផ្គង់ឥរិយា កេរិ៍ក្រើន ចំរើនឧស្សាហ៍ ដោយព្រះចិន្តា អម្ចាស់សព្វថ្ងៃ ។ កូនអើយបើបា ស្រួលឧស្សាហ៍ សព្វព្រះហឫទ័យ បាអើយរបស់ យឹនយសបាក្រៃ ព្រះអង្គទ្រង់មៃ- ត្រីត្រេកស្នេហ៍ស្នាល ។ បើបាឥតច្បាប់ ឥតមារយាទគាប់ ឥតសព្វឥតសារ បាអើយដំនៀល លោកដៀលសព្វកាល អប្បយសរៀងកល ដាលដល់ឪពុក ។ កូនអើយលោកផង សឹងស្វែងបំណាន ឲ្យលុះនូវសុខ យសយឹនសម្បត្តិ ឲ្យឃ្លាតលែងទុក្ខ ប្រាថ្នាសោយសុខ សម្បត្តិលោកិយ ។ នឹងចូលទៅជា មន្ត្រីសេនា ក្សត្រាធិបតី ជិតជួបគាល់ហៅ ទិត្យនៅប្រក្រតី ខ្វះមានបារមី ‹ អម្ចាស់ករុណា ។ ខ្វះសោះសូន្យទេ ត្រមោចឯឯង អសារសោះសា ខ្វះបានយសហើយ ព្រលើយវិញណា យសនោះប្រែជា វិ-នាសពីប្រាណ ។ ហេតុនោះនៃ កូនអើយមិនក្រែ ចិត្តជាប្រធាន មានដោមស្អាងស្អាត មារយាទបើគ្មាន ស្មើឥតវិញ្ញាណ សោះសូន្យអសារ ។

អ្នកមានប្រាជ្ញា លោកយកចិត្តជា ខ្ញុំមខ្លួនតែងជារ វិញ្ញាណជាអាទិ៍
មារយាទជានា ស្មារតីដេញដាល លោកទោសមោហា ៗ ហេតុនោះកូន
អើយ ចិត្តកូវជាត្រើយ ពំនាក់អាត្មា ចិត្តជាប្រធាន ប្រៀនប្រាណ
សុខសា- បាយបទចិត្តជា អម្ចាស់រូបហោង ៗ ហៃបាធម្មបាល បុត្រ
ច្បងសង្ស្ការ ព្រះជនកស្ងួនគ្រង ពីថ្ងៃនេះទៅ បានៅរៀនរង គំនិត
គាប់ហោង បំរើមហាក្សត្រ ៗ កូនអើយកាលបា ចូលគាល់ក្សត្រា
លោកប្រើប្រយ័ត្ន ស្រគត់ឥន្ទ្រិយ ដោយក្តីប្រតិបត្តិ កុំបាផ្សៀងចិត្ត ហាវ
ហានសោះសា ៗ កុំខ្លាចពេកពន់ កុំហ៊ានលើសលន់ តើពោលពាចា
កុំធ្វើជំកើង ករន្ទ្រិងអាត្មា កុំធ្វើសោះសា គ្រឡាគំនាល់ ៗ ចូរបាតាំង
ចិត្ត ប្រកបសីលក្រិត្យ ប្បាស់ច្បាប់ទូវធម៌ ប្រកបប្រាជ្ញា ពិចារណា
ស្គាល់ ព្រះក្រិត្យអម្បាល កាលគាន់រដូវ ៗ កូនអើយបើបា សព្វព្រះ
ទ័យា នៃព្រះតន្ទូ ពោះមានសុខុម នោះសមព្រះកូ- បាលបើកខ្សែបន្ទូវ
ប្រាយប្រាប់បាហោង ៗ កាលព្រះពជា ក្សាន្តខ្សែបប្រាប់បា សព្វ
សេចក្តីផង ចូរបាលបលាក់ រួមរក្សាគ្រង ក្តីសុខុមនោះហោង ទុក
កង៍ទ័យា ៗ បោតុព្រះអង្គសុំទ ស្នេហាទុកចិត្ត ឯកឯងតែបា ល្អិតអ្ញី
បាស្រោល បណ្តាលពាចា ប្រាយប្រាប់ឲ្យជា សាធារណ៍ក្តីនោះ ៗ ទីង
ព្ទុទ្ទ័រ ផ្ដិតផ្ជាបព្រះកាណ៌ ក្រេវក្រោធសុះសោះ គ្នាន់ព្រះទ័យា
ដោយនាទោសនោះ ត្រង់ត្រវចំពោះ ដូចផល់បាហោង ៗ ទោះមាន

កិច្ចការ ផ្ទះក្រោមគេហការ ក្រៃក្រសួងផង មានព្រះតម្រាស់ ត្រាស់ប្រើបាហោង ដោយព្រះបំណង បំណង់ហាទ័យ ។ ចូរបាទស្រាហ៍ដោយគុណប្រាជ្ញា ស្រះសព្វថ្ងៃ ចូរបាកើន ចំរើនរឹងក្រៃ ដោយដូចហឫទ័យ អ្នកជាម្ចាស់ ។ កិច្ចការកាលណា សោតសឹងប្រើបាកាន់ព្រះតម្រាស់ ចេញចែកភ្នាក់ងារ កាន់ការឲ្យច្បាស់ ដោយព្រះតម្រាស់ តំរិះឲ្យធ្វើ ។ ក្តូនអើយបាចូរ ចាំព្រះបន្ទូល អម្ចាស់ប្រុងប្រើ បៀងជាក់ក្នុងចិត្ត ពិនិត្យឲ្យធ្វើ ដោយនូវអំពើ ការកុំប្រហែស ។ បាចេញទៅថា ប្រាប់អស់ភ្នាក់ងារ រៀនហ្វឹងពិសេស ចែកចូលកាន់ការ ភ្នាក់ងារលៃបលេស កុំបាប្រហែស លុះលង់កំណត់ ។ អស់លោកផងនោះ សឹងយោធាគ្នោះ អាមាត្យព្រឹទ្ធព្រទ្ធ បាចែកកំណាន់ការកាន់ដោយបទ កុំបារខ្ជត់ ជ្រែដោយធន្ទា ។ រីផងជញ្ជីង ក្អកទៀងសុះសឹង សាយសព្វយល់ប្រា- កដកាន់លើកឡើង ថ្កល់ថ្កើងលោ ធារទ្រង់ស្មើគ្នា ពុំខុនពុំដើយ ។ លោតែងធារ ក្អកទៀងប្រការ ម្តេចមិញក្តូនអើយ បាយកប្រាជ្ញា ពិចារណាហើយ មធ្យស្បូរឆ្លើយ ដោយក្តីកោតការ ។ ទោះយប់ទោះថ្ងៃ រាជកិច្ចការនៃ ក្សត្រាទ្រង់ធម៌ បន្ទូលត្រាស់ប្រើ បាធ្វើសព្វសារ- ពើពីព្រះហា - ទ័យទើបទៀងហោង ។ បាយកប្រាជ្ញា ចេះពិចារណា រាជកិច្ចការផង ញឹកៗប្រក្រតី កុំបំឲ្យឆ្គង កុំកាន់លេង លើសលែងអាញ់ ។ មួយសោតថាបើ ព្រះអង្គប្រាប់ប្រើ

ប្រដាប់មាគ៌ា ចូកចាំងប្រាលប្រាប ពលភពសោភា ជាពជមាគ៌ា នៃ មហាក្សត្រផ្ដោះ ៗ កុំបាបណ្ដាល ចិត្តចង់ត្រអាល ដើរទៅផ្លូវនោះ រ៉ ទោសទណ្ឌភ័យ កើតក្រៃបំពោះ ដល់បាឯងស្មោះ ហៅប្រមាទបក្រី ៗ កុំបាសេពសម កាមគុណប្រឡំ ជាមួយអគ្គឥ- សូរសព្វទ័យា ដោយ នាប្រក្រតី កូនអើយកុំបី បាត្រាប់ព្រះអគ្គ ។ ទោះបីមាលា គ្រឿង គ្រប់គន្ធា បុប្ផាភ្ញីផ្ចង់ ក្របេះបួងចន្ទន៍ សុគន្ធច្រើនប្រចង់ ប្រដាប់ ព្រះអគ្គ តែងទ្រង់សព្វថ្ងៃ ៗ ពុំនោះព្រះពារ ពស្ត្រាបវរ ព្រះភូសា ថ្ងៃ សែសយផ្ដិតផ្ដាស បេសមាសទ្វារ ខ្ទប់ព្រះអង្គ ស្ទាប់ព្រះ ជង្ឃា ៗ គ្រឿងណាព្រះអគ្គ បពិត្រតែងទ្រង់ កូនអើយនោះបា ពុំគប្បីស្អាង រូបកងអាត្មា ប្រហែលក្សត្រា អម្ចាស់លើសក្រៃ ៗ មួយកុំបាធ្វើ ប្លែកប្លែងអំពើ ក្រិត្យក្រមវិស័យ ជាក្រមក្រិត្យមហា- ក្សត្រាជេស្ឋជ័យ អំពើនោះនៃ ពុំគាប់បាឡើយ ៗ កុំពោលពាក្យធំ សូរសើចប្រឡំ អម្ចាស់ត្រាណត្រើយ កុំពើវចា ដែលមហាក្សត្រ ឡើយ កុំសងពោលធ្វើយ ត្រាប់ត្រង់វិលវល់ ៗ មួយទោះព្រះអគ្គ ក្សត្រាស្ដេចគង់ នៅបរិពារពល ស្រីគ្គារស្រស់ស្រី មហេសីសួស្ដី សល់ ក្សាន្តហាទ័យដល់ ស្រើបស្រួលសប្បាយ ៗ កុំបាធ្វើស្និទ្ធ ស្នេហាបួលចិត្ត មេត្រីពេះពយ ទីងពជទេពី នារីទាំងឡាយ កុំសើច សូរសាយ លេងលេញទៅមក ៗ ទោះទៅស្ថានស្ងាត់ ចូរបាប្រយ័ត្ន

ប្រយោជន៍ឲ្យល្អ កុំបាស្រដី ពាក្យពីរោះរក៏ កលកិច្ចទៅមក លលោម
លេះលាក់ ៗ រីព្រះពជទ្រព្យ ភ្នាក់ងារណ្ដាប់ ត្រួតត្រាជៀងជាក់
ទុកព្រះឃ្លាំងខ្ជាប់ អ្នកកាចលួចលាក់ កុំបារើដាក់ រើសរកយកឯង ៗ
កុំដេកដល់ថ្ងៃ ពេកពន់វិស័យ លើសលោកគម្ពែង ពុំគិតកិច្ចការ
ភ្នាក់ងារខ្លួនឯង យល់ថាពុំក្រែង ការគាន់អាជ្ញា ៗ ស្រាស្រាល
បង្អាត ពាក្យពោលវិវាទ ទោសទណ្ឌភយា ពក្រៃងបញ្ចុក ទោស
ទុក្ខអាត្មា កូនកុំសេពស្រា ស្រវឹងហើយគាល់ ៗ ទោះព្រះចក្រ-
ពត្តិមបក្ស អម្រឹតរង្គារ កុំបាបង្ហិន បៀនបិណ្ឌទៅញល់ បាជ្រោម
ជ្រែងការ រក្សាគ្រប់គ្រង ៗ គ្រែគ្រឹះគុភាំង ទែនទំព្ញទីនាំង បល្ល័ង្ក
រៀបរង ហត្ថីអស្វា រថយានផង ទោះទូកសោតហោង កុំបាឡើង
ស្និត ៗ កុំបាបណ្ដាល ចិត្តអន្ធពាល ថាស្ដេចស្នេហ៍ស្និទ្ធ ករុណា
ឲ្យមាន អស់យានអញស្និត កុំបាទុកចិត្ត ឡើងស្និតឯងឆ្ងាយ ៗ
បើបាចូលគាល់ កុំបាផ្ទួរផ្ទាល់ អម្ចាស់ពណ្ណរាយ កុំទៀបពេកពន់
កុំលន់លាកឆ្ងាយ កុំបាលេងលាយ ប្រឡំពាលា ៗ គាល់គយរំពៃ
ឆ្ពោះព្រះនេត្រនៃ ទតយល់នោះណា កុំបាផ្អៀងផ្អង តែងតែកហត្ថា
កុំលលុកគ្នា លេងលើគំនាល់ ៗ កុំទុកចិត្តថា ព្រះបាទក្សត្រា
ទ្រង់ព្រះក្រសាល សព្វព្រះយេនឹងអញ ស្រឡាញ់កោតការ កុំថាស្ដេច
ខ្ញាល់ ស្អប់អញពេកក្រៃ ៗ ទោះបីព្រះអង្គ ក្សត្រាទ្រើសទ្រង់

ករុណាបានៃ ឲ្យទ្រព្យាករ បវរលើសក្រៃ សព្វព្រះហឫទ័យ ទិព្យទែន
ឧិនបា ៗ កុំបាអួតអាង លើសលើខុនណាង មន្ត្រីយោធា ថាស្ដេច
ស្រឡាញ់ តែអញឯងណា កុំអាងអាត្មា លើសលែងលោកធង ៗ
កុំបាប្រទូស្ត ស្រដីវង្វេស ពោលពាក្យផ្ដាំផ្ដង ទង់ព្រះអង្គឥ- សូរពិ-
សេសហោង កុំបាឃើសឃ្នង លែងលោកសម្មាយ ៗ រីពផ្ទារ
លោកដាក់ភ្នាក់ងារ រក្សាសព្វសាយ គួរបើកគួររាំង គួរខាំងគួរស្រាយ
កុំបាពាយផាយ ហាវហានចូលឯង ៗ កុំបាធ្វើសិទ្ធ ស្នេហាទុកចិត្ត
ចេញចូលឥតក្រែង កុំអាងអាត្មា ដង្វិតជាធំឯង យល់បាពុំក្រែង ក្រិត្យ
ព្រះរាជា ៗ រីកិច្ចក្រិត្យក្រម ក្សត្រាឧត្តម ពុំងាយណាបា ប្រដូច
ភ្លើងហោង អ្នកផងរក្សា បើបេះកាន់រាំ ជាឥតសង្ស័យ ៗ ល្គឹកអ៊ី
ប្រហែស ភ្លើងនោះលុះលែស ឆេះឡើងលើសក្រៃ រាលរោលអាត្មា
ដល់នាលុះក្ស័យ នូវកើតកិតភ័យ ក្រៃក្រប្រមាណ ៗ រីរាជត្រកូល
អម្បាលអម្បូរ ព្រះញាតិប្រធាន បុត្រាសោភី បុត្រីកល្យាណ ទោះ
ព្រះអង្គមាន ព្រះរាជករុណា ៗ ពុំនោះស្រុកធំ នគរសោតសម
ខេត្តខណ្ឌសីមា ទោះនាយដំរី សារថីរថា ខ្ទាន់កាន់រក្សា ថ្មើរជើង
ដំរិត ៗ សម្ដេចក្សត្រា សព្វព្រះទ័យា នៃព្រះបពិត្រ នៅទ្រង់
ករុណា ដោយនាស្នេហ៍ស្និទ្ធ ទោះយសសម្បត្តិ សម្បូណ៌អ៊ី ៗ ៗ

កូនអើយកាលណា៖ ប្រគាល់ចំពោះ ព្រះនេត្របក្រី បាត្រព្រះសូរ បន្ទូលពេះរ៉ែ ពេះពយស្រដី ឆ្ពោះព្រះករុណា ៗ ទំនើបពស្ទុអ៊ី ធន ធានព័ណ៌ពី· សេសសព្វទ័យា ពុំគិតពុំស្តាយ ថែកចាយបេញផា ផ្ទោនអ្នកណា សព្វព្រះទ័យនោះ ៗ កុំបាទូលទាស់ លើព្រះតម្រាស់ តម្រិះឯងស្មោះ កុំកែកលកិច្ច ឲ្យដាច់លាភនោះ កុំកែកលដោះ ឲ្យ សោះសូន្យទេ ៗ កុំកាំងកុំព កុំពោះពោលពា ត្រណាក់ចិត្តគេ កុំកែ ទំខាត បង់ឃ្លាតឃ្មៀងឃ្មេ ឲ្យដាច់លាភគេ វិនាសបង់បាត់ ៗ កូន អើយធម្មតា អ្នកមានប្រាជ្ញា លោកប្រើប្រយ័ត្ន ស្រគត់ឥន្ទ្រិយ ដោយក្តីប្រតិបត្តិ កុំថ្ងួសខ្លោយមាត់ ពោលពាក្យឥតត្រែង ៗ កូន អើយបើញ្ញោះ លោកថាបាបនោះ បៀតបានបាឯង ពៀរប្រការកម្ម បងចាំពុំត្រែង បាបដៀតមាត់ឯង ទាស់ទែងទានគេ ៗ បំណោគៅនៅ នរកព្រាំព្រៅ ទល់ទុក្ខឥតល្ហែ បាបបទបន្ទាន ធនធានទានគេ បាបបាកចិត្តគេ នោះរឹងបាបក្រៃ ៗ ឫស្សីល្អគលាស់ ដើមដុះខ្ពស់ ណាស់ ដុងដោមត្រៃឈ ញ័រអស់អង្គុន លំទោនពក់ពៃ ដោយ ខ្យល់បក់នៃ ប្រការម្តេចមិញ ៗ ពុំនោះដូចជ្ញ ជាងដៀងត្រិះត្រូវ បិតពោសកោសបេញ សម្រេចសម្រួល ទន់ស្រួលបានបាញ់ ប្រការ ម្តេចមិញ ពាក្យពោលញ្ញោះហោង ៗ ចូរបាក្រវែន ទប់ទល់ចំរែន ដោយដានគន្ធង សម្តេចក្សត្រា ករុណាឯងហោង នៃអ្នកនោះផង

សុខសាន្តសោមនស្ស ។ អរព្រះករុណា អរមួយដង្ហែតបា ជ្រោម
ជ្រែងតម្រាស់ ដ៏លោកគុណគាប់ សូរសព្ទក្រៃក្រាស់ ដល់បរលោក
ច្បាស់ សោយ៏សុខសួគ៌ា ។ អំពើគុណគាប់ នេះហោងជាច្បាប់
ច្បាស់នៃអាត្មា ទីងជាអាមាត្យ វរបុត្រក្សត្រា សព្វព្រះទ័យា យស
យីនថេរបិត ។ កូនអើយក្សត្រា កាលគង់ក្រឡា គំនាល់ជុំជិត ទ្រង់ព្រះ
ក្រសាល អម្បាលស្នេហ៍ស្និទ្ធ នោះសឹងពោលពិត ទូលទៅទៃ ។
កូនកុំថាច្នោះ គាល់គយចំពោះ ព្រះនេត្រទិព្យថ្ងៃ គួរគប្បីថ្លែង សំដែង
សម័យ បើពុំគួរនៃ ស្ងៀមក្រៃគួរជា ។ ទោះមានសន្ទុះ អាចអត្ថរករៈ
ក្នុងព្រះទ័យា នូវចង់ជីងជាន បាមានប្រាជ្ញា បែព្រះភក្ត្រា ផ្ពោះមក
ដណ្តឹង ។ កូនកុំបាលង់ ពេកពេញចិត្តផ្ទង់ ទូលដោយដំណឹង ដំណើរ
ដំណោល ប្រការផ្សេងៗ អាថ៌នោះឲ្យដឹង ច្បាស់ច្បាប់ធម៌ថា ។ ពាក្យ
ពោលសារសត្យ លក្ខណ៍លែបល្អិតក្កាត់ សូរសព្ទវាចា ទូលជាទិទាន
ដោយដានកគត់ មោះនោះកុំបា សាំសិនប្រើនពេក ។ បូរបាឧស្សាហ៍
បំរើបិតា មាតាតរេក គុណគម្ភីរសា· គរមហាអនេក អនន្តតរេក ដុង
ដោមខ្ពស់ក្រៃ ។ អណ្តាប់រៀមច្បង គោតកុំឃ្នើសឃ្នង រក្សាសព្វ
ថ្ងៃ អម្បាលអម្បូរ ត្រកូលហ៊ានហៃ រក្ខរមូលមៃ ត្រៃត្រែកស្នេហ៍-
ស្នង ។ បូរបាខ្ជាសបាប វៀរអស់ជពប ជីវិតសត្វផង វៀរកិច្ចកល
កាប អង់អាចឃ្នើសឃ្នង វៀរទោសទណ្ឌផង លះលែងក្រេវក្រោធ ។

ចូរបុត្រសព្វាហ៍ ស្វះស្វែងប្រាជ្ញា រៀនរិះចំណេះ គម្ពីរធារធម៌ អស់អាចស៊ុះសោត កិច្ចកលចំណេះ ឥតឯមានចូល ។ ចូរបុត្រចាំចប់ គម្ពីរសៀវសព្វ- គ្រោះគ្រោះយុគយល់ ទំនឹមទំនាយ ប្រុះប្រាយឥតចូល ស៊ុះសារពើកល កិច្ចកងសាស្ត្រា ។ ចូរបេះផ្សំផ្ចាំ កិច្ចកលកាយកម្ម អាថ៌អាទ៌ពេក ជាថ្នាំប្រាំសប្រោះ បុរសនានា ចូរបុត្រសព្វាហ៍ សង្គ្រោះញាតិជង ។ ទោះសារពើការ ជាងជៀងសព្វសារ- ពើពណ៌ ឥតខ្ចង់ ត្រូវគន្ធ្រិត្រាប់ ក្បូរក្បាច់ភាពជង ចូរបុត្រចាំចង ចិត្តបេះស៊ុះសាយ ។ វិគុណប្រាជ្ញ ទោះគុណសាស្ត្រា គំនាប់កេរ្តិ៍ឆ្ងាយ ជាយានបំពេរ កើតកេរ្តិ៍ស៊ុះសាយ ទសទិសសម្លាយ រូបផលស្ទួគា ។ នេះហោងកូនអើយ ប្រាជ្ញជាត្រើយ ពំនាក់អាត្មា ស្មារតីកុំដាច់ ភ្លាំងភ្លេចឡើយណា ចូរបុត្រសព្វាហ៍ ព្យាយាមលំនៅ ។ អ្នកចាស់ព្រឹទ្ធស្រមណ៍ព្រាហ្មណ៍គណា- ចារ្យចាំស័លស៊ុទ្ធ ពហុស្សូតសព្វ ច្បាស់ច្បាប់ត្រៃត្រិត កិច្ចកម្មការកត់ ព្យាយាមកុំបង់ ។ អស់លោកនោះហោង ចូរចាក់ប់នែ រួសរិះបម្រុង គោរពប្រតិ- បត្តិពិសេសជូនហទ័យត្រេកត្រង់ អនុទនសន្ទា ។ ចូរបុត្រចំអែត គោជន៍ពស្តុពិសេសពិសុទ្ធនានា ប៉ារ៉ែអវៀ ជួចដោយប្រាជ្ញា ចូរបុត្រសព្វាហ៍ បំរើកុំដាច់ ។ អោះមានសទ្ទិះ កន្ទាវែងរិះ កុំបាភ្លាំងភ្លេច ត្រង់ណាកិច្ចកល ឆ្ងាយ

ធ្លល់តុំស្រេច លោកនឹងសម្រេច សម្រាលបាហោង ៗ ចូរបានុនអង្គ
ជិតផ្លូញ្ញាទៅត្រង់ ស្រមណ៍ព្រាហ្មណ៍ព្រឹទ្ធជន ជណ្តឹងត្រង់កម្ម ទឹង
នាំរូបរង់ កម្មកើតចាំចង់ ជាតិជារោគ ៗ ម្តេចហៅសុខសឹង ម្តេច
ហៅតាំទឹង តាំនាក់អាត្មា លោកិយក្សេមក្សាន្ត លុះបានសួគ៌ា អំពើ
នោះណា ប្រការម្តេចសោត ៗ ម្តេចហៅទៀតាន ចាំសីលសមាទាន
លះលែងក្រេរក្រោធ ម្តេចលោកទោសោ មោហោសោះសោត ម្តេច
ហៅអ្នកឆោត កាន់វេរប្រាំ ៗ វេរវៀរបី សឹងកើតអំពី អង្គអាទិ៍
កាយកម្ម មនោវាចា វេរចោមចាំ ម្តេចនឹងឲ្យនាំ ចៀសចាករដោះ ៗ
ស្រមណ៍ព្រាហ្មណា- ចារ្យចាស់ព្រឹទ្ធា អស់លោកទាំងនោះ សឹងមាន
មេត្តា ករុណាអនុគ្រោះ ស្រាយអស់ហេតុនោះ សណ្តាប់បាហោង ៗ
កូនអើយកាលណោះ នាលោកអនុគ្រោះ អស់កន្លាជន ចូលបាដៀង
ជាក់ រួមរក្សាត្រង់ ធម៌នោះឯងហោង ខ្ញូនាទអាត្មា ៗ ចូរបាដំកល់
ចិត្តតែកុសល ត្រង់តែកសទ្ធា ស្វមស្មោះកំសត់ ទុគ៌តកំព្រា ចូរ
បាខុសស្លាហ៍ ឲ្យទានកុំដាច់ ៗ កុំបង់សីលា សីលសេពភាវនា កាន់
កុំបីភ្លេច កុំស្រោលស្រេបស្រែ ទានគេកុំផ្តាច់ កុំរិះគលកិច្ច ចៃណែន
លោកផង ៗ ពស្ត្រទាសការកម្ម ក្សណក្ស័យដោកជាំ ហីនហៃហ្មត់
ហ្មង កូនអើយនោះបា រក្សាហោង កុំបាឲ្យឆ្គង ធ្វើទុក្ខានោះ ៗ អ្នក

កាចរឹងរូស កុំបាប្រទូស្ត ប្រទះឈ្លូសឈ្លោះ កុំបាពោលពារ នូវអំ
ទាំងនោះ រាំងស្ងួនស្នោះ គន្ធគតពាំទីង ៗ ខ្ញុំអសារ បាជាអាជារ
សត្វជង្គាកពាំង កុំបាបង្ហិន បង្កិនរាំទីង ក្បៀរខ្សត់កុំជីង ពេក
ពេញខ្ញុំក្ដខ្ចល់ ៗ ចូរបារក្សា ចិញ្ចឹមស្ងួនភ្ជា នៅទីងសុខសល់
នេះហៅស្នេហ៍ស្នង នេះហោងជាផល អាចនានាំដល់ មោក្ខមាគ៌ា
សារ ៗ កូនអើយមួយណា ព្រះបាទក្សត្រា សម្ដេចភូបាល សព្វព្រះ
ទ័យា ទ្រព្យណាត្រកាល កងខេត្តបរិបាល ព្រះអង្គឯងនៃ ៗ
ប្រើបាទៅយក នាំទ្រព្យនោះមក ដូចព្រះហទ័យ បាកុំពោរពារ
ទីងអាថ្ងៃ ចូរបាធ្វើមែ- ត្រិត្រកចូលចិត្ត ៗ ទោះបីកម្រ ចូរបា
លោមល ដោយនូវសុចរិត គេហោងទីងភ្ជាប អំណាចបពិត្រ មួយ
ភ្ជាបចរិត បាបិទសេចក្ដី ៗ កុំអាងអួតធំ ដើមដល់ខៀនខំ ពោល
ពាក្យអប្រិយ កុំអាងអាត្មា ដ្បិតជាមន្ត្រី កុំរកគេស៊ី បង្ហិនក្រស្តផង ៗ
ក្រស្តផងត្រជាក់ ដ្បិតបានពំនាក់ ទីងអ្នកធំហោង ល្អកធំកុំនៅ លំនៅ
ក្រស្តផង ក្រស្តរឹងក្ដៅហោង អគ្គឥតអាស្រ័យ ៗ កូនអើយលោកថា
មច្ចោមច្ចា ពីងគង្គានៃ លំនៅឯភ្នា ពីងភារព្រឹក្សព្រៃ ក្រស្តទាសខ្សត់
ខ្សៃ ពីងអ្នកធំជារ ៗ កូនអើយចូរបា រៀនរ៉ះអធ្យា- ស្រ័យសព្វប្រការ
ប្រុះប្រើយង់យល់ ដឹងកលដឹងការ ដឹងកិច្ចតែងជារ- នាក្រស្តមណ្ឌល ៗ

ឲ្យដឹងរដូវ ដឹងការទាទៅ ចែកទានស្កប់ស្កល់ ឈ្លាសដឹងអំពើ បំរើកុំធ្វល់
ដឹងកិច្ចកម្មកល ការស្រែចំការ ។ ចូរបុធ្យាស្រ័យ ដោយនូវវិស័យ
អំពើការងារ គួរគោកគួរទឹក គួរផឹកភោគ្គា គួរស្រែចំការ ការកាន់ដោយ
បទ ។ ចូរបារំសាយ បាវព្រាវតាំងឡាយ ទៅដោយកំណត់ កំណាន់
ការងារ សព្វប្រការកត់ ចូរបាផ្គង់ផ្គត់ ដណ្ដឹងងារផង ។ ទោះស្រែទោះ
ភ្លឺ ទោះគោក្របី ចំណាររបង ទោះបានទោះបង់ ទោះគង់សោតហោង
មើលកលការផង ដោយអធ្យាស្រ័យ ។ រដូវការងារ ស្រោចបាច់កាល
ណា អំពើទទៃ នោះឲ្យគណនា ត្រួតត្រា ស្វយរៃ រៀងដោយវិស័យ
បុព្វណាកដា ។ បាមើលអាចិក្ដី ណាគួរគប្បី ដោយខ្នាតមាត្រា កុំបី
ខិតខំ តាមកំឡាំងងារ យកដោយអធ្យា-ស្រ័យស្រួលចូលចិត្ត ។ រីទ្រព្យ
ជន្ទាយ កុំបាសាយកាយ បាត់បង់ពុំគិត ចូរបាត្រួតត្រា គណនាពិនិត្យ
ឲ្យអ្នកទុកចិត្ត រក្សាគ្រប់គ្រង ។ ចំណេរបេរទៅ ទោះញាតិទោះផៅ
ខ្សត់អត់ឃ្លានផង ចូរបាអនុគ្រោះ លំដោះស្ទួនគ្រង ចិញ្ចឹមរឹមរង
ដោយធម៌បុណ្ណ ។ រីគុណអនុគ្រោះ គុណបុណ្យលំដោះ សុខទុក្ខ
ស្រែកឃ្លាន នោះហាងជាផល កុសលជាយាន នាំអាត្មាបាន ត្រិពិធ
សម្បត្តិ ។ រាស្ត្រទាសការកម្ម ក្លួចកើតក្ដីកាំ ភិតភ័យពេកក្ដាត់ រំរេក
ពំនឹង ពាក់ពឹងបាថ្កាត់ កុំបាស្មៀមស្ងាត់ ក្រីក្រទីងងារ ។ អាស្ងូវកំសក

អាសូរទុគ៌ត អាសូរកំព្រា អាសូរត្រមោច ហ៊ានហោចឥតគ្នា ឆ្ពោះមកកាន់បា ដាម្ដាយសត្វផង ៗ ចូរបារមើល ក្ដីទាំងពីរ ឯណាឆ្គាំឆ្គង បាកាត់ដោយបទ ចូលចិត្តផង កុំបារំលង វែងធម៌បុរាណ ៗ មួយទោះក្សត្រា ស្ដេចគង់នៅនា - ទីព្រះរាជស្ថាន ពពួកស្រីគ្គារ ធីរជាក្សេមក្សាន្ត កុំបាហៅហាន នាំក្ដីចូលទូល ៗ អាថ៌នោះពុំគាប់ ពុំជួជាច្បាប់ នៃរាជ-ត្រកូល ហៅក្ដីប្រមាទ ព្រះបាទឥសូរ ទោសនោះពុំយូរ ជួបដល់បាណា ៗ កុំពឹងសក្ដិបុណ្យ កុំពឹងមានគុណ កុំពឹងប្រាជ្ញា កុំពឹងជាចិត្ត វែងស្និទ្ធស្នេហា កុំពឹងករុណា អម្ចាស់សួនត្រង ៗ កូនអើយលោកថា ពពួកភាព សហស្សពាន់ផង ពុំស្មើព្រះចន្ទ្រ មួយស្បាន់កន្ទុង សហស្សទូកផង ពុំស្មើរកត្រា ៗ លោកថាស្ទឹងធ្នារ សហស្សសហា ជន់ជោរមហិមា ត្រដែតត្រដាប ស្ទាបសឹងគ្គា មោះពុំស្មើមហា - សមុទ្រមួយជ្រៅ ៗ ទោះគណនាគុណ សោតសល់ពាន់ធូន អនេកទូទៅ ស្មើមួយអគ្គា អាត្មានិត្យនៅ ទោសមួយចូលទៅ គុណនោះបាត់បោង ៗ កូនអើយមួយណា ក្រិត្យក្រមទឹងជា អាមាត្យក្សត្រផង ក្រទឹងរក្សា អាត្មាកន្ទង វែងទោសទុក្ខផង ភ័យកិតអន្ត-រាយ ៗ កូនអើយអ្នកប្រាជ្ញ ផងពុំដែលអាច គិតក្ដីស្រស្រាយ លោកផ្គត់ស្មាតើ ឥតប៊ីសោយ ហេតុបទលោកណាយ ដំនៀលនិទ្ទា ៗ អស់

អ្នកប្រាជ្ញផង លោកយកចិត្តបង ចាំបទគាថា អាចឲ្យរកទាន ខ្នាន
គាត្នា ឲ្យគាប់ឲ្យជា ទើបខ្ញុំនាំគេ ។ លោកវៀរទោសភ័យ វៀរក្តី
ចង្រៃ ឲបទ្រព្យវៀរវេ វៀរពាក្យពាលា និន្ទាស្អប់គេ វៀរក្តីស្រាយស្រៃ
មិនឲ្យមានហ្មង ។ កូនអើយព្រះក្រឹត្យ ព្រះបាទបពិត្រ ក្រៃក្រកន្ទង
ក្រនឹងដឹងអាថ៌ សព្វសារពើផង ហេតុបទនោះហោង កុំបាប្រែហែស ។
ចូរបាផ្គត់ចិត្ត ស្មារតីពិនិត្យ ត្រង់អាថ៌លៃបលេស ញឹកៗ ប្រក្រតី
កុំបីប្រែហែស ហទ័យពិសេស កុំឲ្យមានញាល់ ។ បាមើលអាថ៌ក្តី
កាលព្រះបក្រី ទ្រង់ព្រះក្រសាល ពពួកស្រឹង្គារ បរិពារខ្ញៀវខ្ញារ
កុំបាផ្ទេរផ្ទាល់ គាល់ទៀបពេកពន់ ។ មួយកុំបាឃ្លាត កាលទ្រង់អា-
ពាធ ជម្ងឺស្រាលធ្ងន់ កុំបាណាតលះ ពីព្រះបាទគន់ បាជួយគិត
គន់ ជម្ងឺម្តេចៗ ។ បាគន់ទឹកស្រង់ គន់ទឹកសម្រង់ សម្រាប់កុំ
ក្អួច រកពេទ្យផ្សំថ្នាំ មកចាំកុំដាច់ រកហោរសម្រេច សម្រាលព្រះ
គ្រោះ ។ បាជួយគិតគន់ គម្ពីរមន្ត ស្រមណ៍ផងចំពោះ បំរើនមេត្តា
ផយាលំដោះ ព្រះជន្មព្រះគ្រោះ ទុក្ខទោសភយា ។ អម្ចាស់អផ្សុក
យកខ្លួនជាទុក្ខ ក្រៃវិញណាបា កុំគិតត្រង់ដេក ត្រង់ស្រេកឃ្លានណា
ចូរបារក្សា អម្ចាស់សព្វថ្ងៃ ។ ទោះព្រះទេពី ព្រះរាជបុត្រី បុត្រាថ្វា
ថ្ងៃ មានព្រះជម្ងឺ បាឈឺវឹងក្រៃ កុំឲ្យព្រះទ័យ ជាទុក្ខឡើយណា ។

អម្ចាស់រូវជ្រៃ(១) អ្នកផងអាស្រ័យ អម្បូរនាយា ទេពអម្ចាស់ រូមែក
សាខា ពជបុត្រផ្កា ពន្លកផ្លែនោះ ៗ នរអ្នកណា ទ្រឹស្តិទ្រស្ត
ប្ញស្សា បីកាន់កាប់ស្នោះ(២) ទោះត្រួយពន្លក ពោះធ្លាក់ទោះស្លោះ
ហៅមហាមិត្តទ្រស្ត បានបាបអវិចិ ៗ នរអ្នកផង បរក្សាគ្រង ព្រះ
ផ្លែនោះខ្ចី ប្រកបបុប្ផា ផលាផលពី- សុទ្ធសុគលាស់ខ្ចី មានផល
នោះផ្លែ ៗ មួយពោះព្រះអង្គ បពិត្រនៅស្រង់ ស្រប់ព្រះបាទថ្ងៃ
ពោះលើសិរសា លើខ្លួនបានៃ កុំបាសង្ស័យ ថាអម្ចាស់ស្អប់ ៗ បាទូន
សិរសា កបរធីបាទា ដោយព្រះទ័យសព្វ កុំបាទុកចិត្ត ថាអម្ចាស់ស្អប់
កុំបាថុំថប់ ដើមផល់អប្រិយ ៗ កុំថាតែម្ទេះ ក្រៅក្រៃលែងនោះ ផល
ប៉ុនាពក្តី កុំបាអាចហ៊ាន ដើមបានស្រដី ទូលតាស់ចក្រី ពុំគួរឡើយ
ណា ៗ រីឯរៃព្រៃផង ស្វែងលាភបំណង ចំណង់ប្រាថ្នា ទូលទឹក
ពេញក្អម ថ្ងូមលើសិរសា ករុសម្ម័ម្មា បិតទូលទឹកនោះ ៗ មាន
កាលបបាត ច្រៀងជាគាថ៍ ស្រែកយំចំពោះ លើកដៃមម្ញា វន្ទាសត្វ
នោះ ហើយពាក្យពីរោះ សរសើរជ័យសោភ ៗ មានកាលបិតឈើ
ប្លូនព្រឹងហើយធ្វើ គំរប់ការគោត ស្រាបាយអាហារ ត្រកាល
សាច់សោត បូជាកាន់គោត វន្ទាសក្តិថ្ងៃ ៗ ហេតុអ្វីដូច្នោះ ផ្សេង

---

១ រូវនេះជាពាក្យបុរាណ បានសេចក្តីថា "ដូច ឬ បីដូច" ។ ២ បី នេះ ... "ទោះបី ឬ បើ" ។

ចិត្តរំឆ្ពោះ ចង់បានលាភក្រៃ អំពើជាអាទិ៍ នេសាទជើរព្រៃ ចិត្តរំ
សព្រៃ លាភលុះប្រាថ្នា ៗ កូនអើយឥឡូវ សម្ដេចព្រះភូ- បាល
បុណ្យមហិមា បន្ទូលត្រាស់រក ឆ្ពោះមកកាន់បា ទូវកិច្ចកលប្រា- ការ
កម្មនោះហោង ៗ ព្រះបាទឥស្សូរ ស្ដេចជាកំពូល មកុដសព្វសត្វផង
មានព្រះហឫទ័យ ជ្រាស្រ័យក្ដាត់ហោង បេលអាជីកទ្ទង់ គប្បីករុណា ៗ

ហៃបាធម្មបាល បុត្រច្បងសង្សារ កូនអើយបើបា នៅជា
មន្ត្រី ភក្ដីក្សត្រា លែងចិត្តឥតស្វា- មីភ័ក្ដិអម្ចាស់ ៗ លែងចិត្តបា
ខ្ជាប់ ទៀងនៅដោយច្បាប់ នៃព្រះតម្រាស់ ត្រង់ណាអំពើ បាធ្វើ
ឲ្យច្បាស់ ត្រង់ណាក្រណាស់ បាគិតឲ្យឆ្ងាយ ៗ ទោះព្រះចំណាន់
ចិន្តាត្រេកត្រង់ សុខុមកុំស្រាយ ចូរបារកះ ត្រាប់ត្រិះឲ្យឆ្ងាយ
ឲ្យបានមកថ្វាយ ដូចព្រះទ័យា ៗ អំពើក្រៅក្រិត្យ លោកវែងពិ-
និត្យ សឹងជាងសឹងជា រក្សព្រះទ័យ ក្រៃក្រមហិមា ហេតុនោះ
ចូរបា ត្រិះត្រង់នោះហោង ៗ បាសព្វព្រះទ័យ អម្ចាស់សព្វថ្ងៃ
អ្នកនឹងសុខត្រង់ ដូចមហាមេឃា បង្អុរភ្លៀងផង ពីអាកាសកង
ចុះមកក្រៃក្រាស់ ៗ

ហៃបុត្រទាំងឡាយ ចូរស្ដាប់អាក់ប្រាយ អាជ្ញានេះឲ្យច្បាស់
ច្បាប់ពជស្នួស្ដិ៍ មន្ត្រីអម្ចាស់ ចូរបាជាក់ជាស់ ទុកក្នុងទ្រៃ ៗ នរូ

អ្នកណា នឹងចូលទៅជា រាជសេវកៈនៃ អ្នកនោះប្រុះប្រាជ្ញ ដឹង
អធ្យាស្រ័យ ក្នុងកិច្ចព្រះទ័យ ទំព្រទៀងឲ្យច្បាស់ ។ អ្នកនោះនៅ
បាន ក្រឃាប្រមាន អនេកក្រៃក្រាស់ សម្បត្តិសម្បូណ៌ ធានធន
ការពេស្ត យសយឹនបាប់ប្រាស់ លោកិយប្រាកដ ។ រាជសួស្តី
នៅជាមន្ត្រី គប្បីផ្គង់ផ្គត់ ឥតួកជាថ្លៃង សំដែងប្រាកដ ពូវចាំអស់
បទ ប្រការម៉េះហោង ។

ច្បាប់រាជសួស្តី ព្រះបាទចក្រី រាជសង្ការច្បាស់ច្បង ទ្រង់លើក
ទុកត ឲ្យនរជនជង សណ្តាប់ត្រាប់ត្រង ឯវំចប់ហើយ ។

ចប់ច្បាប់មហាគេតិរាជសួស្តី តែប៉ុណ្ណេះ ។

# ល្បើកច្បាប់ក្រឹត្យក្រម

របស់ព្រះគ្រូវិសុទ្ធវង្ស ទិត វត្តសិរីសាគរ ស្រុកត្របែក ខេត្តព្រៃវែង

នេះនឹងថាថ្លែងថែងតារចង លើកតាមទំនងជាកាព្យ ប្រាំពីរពាក្យ ពិតគិតបួនឃ្លា ចងជានិទានទុកប្រដៅ ។ អស់ទាំងកុមារក្មេងតូចៗ ចិត្តឯងនៅខ្ចីច្រើនខ្លាំងខ្មៅ ស្រើបស្រាលដោយសារខ្លួនឆោតឆៅ មិនតាមប្រដៅគ្រូសោកន់ ។ កាលណោះព្រះពុទ្ធសាសនា កន្លងហើយណាបានពីរ·ពាន់ បួនរយចិតសិបបីគ្រោះគ្នាន់ ឯខែគ្រប់គ្រាន់កន្លងគ្នា ។ ថ្ងៃកន្លងបានម្ភៃពីរ ទំនងគិតការញ៉ែគ្រងក្នុងបច្ចុប្បន្ន ឆ្នាំមមីទោស័កក្នុងគិម្ហន្ត រដូវខែជេស្ឋប្រាំបីកើត ។ គោនុនាមាអាត្មាភាព បំរើនពរជ្រាបឈ្មោះកំណើត ទិតគិតពិគ្រោះឃើញក្បាក់ព្រើត ចិត្តកើតសង្វេគចេញបញ្ញា ។ សាមសិបប្លាយឆ្នាំជាកំណត់ នៅវត្តសិរីសាគរ ឃុំខ្ចណ្ឌត្របែកក្នុងតាមា រួមខេត្តព្រៃវែងស្រុកបាភ្នំ ។ ខ្ញុំមានសិស្សកុមារច្រើន ស្រដីជាសំនៀនរ៉មិនខំ បានជាគិតលើកល្បើកក្រិត្យក្រម ឲ្យរៀនខិតខំកុំឲ្យធ្វេស ។ ហៃអស់ពួកក្មេងកុមារ ចាំទុកពល់គ្នាកុំប្រហែស ប្រតិបត្តិតាមបែបយ៉ាងន័យៈនេះ អ្នកកុំសន្ទិះនឹងបេះបាន ។ ក្ញាក់ឡើងពីព្រឹកនឹកបំណោះ ដែលខ្លួនរៀនចេះចាំប៉ុន្មាន ខំរន្ធញឲ្យស្ទាត់មាត់កុំខាន ដ្បិតទើបនឹងបានរៀនថ្មីៗ ។ ហើយឲ្យអ្នកផ្ទៀតរៀនអក្សរ អក្ខរាឲ្យល្អរៀនសំដី នព្វន្តខេរចិនឲ្យស្ទាត់ដៃ

លោកិយនេះគ្រាន់ប្រែឲ្យគេ ៗ ហើយឲ្យអ្នកឆ្លៀតរៀនបាលី នោះទើប គប្បីកុំទំនេរ មើលសូត្រឲ្យស្ទាត់ចាំមាត់ទេ ដល់បាពៅប្រែថ្វាយអាចារ្យ ៗ បើប្រែរួចហើយទៅដល់ស្ថាន កុំខ្ជិលប្រះប្រាណពោះសាស្ត្រា ពីដៃ ហើយដេកធ្លោចនិទ្រា មិនត្រួតត្រាការវិជ្ជាខ្លួន ៗ ចំណាំវិភត្តិបទបច្ច័យ អាចារ្យប្រាប់ន័យចាំឲ្យមួន ហោងអានរំឭកមើលថៃធួន បើចួនភ្លេចសព្ទ សួរគ្នាឯង ៗ បាចូរប្រតិបត្តិសួរអាចារ្យ វិបត្តិអក្ខរាឲ្យជាក់ស្តែង សូមទាន ករុណាចូរសំដែង ថ្វាថ្លែងប្រាសប្រាប់តទៅទៀត ៗ អាចារ្យសំដែង ប្រាប់សិស្សថា អក្ខរោមាលាតាមដោយប្រៀត នឹងប្រែអក្សរតាមសង្កេត រៀបរយតាមគេចាំឲ្យជាក់ ៗ របៀបប្រើពាក្យក្នុងលោកិយ ប្រើឲ្យគប្បី តាមអក្ខរៈ លោកយកប្រកបនឹងតួស្រៈ ជាពាក្យទ័យៈរស្សៈខ្លី ៗ ទ័យៈ លោកប្រើពាក្យយ៉ាងវែង រស្សៈនោះឯងប្រើពាក្យខ្លី ឯស្រៈមាននៅក្នុង បាលី នោះមានប្រាំបីអក្ខរ ៗ បើពាក្យណាសុទ្ធបាលីចំ លោកយក មកផ្សំនឹងពាក្យប្រែ ដូចជាពាក្យថាអ្នករៀនស្នេហ៍ នោះត្រូវការមេព្រោះ ហេតុតាម ៗ ពាក្យមួយលោកថាធ្វើត្រូវពេទ្យ ក្នុងអាណាខេត្តសត្វប្រែក ប្រាំ ពាក្យជាកិលេសវិសេសសាំ ព្រះគេជះចាំព្រះមហាថេរ ៗ យ៉ាង នេះយកស្រៈ (េ) មកប្រើ ដាក់តាមពាក្យស្មើដូចពាក្យខ្មែរ បាអានសំ ទៀងឲ្យបង្វែរ ជាពាក្យស្រៈ (ែ) វិញណាបា ៗ ផ្សិតពាក្យស្រៈ (ែ) យ៉ាងនេះនៃ នៅក្នុងបាលី គ្មានទៀយណា មានតែស្រៈ (េ) អក្ខក

នេះលោកពោលថាប្រើជួស (វ) ។ ហេតុនោះបានលោកយកមកប្រើ តាមបែបបទស្មើភាសាប្រែ យក (រ) នេះឯងតាងស្រៈ (វ) ចាំឲ្យជាប់ដៃ ណាទៅណា ។ ឯរឿងបទស្រៈ១ ឧទាហរណ៍ ដែលត្រូវអក្សរមេ-កកា ទុកសម្រាប់ប្រើក្នុងភាសា ក្រុងកម្ពុជាធិបតី ។ ចូរបាអានឲ្យប្រុងប្រយ័ត្ន កុំឲ្យបង់បាត់បែរសេចក្ដី អានកុំបំភ្លាត់បំភ្លៃស្ដី តាមន័យពាក្យឃ្លោងឃ្លា យារមុខ ។ ចូរបារាំងទាំងគួរខ្សល់ ប្រុងប្រយោគដល់ដោយទំនុក ប្រយ័ត្ន កុំអានឲ្យទន្គុក ផ្លូសទៅមុខហួសមិនត្រូវ ។ សេចក្ដីពាក្យណាមើល មិនចំ កុំថាបន្ទំរម្ងទៅ ចូរបាបង្អាក់ឈប់ចាំនៅ ទៅសួរលោកគ្រូសិន សឹមថ្លែង ។ កុំគិតចិត្តព្រើលខ្ចូបតែផ្ដាស ទៅគិតរៀនខ្មាសនឹងគ្រូឯង មិនហ៊ានទទឹងសួរទទឹងសំដែង ថ្លែងសួរពីរឿងហេតុនានា ។ យ៉ាងនេះដូច មានក្នុងបាលី បុរាណលោកស្ដីតៗគ្នា ខ្មាសគ្រូបាធ្យាយគ្មានវិជ្ជា ខ្មាស ភរិយាពុំមានកូន ។ ខ្មាសមហាក្សត្រខាតយសយាន ខ្មាសធ្វើសីលទាន គ្មានបុណ្យជួន ខ្មាសធ្វើការងារសោបស្មាត់សូន្យ ខ្មាសញាតិបងប្អូនគ្មាន ក្រៀវឡើង ។ ខ្មាសខ្ញុំកំដរខានះប្រការ ខ្មាសសុំអាហារពោះផតស្ដើង ខ្មាសបុណ្យយសស័ក្ដិពុំបានច្រើន ខ្មាសពួកអ្នកយើងខានធ្វើបុណ្យ ។ ខ្មាសបាវភ្នាក់ងារគ្មានអាង ខ្មាសពាក្យមុសាលក់ខាតទុន ខ្មាសអន្តេ-វាសិកខានដើរមុន ខ្មាសអ្នកមានគុណខានធ្វើកាច ។ ខ្មាសកូនខានស្ដី រៀនប្រដៅ ខ្មាសអ្នកព្រានក្រៅថយអំណាច ខ្មាសពាលល្ងង់ខ្លៅ

មានគេខ្លាច ខ្មាសបណ្ឌិតប្រាជ្ញពេញព្រៃលធំ ៗ ពាក្យចាស់ពីព្រេង តែងប្រឌិត មានមកមែនពិតដោយនិយម ពាក្យនេះមានមកពីបរម បុរាណចាស់ទុំជាដូច្នេះ ៗ ធម្មតាឯចិត្តគ្រូអាចារ្យ តាំងនមស្ការឲ្យ សិស្សចេះ ពុំមានលាក់លៀមទុកចំណេះ ចង់ឲ្យសិស្សចេះសព្វសេចក្ដី ៗ មួយទៀតរឿងដែលទងសិក្សា ចំណេះវិជ្ជាក្នុងលោកិយ លោកថាប្រកប ដោយអង្គបី នោះគឺស្មារតីទីងប្រាជ្ញ ៗ ព្យាយាមជាទីគំរប់បី ប្រែថា សេចក្ដីគឺឧស្សាហ៍ រីឯស្មារតីគឺសញ្ញា កំណត់កត់ត្រាការអ្វីៗ ៗ ប្រាជ្ញ វាងវៃនាមបញ្ញត្តិ ជាអ្នកអារកាត់សព្វសេចក្ដី ទៅខាងបរលោកឬលោ- កិយ កែខ្លួនឲ្យបានស្ថានល្អ ៗ បើបានគ្រប់ព្រមទាំងអង្គបី ប្រាជ្ញ រៀនអ្វីសោតពុំក្រ សម្បត្តិក្នុងខ្លួនទាំងបីប- រិបូណ៌បានល្អជាអ្នកចេះ ៗ រីឯស្មារតីគឺចេតសិក ឲ្យចាំរំឭកនឹកដម្រិះ កំណត់ចំណាំចាំចំណេះ បរិបូណ៌បានចេះស្រេចវិរិយា ៗ ទោះបីបើមានប្រាជ្ញច្រើន ថាបើចំរើន កោសជ្ជា កំជិលខ្ជិលក្រែមហិមា ពុំអាចធ្វើជាអ្នកចេះបាន ៗ ថាហៃ អស់អ្នកពួកទារក ចូរឲ្យចាំទុកក្នុងអង្គប្រាណ ឧស្សាហ៍ព្យាយាមយក ឲ្យបាន ទុកជាច្បាប់កាន់កេក្យខ្លួន ៗ មួយទៀតឯអ្នករៀនព្រះត្រៃ- បិដកថ្វាថ្ងៃតាមចំនួន លោកថាប្រកបដោយអង្គបួន នោះគឺ សុ. ចិ. បុ. លិ. ចាំ ៗ សុ. ប្រែថាឲ្យប្រឹងស្ដាប់គេ ចិ. គិតកាញ់គ្នេរខំចំណាំ បុ. ឲ្យសាកសួរតាមលំនាំ លិ. ឲ្យថែចាំពុំឡង់ទុក ៗ ធម្មតាអ្នករៀនរឿង

បាលី គឺព្រះត្រៃបិដកជាមុខ ចូរបាខំប្រឹងសរសេរទុក ក្រែងភ្លេច ទៅមុខបានមើលស័ព្ទ ៗ ជាបើប្រកបដោយអត្ថបួន បានគ្រប់ចំនួនដោយ អណ្ដាប់ សិក្សារៀនសូត្រក៏ចេះឆាប់ នឹងជាសណ្ដាប់ប្រាជ្ញពេហារ ៗ ជាបើបាឃាតប្រាសចាកជួន ពីអង្គកង្ខុនបួនប្រការ នោះឯងពុំបាន ជាអាចារ្យ រៀនដល់ចាស់ណាក៏ពុំចេះ ៗ ព្រះពុទ្ធដីកាព្រះអង្គត្រាស់ ទ្រង់ថ្លែងប្រកាសទុកដូច្នេះ កុមារអ្នកខំប្រឹងត្រេកត្រិះ គិតរករៀនវិះ អស់វិជ្ជា ៗ ឯចំណេះសិល្បសាស្ត្រសព្វ បើបានចេះចប់គ្រប់ហើយណា មិនបាច់នឹងព្រួយអង្គអាត្មា ទៅរកកាប់ឆ្កាក្លួរស្រែព្រៃ ៗ ជាបើនឹង ទៅទីស្ថានណា ទឹងមានឈ្មោះជាប្រាកដល្បី ពុំបាច់នឹងទៀតព្រួយ ស្ដាយដៃ ដើរតាមក្រោយគេទេណាពៅ ៗ ប្អូមួយទឹងទៅផ្គាប់ផ្គុន ស្ដេច នោះឯងមិនបាច់ទៅហាលក្ដៅ ករុណាកាន់ទ្រង់ប្រោសប្រាណ ពៅ ឲ្យយសស័ក្តិទៅជាអគ្គដ្ឋាន ៗ ះទោះបីក្រខ្សត់អត់ញាតិផៅ គង់ តែគេហៅរករាប់អាន ស្រឡាញ់ទុកដូចជាសន្ដាន គ្រាន់បានពឹងពាក់ គ្រាមានទុក្ខ ៗ ធម្មតាវិស័យរៀងចំណេះ បើបាបានចេះច្រើនគ្រប់មុខ ទោះបីបើនឹងមានទោសទុក្ខ គង់តែបានសុខស្រួលក្សេមក្សាន្ត ៗ ចំណេះ វិជ្ជាលោកថែងតាត់ ទុកជាសម្បត្តិសម្បូណ៌បាន ទោះបីក្រក្សត់អត់ ប៉ុន្មាន គង់តែបាបានគ្រាន់អាស្រ័យ ៗ សម្បត្តិនៅស្ថាននាលោកិយ មាសប្រាក់ប្រក្រតីនៅសព្វថ្ងៃ សឹងតែប្រកបទៅដោយភ័យ បាត់បង្វៀត

នៃជាអនិច្ចំ ៗ រីឯសម្បត្តិគឺចំណេះ បើបានចេះដោយកំឡាំង ជាប់នឹងជាប់យាវជីវ សឹងទៀងចិត្តតាំងដល់ខ្លួនស្លាប់ ៗ ពុំដែលមានភ័យមកពាធា អាចធ្វើវិជ្ជាឲ្យអន់អ័ប្ប ទោះបីដល់ក្មេងប្រល័យកប្ប ក៏ពុំអាចឆាបឆេះអន្តរាយ ៗ ថាហៃអស់ពួកកុមារ ចូរបោះស្រាហ៍ខំខ្វល់ខ្វាយ សង្កេតកំណត់កុំឲ្យម៉ាយ តាមពាក្យបរិយាយយើងពណ៌នា ៗ រីឯវិជ្ជានាលោកិយ ប្រយោជន៍សិរីសួស្តីជា នឹងជួយឲ្យបានទ្រព្យនានា គ្រឿមគ្រាន់សុខាក្នុងលោកនេះ ៗ រីឯវិជ្ជាគឺព្រះត្រៃ- បិដកថ្លាថ្លៃកុំសន្ទិះ ប្រយោជន៍តាំងនៅក្នុងលោកនេះ ដរាបដល់ទិសទិព្វបរលោក ៗ ជាស្ពានជាប់លៀនរូបអាត្មា នាំអង្គរួចចាកទុក្ខសោក ទៅកាន់ខេមស្ថានសិវមោក្ខ និព្វានស្ថានលោកជាអវសាន ៗ

ឥឡូវបញ្ចប់ស្ទះចរចា អក្សរមាលាប៉ុណ្ណេះបាន និយាយអំពីក្មេងគ្រប់ប្រាណ ប្រដៅខ្លួនតទៅទៀត ៗ មនុស្សយើងត្រូវរៀនចំ- ណេះ ឲ្យបានចាំចេះមិនបង្អៀត បញ្ហាណាក្រយើងកែធ្វៀត ប្រៀតយកសេចក្ដីឲ្យឆ្ងាយស្លាប់ ៗ ត្រាជាអកុសលចូលមកសួរ អ្នកប្រាប់ឲ្យគួរតាមសណ្ដាប់ ធម៌អាថ៌ណាគ្រូបានថ្លែងប្រាប់ សារសើរតាមធម៌តាមហេតុ ៗ នឹងមានកិត្តិសព្ទសូរពីរោះ នឹងមានកេរ្តិ៍ឈ្មោះខ្ពស់ពន្លឺ នឹងមានប្រាជ្ញាពីលោកិយ នឹងមានសិរីសួស្តីប្រាណ ៗ យកចិត្តទុកដាក់នឹងចំណេះ អ្នកកុំប្រហែសធ្វេសគិតខាន ខូចវេលាមួយដូចខាតច្រើន

ចាំក្រវើនណាអ្នកណា ៗ នឹងបានក៏ច្បាស់សព្វសេចក្តី ក៏ដូចស្មើសែង
សុរិយា ក៏ច្បាស់ត្រចះនឹងនេត្រា ក៏ថាដូចចិត្តឥតសង្ស័យ ៗ តែបាន
រៀនច្រើនកើតបំណេះ តែបេះការច្រើនជាបច្ច័យ តែខំរៀនសូត្ររាល់
ខែថ្ងៃ ដូចឆ្នៃត្បូងពេជ្រលេចពន្លឺ ៗ បើមានបំណេះចេះវិជ្ជា បើឯងស្គាថា
ច្រើនគេត្រូវ បើមានការគេប់ក្លី បើមានជម្ងឺជួយភ័ក្តិ ៗ បើបានចេះ
ហើយនឹងមានឈ្មោះ សូរស័ព្ទពីរេះខ្ពស់ព្ទល្បី មានពាក្យសរសើរពី
លោកិយ ដល់បរលោកក្តីសុខក្សេមក្សាន្ត ៗ បើបារៀនសូត្រខំខ្មាត
ខ្នះខ្នែងសង្វាតកុំឲ្យខាន ឲ្យខាតវេលាវិជ្ជាប្រាណ ចិត្តត្រេកកំសាន្តតាម
ទំនើង ៗ កុំនិយាយគ្នាណាអាក៏ ឲ្យខាតវិជ្ជារបស់យើង បើគេនិយាយ
បាឆ្មើឆ្មើង កុំឥតបឡើងជាប់សំដី ៗ ដោះឡើងដើរចេញទៅរករៀន
បំណេះរបៀនតាមសេចក្តី ដែលត្រូវការរៀនវិជ្ជាអ្វី តែជាប់សំដីខាន
រៀនសូត្រ ៗ មួយទៀតកុំបារៀនចិត្តឈ្មោះ ប្រកែកទ្រគោះរៀនឲ្យស្ទួត
សំដីគេលើសបាកុំស្រែក រូតរះបង្ឈ្នះឥតអំពើ ៗ រវល់តែចិត្តគ្របាធ្យាយ
ដំនុំអភិប្រាយរកស្រើរ ឃើញទោសហើយផ្លាលតាមដំណើរ អ្នកណា
គេប្រើឲ្យឈ្មោះគ្នា ៗ ធម្មតាជាអ្នករៀនសិស្សសេក្ខ កុំរៀនកាចពេក
ណាអាក៏ គួរខ្លាចរំពាត់គួររាំងឹក ចិត្តកាចនោះណា គួរនឿយណាយ ៗ
មួយទៀតរឿងល្បែងលេងមិនសុខ ច្រើនតែមានទុក្ខបៀតបៀនកាយ
លោកថាលេងច្រើនៗ អន្តរាយ វិនាសខាតខ្លាយសម្បត្តិទ្រព្យ ៗ

អ្នកអើយធម្មតាកើតជាមនុស្ស ឲ្យដឹងគាប់ខុសទើបគាប់ កុំរៀនធ្វើ
ល្មើសលើសទំនងច្បាប់ ចូរស្ដាប់ពាក្យនេះចាំទុកទៅ ៗ គំនិតសេក្ខសិស្ស
អ្នកនៅវត្ត ប្រោសប្រាណប្រតិបត្តិឲ្យត្រឹមត្រូវ កោតខ្លាចលោកគ្រូជាង
ម៉ែឪ ចូលទៅប្រតិបត្តិកុំឲ្យអាក់ ៗ បារៈបៀកម្ពូស្លាម្លូវបារី ប្រគេនហើយ
ទំរៀបស្រក្យ វែចាំដាំទឹកក្ដៅត្រជាក់ ទុកដាក់របស់តាមរណ្ដាប់ ៗ
បើលោកៈហៅប្រើការអ្វីៗ រៀបរួសដៃជាប្រញាប់ យកចិត្តទុកដាក់ធ្វើ
ឲ្យឆាប់ លោកប្រាប់យើងធ្វើតាមព្រះវិន័យ ៗ ផ្គាប់គ្រូមិនសូវមានគ្រោះ
ខ្លួន បើផ្គាប់ឲ្យមួនកុំសង្ស័យ ខុសពីបើជងលោកអភ័យ សំដៃចំណី
ទុកឲ្យស៊ី ៗ

១ ឥឡូវបញ្ចប់រឿងនាគ ទំនងលើកស្រុះទុកតសេចក្ដី ពីត្រឹមណោះ
ទៅលើករឿងថ្មី ខ្ទនាទប្រុសស្រីគ្រប់ពល់ខ្លួន ៗ ទំនងថ្ងៃងពីរូបយើង
ពល់គ្នា កើតក្នុងសាសនាគិតឲ្យមួន បើមិនប្រយ័ត្នខ្លាចក្រែងខ្លួន ណោះ
សូន្យមិនកើតឥតអំពើ ៗ បំណាច់កើតមានក្នុងសាសនា គួរគិតប្រាថ្នាកុំ
ពន្យើ យកចិត្តទុកដាក់ធ្វើលើ ក្រែងឥតអំពើបង់រូបកាយ ៗ ខំស្វែង
រករៀនធម៌បរមត្ថ ប្រឹងចិត្តប្រយ័ត្នគិតឲ្យឆ្ងាយ ជីវិតយើងនេះទំនងអន្ដរាយ
សុទ្ធសឹងតែស្រាយឥតខ្លឹមសារ ៗ ឥតមានអ្នកយកជាទីពឹង ពិតជា
ពុំដឹងស្លាប់ថ្ងៃណា ហេតុដូច្នេះរូបនេះអនិច្ចា ជាអនត្តាពុំឃៀងឃ្លាត ៗ
ហេតុដូច្នោះឯងប្រុសប្រុសស្រី កើតក្នុងលោកិយគួរខ្ជាហ្លួត រក្សាសីលទាន

ខំសង្វាត បិត្តកុំប្រមាទដូចពណ៌នា ៗ មានមកក្នុងច្បាប់នេះស្រាប់ហើយ
មិនមានខុសឡើយរៀងរាល់ឃ្លា សំគាល់ចាំទុកទៅមុខជា គ្រឿងការពារ
ការសត្រូវ ៗ អ្នកខំសំគាល់ធម៌សុខុម ធ្វើជាអារម្មណ៍ចាំទុកទៅ ពល
រូបមុខជាមិនលែងត្រូវ ការស្លាប់នោះនៅកាលរូបពិត ៗ អ្នកអើយអ្នក
ខំត្រិតត្រៀងផ្ចាត់ កុំថាតែមាត់ស្រេចនូវចិត្ត សព្វថ្ងៃចិត្តយើងគួរពិនិត្យ
ផ្សិតចិត្តបុណ្យបាបប្រទាំគ្នា ៗ ចិត្តណាខិលខូចបណ្តេញចេញ កុំឲ្យរា
ខាញក្នុងរូបា រាំនាំឲ្យទុក្ខរូបវេទនា កើតទុក្ខកាលណារារតែចោល ៗ
រូបយើងសព្វថ្ងៃចិត្តធំណាស់ ធំជាងបង្អួសជាបង្គោល អាខ្លះជាភ្លើងតែង
ដុតពេល អាខ្លះជាលដោលឲ្យវង្វេង ៗ អាខ្លះរាំធ្វើឲ្យទុញថប់ បុណ្យ
សីលទានស្អប់គ្នានកោតក្រែង ខ្លះនាំបង្ហាញប្តូកខ្លួនឯង ឲ្យទុញវង្វេង
នឹងកាមគុណ ៗ ខ្លះរាំនាំល្មួចប្រពន្ធគេ អាខ្លះបង្វើរឲ្យល្មួចប្លន់ អាខ្លះកាប់
ចាក់មិនគិតគន់ អាខ្លះលោភលន់បោកប្រាស់គេ ៗ ហៃអស់មហាជនទាំង-
ឡាយអើយ បើដូច្នេះហើយចូរអ្នកគ្រេ អ្នកទុករក្សាមិនបានទេ ល្មមអ្នករាយ
ដេរបណ្តេញចេញ ៗ រាំនៅរាំនាំបង្ហាញរូប អ្នកអើយកុំខុបកុំស្រឡាញ់
ទាត់ចោលឲ្យឆ្ងាយពីខ្លួនចេញ តែអ្នកស្រឡាញ់ខូចខ្លួនហើយ ៗ ដែល
នាំខ្លួនខូចពីព្រោះខឹង អន្តរាយមិនដឹងខ្លួនសោះឡើយ នាំទាញលិច
លង់មិនដឹងត្រើយ អ្នកអើយអ្នកគិតកុំឲ្យខាន ៗ អ្នកគិតតែល្អគ្រប់
ត្រឹមត្រង់ ល្មមអ្នករំពឹងលើខ្លួនបាន ទៅណាយកទៅជាប់នឹងប្រាណ

ទើបបានគេស្រមកក្សាន្តរួចគ្រោះថ្នាក់ ៗ តាមបន្ទូលព្រះអង្គទ្រង់ឲ្យ ទើបបាន
ទៅសោយសួគ៌ជៀងជាក់ កោតខ្លាចគោរពពុំឡើយអាក់ កុំឲ្យមានថ្នាក់ការ
ថ្វល់ឡោយ ៗ បើដាច់ធម៌សីលទានទៅក៏ គ្រាន់បានជាគ្នាឃើតយោងជួយ
កប់អានស្រឡាញ់ដូចខ្លួនមួយ សីលទានជាត្រួយស្មើជីវិត ៗ ឲ្យអ្នកការ-
នាតែសព្វថ្ងៃ អកុសលចង្រៃគ្មានហ៊ានជិត បាក់បបខ្ទបខ្លាចអំណាចពិត
ដោយគុណសុចរិតខ្លាត់ទៅឯង ៗ អ្នកកុំស្អប់ទើបសីលសិក្ខា លោកសង្ឃ
កាចារ្យត្រូវកោតក្រែង ដូចកែវកំណើតកុំចំខែង លោកតែងដុសលាង
រូបខ្លួនឡា ៗ ព្រះធម៌ថ្ងៃថ្ងាគ្មានស្អប់សត្វ អ្នកកុំលះកាត់ដោយមោហោ
ព្រះធម៌នាំសត្វឋានសុខោ កុំគិតការលោភខ្លាចស្លាប់ ៗ តែផុតវេលា
ទៅកាលណា ទៅតាមវេរបុណ្យបាបធាប់ ធ្វើអ្វីបាននោះតាមចិត្តគាប់
ប្រាប់យមបាលធ្វើតាមកម្ម ៗ ត្រូវដុតត្រូវស្ងោរត្រូវស្ងួតថ្ពក់ ត្រូវ
ដោលត្រូវក្រគាប់ចង្រ្កាំ ត្រូវឡើងរកាដែកតាមកម្ម តាមហេតុដែល
ចាំមានសាក្សី ៗ ទោសខ្លះត្រូវបុកអង្រែដែក ល្អិតល្អោចខ្ទិចបែក
ដូចសំឡី ស្លាប់ហើយរស់វិញតែពល់ថ្ងៃ រងភ័យនរកវេទនាណាស់ ៗ
ស្រែកយំលោខ្ទោចខ្ទោចឈឺផ្សា ពីព្រោះអាត្មាធ្វើកម្មក្រាស់ ប្រកាច់ដី
ផើធ្វើទីសទាស ផ្ទេសផ្ដាសរកអ្វីទីពឹងគ្មាន ៗ យំខ្លួនញ្ញស្រែកហៅប្រពន្ធកូន
កូនទៅប្រុសស្រីតាមមួយគ្នា ហ៊ុតខ្ទះដែកឈាមដោយសារយ៉ាន មិន
មានអ្វីស៊ីលំបាកណាស់ ៗ ចាំស្រែកអង្វរយមបាល ថាខ្ញុំកងបាលហើយ

លោកម្ចាស់ គេតែតែចងចងភេទះ ថាពះអាហោរខូចអប្រិយ ៗ មិន ឯងលួចប្លន់កាប់ចាក់គេ មិនមានទំនេរតែកល់ថ្ងៃ ប្រពន្ធគេឯងគាប់ចៃ លួចមិនប្រណី ព្រោះចិត្តធំ ៗ ប្រមាថមែឪគ្រូអាចារ្យ ផញ្ជីងធូន់ស្រាល ជុំងបន្ទុំ ដេញចាញ់ម្រឹគបក្សីតូចធំ មិនមេត្តាពុំប្រណីឡើយ ៗ ផឹក ស្រាស្រវឹងស្រែកហាមក្អក ចិត្តត្រអាលត្រេកមិនមានសង្ស័យ គ្មានគិតធ្វើ បុណ្យសីលទាន ឡើយ រៀនធម៌ឲ្យហើយទៅតាមស្ថាន ៗ រីយមបាលទាំង បួនទាក់ តែងតែទាត់ធាក់ប្រាសប៉ំប្រាន កាន់លំពែងចាក់សួសសព្វ ប្រាណ អ្នកខ្លះសោតបានទំកទង់ដែង ៗ យកមកចាក់ស្រែចហុចឲ្យទៅ ហើយកាន់ពូថៅឈរកំហែង ថាហ៎ះនេះស្រារបស់ឯង ដែលអាធ្លាប់តែង ផឹកពីមុន ៗ អញបំទយ៉ាងល្អទុកសម្រាំង កក្កុលស្រាយ៉ាងខ្លាំងពីសាសុន ផឹកទៅអាភ៌ពបាតគ្រន មិនបាច់គេគ្រានគិតថ្ងៃថ្នូរ ៗ អញឲ្យអានាងឯង ផឹកចុះ ដោយចិត្តអញសោះមិនលក់ដូរ ឲ្យផឹកទទេគ្មានថ្ងៃថ្នូរ ដ្បិតធ្លាប់ ផឹកហូរពីដើមមក ៗ រីឯអស់ពួកសត្វនរក ភ័យភិតជាទុក្ខតេ៍ពួនជ្រក យមបាលគម្រាមដេញសង្រុក ដេរស្រែកគំហកកំហែងចាប់ ៗ បាន ហើយបំផឹកទឹកទង់ដែង គិតទៅគួរស្បូវ ភ្លើងឆេះឆាប រលាករលួយ រលាយស្លាប់ ប្រែប្រាណក្រឡាប់រស់ឡើងវិញ ៗ អាហារនៅក្នុងស្ថាន នរក នោះមានតែលាមកខ្ទុះឈាមមិញ ហើយក្រេងបានស៊ីឲ្យពេញ ពោះកើតទុក្ខមេញទិង់ភ្លើងក្តៅ ។ ឯណាស្រែកទំកស្ងួតខះក ឃើញ

ទឹកថ្លាល្អរត់សំដៅ ស៊ើរស៊ុះស៊ើរលោតរត់លឿនស្ទៅ លុះបានដល់
ទៅត្បូងទឹកឡើង ៗ ពុំទាន់ទឹងបានដល់ក្នុងពោះ រីឯទឹកនោះក្លាយ
ជាភ្លើង ឆាបឆេះជាបេកលដល់ចុងជើង ស្ទុះរត់ក្រញៀងក្រកសស្គុះ ៗ
ភ្លើងឆេះឡោតពេលល្វេយសាច់ របូតអស់អាចម៍ពីក្នុងពោះ ស្លាប់ហើយ
បណ្តាលឡើងជារស់ ចំពោះមួយថ្ងៃមួយរយដង ៗ តែងតែទឹងស្លាប់
ក្រឡាប់កើត រាប់ជាតិកំណើតច្រើនកន្ទង វេទនាវង់ទុក្ខវង់ទោសផង
ស្រែកយំរំពងរងកម្មក្រាស់ ៗ សំដែងអំពីសត្វនរក ទឹងលើកស្ទុះ
ទុកឲ្យលោកលះ ដ្បិតនៅមានច្រើនប្រការណាស់ ក្រឡាស់ថ្លែងពីលោ-
កិយវិញ ៗ លោកិយនេះត្រូវតែខំរៀន បំណោះរបៀនខំទន្ទេញ ធម៌
យាមត្រួតត្រាប្រែចេញ ជាពាក្យខ្មែរវិញតាមតិចច្រើន ៗ មួយម៉ាត់ពីរម៉ាត់
ខំខ្សឹបក្រហ៍ តាំងចិត្តការទាទឹងចម្រើន ផលាទិសង្ឃទឹងបានកើន បើ
មិនក្រវើនឥតអំពើ ៗ បេះតិចបេះច្រើនឲ្យជាក់ច្បាស់ កុំស្ងួតផ្តេស
ផ្តាសថាពញ្ញើ បន្ទុបន្ទំដូចមម៉ើ ងើងើផ្តេសផ្តាសមិនច្បាស់ត្លួ ៗ ងឿង
ឆ្ងល់ត្រង់ណាចូរប្រតិបត្តិ លោកណាចេះស្ទាត់ឲ្យស៊ើបសួរ ពិនិត្យសង្កេត
រៀងពល់ត្លួ ចាំទុកទៅគួរទើងមានអាង ៗ សេចក្តីស្លាប់មានតែពលគ្នា
គួរកេងគួរកេគួរទំសាង កំណាត់មានឈ្មោះនៅក្នុងក្រាង ចាប់បានកើចឆាំង
ពមិនលែង ៗ ជាអ្នកកន្រ្ទឹសការអាក្រក់ ចូលចាប់កាប់ឆក់តតគោតក្រែង
សិពេះបង់ដៃគ្មានយល់ឯង ចាប់បានមិនលែងឲ្យរួចទេ ៗ ទុកជាមាស

ប្រាក់ទាំងប៉ុន្មាន គេមិនទុកប្រាណនៅទំនេរ ចោលកូនចោលចៅចោល ឪម៉ែ ចោលកេរ្តិ៍ចោលស្រែទ្រព្យរបស់ ៗ អង្វរថា ខ្ញុំធ្វើបុណ្យទាន ខ្ញុំស បញ្ជូនលោកឥតខ្មោះ សូមបង្អង់ឲ្យរៀបកូនអស់ គេគ្មានស្រណោះ ស្តាប់អ្នកទេ ៗ ជានុអ្នកផងទាំងឡាយអើយ មរណៈនេះហើយមិនទំនេរ មានពល់តែរូបមិនតែគេ យើងក៏មានដែរមិនរលង ៗ តាម ព្រះពុទ្ធដីកាឲ្យភាវនា រំឭកគាថាបីបទផង ឲ្យរឿយៗ ណាស់កុំរលង ទើបបានផលផងយ៉ាងឧក្រិដ្ឋ ៗ អដ្ឋវៈស្មរៈ ថ្ងៃនេះស្អែក បរមស្មរៈ ខានស្អែកពិត ឲ្យចំភាវនារំពឹងគិត ថាអញប្រាកដជានឹងស្លាប់ ៗ រំឭកឲ្យជាប់ពល់វេលា កុំឲ្យឃ្លាតឃ្លាមិនត្រង់ត្រាប់ ឲ្យលង់ចិត្តចុះទៅតាមច្បាប់ ទើបគាប់ដូចព្រះបន្ទូលថា ៗ សង្វេគបង្វឹកកុំឲ្យភ្លេច ឲ្យបានសម្រេចធម៌អនិច្ចា រំពឹងឲ្យច្បាស់ផ្គាល់ផ្ទួន ថាអញត្រូវការស្លាប់មិនលែង ៗ ភាវនាកុំភ្លេចពល់វេលា ឲ្យបាន់ពិស្តារៈច្រើនយូរវែង បង្ហឹកបង្ហាត់គំនិតឯង គួរស្បែងខ្លាចស្លាប់រូបវេទនា ៗ រតនត្រ័យទាំងបីបទ ឲ្យចាំរត់មាត់រៀនពល់ឃ្លា ថ្វាយបង្គំព្រះពល់ៈវេលា ជាគ្រឿងសស្ត្រាការសត្រូវ ៗ សំគាល់ធម៌ណាជាបរមត្ថ ប្រុងៈប្រៀបប្រយ័ត្នចាំទុកទៅ ពល់រូបមុខជាមិនលែងត្រូវ ការស្លាប់មានៈនៅរូបទាំងអស់ ៗ អាចារ្យឲ្យធម៌កម្មបាន ព្រលឹងវិញ្ញាណមិនពុះសោះ ស្លុតមាត់ច្រហក ក្រៀមផ្អោះ លុះតែគិតរួចសទើបស្លាប់បាន ៗ អហោគាំងចិត្តគិតឲ្យហើយ

អ្នកកុំបណ្ដោយឲ្យចាកស្ថាន សំណាងតិចៈច្រើនបានមិនបាន កុំខានចាំ
តែទីពឹងគេ ។ កុំអួតកុំអាងសំណាងខ្លួន ត្រែងជួនជាខុសទៅទទេ
វេទនាខ្លួនខ្វះសង្វេបជាគេ គិតគ្រឿងទៅឃើញលំបាកក្រៃ ។ មរណ-
ទុក្ខនេះលំបាកណាស់ លុះដល់ប្រទះទើបបានភ័យ មិនដឹងជាក្រឬជា
ងាយ បើងអ្នកនៅកាយមិនដឹងគេកៈ ។ ស្លាប់ទៅប៉ុន្មានបាត់សូន្យ
ឈឹង គ្មានត្បូងដំណាំងនៅតែឈ្មោះ ធ្វើបុណ្យតែរូបដូចគល់ឈស ដុតគារ
បញ្ចុះថាបានហើយ ។ ត្រង់ក្រត្រង់ងាយគ្មានដំណឹង មិនមានវិល
វិលមកប្រាប់ឡើយ ដុតគារបានទៅទុកព្រងើយ អ្នកអើយគេធ្វើតប
គុណទេ ។ បើកូនស្រុះស្រួលដោយចិត្តស្មោះ ធ្វើបុណ្យចំពោះទៅ
ឪម៉ែ តាមដោយសុចរិតបានខ្លះវែរ បើចិត្តវាប្រែមិនត្រង់ស្មោះ ។ អ្នក
កុំរំពឹងបានទៅដល់ វាគិតខ្វាយខ្វល់ទឹងរបស់ ចិត្តវាក៏ដឹងមិនត្រង់ស្មោះ
ធ្វើច្រើនក្រែងអស់ក្រខ្លួនវា ។ វារៀបដំណើរដាក់ទៅឲ្យ របស់ខ្សត់
ខ្សោយហើងខ្ជិល ប្រអប់ចានថ្នាំងកាំបិតព្រា ទ្រព្យណាឥតការវាដាក់
ជូន ។ ទំញត្តិលឬថាសប្រអប់ស្លាំង បង្ហុកូលដំកើងទុកបំរុង អាល័យ
សោកស្ដាយគិតដើមចុង ស្ទើរផុតប្រខ្ចូនសូមពោងង ។ អាល័យ
ខ្វាំងណាស់មួយខែថ្ងាយ ចែកទ្រព្យប្រញាយគ្រប់ប្អូនបង បានតិចបាន
ច្រើនកើតសៅហ្មង ប្អូនបងពាស់គ្នាកើតក្ដីក្ដាំ ។ អ្នកអើយទំប្រឹងចិញ្ចឹម
កូន ប្រចិត្តប្រខ្វូនទឹងពៀរកម្ម មិនឲ្យអត់ឃ្លានប្រឹងទ្រទ្រាំ ដល់ខ្លួន

ប្រថមជាសំដក ១ រកកូនណាមួយគាស្លូគ្នាន ប្រដៅខ្លួនខ្នានមិនស្តាប់
ណា ប្រចូស្តអ៊ំស្រូសឈ្មោះធ្វើយថា បុស្សាផ្តុញផ្តាល់បង្អាច់វិញ ។
ស្រឡាញ់កូនស្មើរប្តូរជីវិត ចំអត់មិនហ៊ានរះបាបហាះចេញ ចំកក្ដែកស-
ស្រោកតុះពោរពេញ កូនទៅស្រឡាញ់មិនដូចចិត្ត ។ ម្ល៉ោះហើយ
ចិន្តាញ់ស្តីឲ្យវា ឥតមានកូនណាដូចគំនិត វាថាឯងចាស់មិនប្រព្រឹត្ត
ម្ល៉ោះហើយចំងចិត្តអាណិតខ្លួន ។ ទ្រព្យធនណាលួមិនធ្វើបុណ្យ ដ្គត់ផ្គង់
បម្រុងទុកឲ្យកូន បុណ្យទានមិនបានធ្វើមាំមួន ក្រែងកូនគ្មានសុំគ្មាន
ស្មៀកពាក់ ។ ទាល់តែស្លាប់ទៅវង់វេទនា ឥតមានកូនណាជួយធុរៈ
ទ្រព្យរបស់ចែកវាមានមាសប្រាក់ គិតចុះណាអ្នកកុំសង្ស័យ ។ ស្លាប់
ទៅរំពឹងកូនធ្វើបុណ្យ ពិតារណាចុះជនទាំងប្រុសស្រី តែមិនប្រយ័ត្ន
ទៅអវិចី ធ្វើអ្វីធ្វើទៅតាន់ខ្លួនរស់ ។ រៀនធម៌ប្រតិបត្តិតាមសម្មា ព្រះ
អង្គទេសនាមិនដែលខុស រៀនសូត្រភាវនាទាន់ខ្លួនរស់ គួរគិតពិគ្រោះ
ទំងអ្នកប្រាជ្ញ ។ គេធ្វើបុណ្យឲ្យមិនទៀងណា ស្រេចនូវអាត្មាក្រែង
កោតខ្លាច កាន់សីលភាវនាពល់ព្រឹកល្ងាច នោះអាចប្រាកដទៀងជា
បាន ។ ដល់វេលាស្លាប់លះលែងជាតិ អះឡាលឃ្លាឃ្លាតមនុស្សលោក
ឋាន គេជះភាវនាធម៌សីលទាន នាំប្រាណហោះវង្វេងទៅតុសិត ។
ស្ថានរនោះមែនមានប្រាង្គណ៍ប្រាសាទ ប្រសើរក្អាង់ស្អាតអស់ពីចិត្ត
សម្បត្តិទ្រព្យហូរចូលលែងគិត រាប់ពុំអស់ឥតមានខ្វះអ្វី ។ មានហ្វូង

នាងស្រីទេពកញ្ញា នៅជាបរិវាររូបស្រស់ស្រី ពីរពាន់សម្រាប់ជាប្រក្រតី មានត្បូងត្រចៀកក្រៃស្រឡៃ ៗ ដេញដំប្រគំពិណប្រឡែងថ្វាយ ឮស័ព្ទសូរសាយពីរោះក្រៃ ពល់ពេលវេលាអចិន្ត្រៃយ សព្វថ្ងៃគាប់ចៃល្អចំឡែក ៗ អស់ពួកស្រីស្នំក្រមការគាល់ រាយរៀងរូបពល់យ៉ាងឯក ៗ ស្អាងខ្លួនពួល យាមតាមដោយឡែក ដោយពួកៈដោយប៉ែកចែកវេនគ្នា ៗ គ្មានអាក់គ្មានអៀនគ្មានអន់ចិត្ត គ្មានប្រណែនគិតនឹងនិន្ទា តាមតែសព្វព្រះហ-ឫទយា ទីងរូបអ្នកណាឥតមន្ទិល ៗ សំដែងបែបនេះយ៉ាងថោកទាប ប៉ែតាមសភាពអំណាចស៊ីល កាន់ខ្ជាប់ទំនៀនសូត្រកុំខ្ជិល រំកិលជាតិកើនលឿនទៅមុខ ៗ បានដល់អរិយមគ៌សឹងមាន សម្រេចនិព្វានស្ពានក្សេមសុខ ប្រាសចាកអំពីសេចក្តីទុក្ខ ប្រយោជន៍ទៅមុខព្រោះតែសីល ៗ ហេតុនេះគួរអ្នកខំសង្វាត ចិត្តកុំប្រមាទថ្ងួបជាទ្វៀ ខំរៀនសព្វថ្ងៃកុំគិតខ្ជិល ទើបបានរំកិលជឿនជាតិទៅ ៗ តាំងចិត្តធ្វើឲ្យបរិសុទ្ធ ឲ្យទៀងហ្មត់ចត់ត្រង់ត្រឹមត្រូវ ប្រព្រឹត្តដើរតាមគន្លងផ្លូវ អរិយមគ្គត្រូវទើបបានខ្លះ ៗ អ្នកឯងកុំខឹកថាខ្លួននៅ ក្មេងទេឥឡូវមិនទាន់ចាស់ ឈប់ចាំបន្តង់ឲ្យចំ-ណាស់ សិនសឹមគិតប្រាសគេរៀនធម៌ ៗ កុំគិតក្នុងចិត្តស្រវឹងថា ខ្លួនអ្នកឯងណាទៅរូបល្អ ក្នុងក្តាងក្នុងចិត្តគិតស្មោះសរ ត្រូវអរទើបរូបឥតកេតចាប់ ៗ ហើយអ្នកកុំអាលគិតថាខ្លួន ចំណាប់យ៉ាំមួយមិនទាន់ស្លាប់ បន្តិចទៀតស័នសឹមរៀនច្បាប់ ធ្វើតាមសណ្តាប់គ្រូអាចារ្យ ៗ គិតគំនិត

នោះខុសមិនស្អាត ចាត់ជាប្រមាទក្នុងសង្ខារ សំដីយ៉ាងហ្នឹងមិនគួរថា កុំអ្នកបរោចាត់ចោលចេញ ៗ ផ្លូវស្លាប់សព្វថ្ងៃទៅហូរហែ មិនគិត កាញ់គ្នេរៀនទន្ទេញ បង្ការប្រយ័ត្នខ្លួននោះមិញ ទៅវិញពន្លឺផ្លូវឲ្យ យល់ ៗ ពេលធ្ងន់ថយចេញអស់វិញ្ញាណ រូបប្រាណចង្គ្រានដូចខុស គល់ កំពុងនៅពាលគ្មានគិតយល់ ធ្លាក់ដល់ផកមរណក្ស័យ ៗ ទើប បានគិតឃើញភ័យរកផ្លូវ រកម៉ែរកឪព្រះគុណថ្លៃ គ្មានធម៌សូត្រអុជធូប សព្វថ្ងៃ ទៀបក្ស័យដឹងខ្លួនជាតុកឡុង ៗ លុះដល់ពេកមកបៀតបៀន កាយ ឈឺចុកសៀតសាយជាប់ដល់ចុង អាហារបាយទឹកទោះផ្ទុកហុង ដាក់ចុះក្នុងមាត់លេបមិនបាន ៗ ដឹងខ្លួនជាក់ច្បាស់ជាន់ដឹងក្ស័យ ភិតភ័យ ពេកក្រៃពន់ប្រមាណ ប្រមើលមើលរូបកាយខ្លួនប្រាណ រំងាររំខានចិត្តជា ទុក្ខ ៗ ស្តាយកូនស្តាយចៅស្តាយប្រពន្ធ ស្តាយអស់ទ្រព្យធនរែងរក ទ្រង់ត្រូតស្ងួតស្ងប់សញ្ជប់មុខ ពេកក្រៃរឹងរិតទុកការតែខ្លាំង ៗ លុះដល់ទៀប ហៀបផុតទីងក្ស័យ ភិតភ័យពេកក្រៃស្ទួនស្ទុតស្ទាំង ស្មារតីភ្លេចភ្លើដល់ កំឡាំង ទើបរករៀបក្រាំងសូត្រការវតា ៗ ប្រាថ្នាបង់ឲ្យរដោះកម្ម តែ គ្មានបានចាំបទត្រង់ណា រវល់តែនឹងឈឺខ្លោចផ្សា ក្នុងអង្គកាយាពន់ប្រ-មាណ ៗ ធម៌រៀនចេះហើយគ្មានរក្សា ដល់ភ័យប្រាករកធម៌គ្មាន មិន រក្សាទុកបម្រុងប្រាណ មិនចេះពប់កានចោលបង់ចោះ ៗ ប្រៀបដូចបង ប្អូនស្រឡាញ់គ្នា យូរទៅឃ្លាតឃ្លាមិនរាប់សោះ មិនដែលហៅរកចំចេញ

ឈ្មោះ ពីព្រោះចិត្តលោភដូច្នេះឯង ៗ ដល់ក័យហៅគេបងប្អូនជួយ ប្អូន បែរមុខក្រោយមិនគិតក្រែង កាលណាគេទឹងស្រែណោះឯង ក្រែងតែ មានព្រេងបុណ្យកុសល ៗ អំពីអតីតសាងមកច្រើន ជួយថែគ្រវើននោះ មិនថា គ្មានគិតសន្សំមគ្គផល បង្ការប្រយ័ត្នដល់ខ្លួនស្លាប់ ៗ អ្នក ស្លាប់ទៅមុននោះច្រើនណាស់ មិនដែលប្រទះវិលមកប្រាប់ ដំណើរ ដែលទៅឲ្យយើងស្តាប់ សារសព្វឲ្យដឹងបែបយ៉ាងណា ៗ តែស្លាប់ទៅ បាត់ព្រងំឈឹង មិនដែលវិលវិញមកប្រាប់ថា ទៅបានសុខទុក្ខយ៉ាងម្តេច ម្តា ឲ្យយើងកល់គ្នាបានដឹងផង ៗ

ក្រែងខ្ញុំលើកលោះខុសសេចក្តី មិនគួរគេរៀបបែបទំនង ខុសពាក្យ កុំបតិនមិនប៉ុនយោង ខុសបែបគន្លងផ្លូវធម៌គាថា ៗ ផ្ទៀតទៀបទីងរៀបរៀង លើកម្តង សេចក្តីច្រើនគ្រង់គ្រប់ប្រការ លោកណាបេះគាថសូមមេត្តា ផ្ទៀងភាសាឲ្យពានផង ៗ ឥឡូវបញ្ចប់ចប់សេចក្តី លម្មគួរគេប្បស្តាប់ ហើយហោង អស់តាំងសុទ្ធានគួរចាំចង សូមរេចម៉េះផងចប់ឯរំ ៗ ៙—

ចប់ច្បាប់ក្រិត្យក្រម តែប៉ុណ្ណេះ ៗ

# ប្រវត្តិពួកឧបាសិកា

## ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់

### ៥ នាងឧត្តរា — នន្ទមាតា

ជាអ្នកក្រុងរាជគ្រឹះ បិតារបស់នាងឈ្មោះបុណ្ណៈ ដែលជាខ្ញុំនៅក្នុងផ្ទះរបស់សុមនសេដ្ឋី ។ ថ្ងៃមួយនោះជាថ្ងៃមហោស្រព សុមនសេដ្ឋីមិនព្រមឲ្យនាយបុណ្ណៈឈប់លេងមហោស្រពទេ បង្គាប់ឲ្យកាន់នង្គ័លរនាស់ទៅភ្ជួរស្រែ ចួនជាថ្ងៃនោះព្រះសារីបុត្រលោកចេញអំពីនិរោធសមាបត្តិ ឃើញឧបនិស្ស័យរបស់នាយបុណ្ណៈទើបលោកនិមន្តទៅជិតកន្លែងភ្ជួរស្រែនោះ នាយបុណ្ណៈគ្រាន់តែក្រឡេកឃើញព្រះថេរៈក៏កើតបីតិត្រេកអរ ទើបយកឈើស្ទន់សម្រាប់ជម្រះធ្មេញ និងទឹកទៅប្រគេនលោក ហើយរំពឹងគិតតែក្នុងចិត្តថា កាលពីថ្ងៃមុនៗមក អញមកស្រែមិនដែលបានជួបប្រទះនឹងលោកម្ចាស់សោះ ទើបតែបានប្រទះក្នុងថ្ងៃនេះប្រហែលជាភ័ព្វសំណាងរបស់អញ ប្រសិនបើភរិយាយកបាយមកឲ្យអញហើយ បានជួបនឹងលោកនៅពាក់កណ្ដាលផ្លូវ ចូរប្រគេនបាយនោះទៅលោកចុះ អញមុខជាបានផលបុណ្យជាច្រើនពុំខាន ។

គ្រានោះ ភរិយារបស់នាយបុណ្ណៈ កំពុងនាំបាយមកឲ្យប្ដីស្រាប់តែបានជួបនឹងព្រះថេរៈនៅពាក់កណ្ដាលផ្លូវ ទើបប្រគេនបាយនោះដល់ព្រះថេរៈដោយចិត្តសទ្ធាជ្រះថ្លា សមតាមគំនិតស្វាមីរបស់នាង ។ លុះនាងបាន

ប្រគេនចង្ហាន់ព្រះថេរៈហើយ ក៏វិលត្រឡប់ទៅផ្ទះចាត់ចែងដាំបាយជាថ្មី ហើយនាំយកទៅឲ្យស្វាមីទៀត បាននិយាយរឿងធ្វើទាននោះប្រាប់ស្វាមីសព្វគ្រប់ ឯនាយបុណ្ណៈក៏និយាយប្រាប់អំពីគំនិត គិតគូររបស់ខ្លួនឲ្យភរិយាស្ដាប់ដែរ ស្វាមីភរិយាទាំងពីរក៏មានចិត្តសោមនស្សស្មើគ្នាទាំងពីរនាក់ ។

នាយបុណ្ណៈបរិភោគអាហាររួចហើយ ក៏ដេកលក់ទៅមួយស្របក់ ក្រោកឡើងឃើញមានពណ៌លឿងពេញទាំងស្រែ ក៏ស្មានថាជាផ្លែល្ពៅ តែការពិតនោះជាដុំមាសមានទំហំប៉ុនផ្លែល្ពៅ កើតឡើងដោយអំណាចបុញ្ញសម្បទានៃខ្លួន ដែលបានបរិច្ចាគរួមគ្នាក្នុងថ្ងៃនោះ ទើបនាំសេចក្ដីនោះក្រាបបង្គំទូលដល់ព្រះរាជា ព្រះរាជាទ្រង់ប្រោសឲ្យគេចាត់នាំយកមាសនោះមកហើយ ទ្រង់តាំងជាសេដ្ឋី ជាអ្នកមានស្ដុកស្ដម្ភបំផុតក្នុងស្រុកនោះ ។

លោកបុណ្ណសេដ្ឋី បានក្រាបបង្គំទូលអារាធនាព្រះពុទ្ធជាម្ចាស់ព្រមទាំងព្រះភិក្ខុសង្ឃទៅទទួលចង្ហាន់នៅផ្ទះរបស់ខ្លួន ហើយលោកសេ-ដ្ឋីអង្គាសដោយភោជនាហារយ៉ាងផ្ចិតផ្ចង់ជាវេលា ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ បានស្ដាប់ភត្តានុមោទនា ហើយបានសម្រេចសោតាបត្តិផល ទាំងប្ដីទាំងប្រពន្ធនិងធីតាផង ។

ឯធីតារបស់លោកបុណ្ណសេដ្ឋីនោះឈ្មោះនាងឧត្តរា ជាស្ត្រីមានសទ្ធាជ្រះថ្លាយ៉ាងខ្ជាប់ខ្ជួនក្នុងព្រះពុទ្ធសាសនា កាលបានចំរើនវ័យពេញ

ក្រមុំហើយ ទើបពជគហសេដ្ឋីជាចៅហ្វាយតាសរបស់បុណ្ណសេដ្ឋីកាលបានដំណឹងថា បុត្ររបស់បុណ្ណសេដ្ឋីពេញក្រមុំហើយ ទើបចាត់ឲ្យមនុស្សទៅដណ្តឹង ឲ្យកូនប្រុសរបស់ខ្លួន ៗ ដំបូងបុណ្ណសេដ្ឋីមានសេចក្តីរង្កៀសមិនព្រមឲ្យ ព្រោះត្រកូលពជគហសេដ្ឋី ជាមិច្ឆាទិដ្ឋិ នៅទីបំផុតបានព្រមព្រៀងគ្នាវិញ ដោយពជគហសេដ្ឋីឲ្យខសន្យាថា នឹងអនុញ្ញាតឲ្យកូនប្រសាស្រីនោះកាន់លទ្ធិសាសនា នឹងធ្វើបុណ្យទានផ្សេងៗតាមចិត្តបាន ទើបបុណ្ណសេដ្ឋីព្រមព្រៀងឲ្យរៀបមង្គលការផ្សំផ្គុំបុត្រីនឹងបុត្រពជគហសេដ្ឋីនោះ ៗ

នាងឧត្តរានៅរួមរួមជាមួយនឹងស្វាមី ដោយសេចក្តីសុខសប្បាយរហូតមក តែនាងចង់ដោះខ្លួនទៅរក្សាឧបោសថ ចំរើនកិច្ចតាមមុខក្រសួងរបស់ឧបាសិកា ទើបនាងទៅនិយាយជួលនាងសិរិមា ដែលជាស្រីពេស្យាមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងវេលានោះ ឲ្យមកនៅបំរើស្វាមីរបស់ខ្លួន ទើបនាងបានឱកាសទៅចំរើនធម្មបដិបត្តិនិងបំពេញកុសលក្នុងព្រះពុទ្ធសាសនា ៗ ចំណែកឯនាងសិរិមា កាលបានមកនៅបំរើស្វាមីនាងឧត្តរាជាយូរថ្ងៃទៅ ក៏ភ្លេចខ្លួនកើតសេចក្តីប្រចណ្ឌនឹងនាងឧត្តរា ទើបចូលទៅប្រទូស្តរាយនាងឧត្តរា ឯពួកទាសីស្រីបំរើរបស់នាងឧត្តរា បានឃើញដូច្នោះ ក៏នាំគ្នាស្ទុះមកជួយការពារចៅហ្វាយរបស់ខ្លួន ហើយប្រែងនឹងប្រទូស្តតបទៅវិញ តែនាងឧត្តរាបានហាមឃាត់កុំឲ្យធ្វើ ៗ សេចក្តី

ប្រព្រឹត្តិល្អរបស់នាងខុជ្ជុត្តរាធ្វើឲ្យនាងសាមាវតីនិងខ្លួនថា ជាអ្នកធ្វើខុសហើយ សុំខមាទោស នាងខុជ្ជុត្តរាក៏ទទួលអត់ទោសឲ្យនៅចំពោះព្រះភក្រ្តព្រះបរមសាស្តា ។ អាស្រ័យហេតុដែលនាងខុជ្ជុត្តរាជាអ្នកស្ដាប់ដ៏ជំនាញក្នុងការចំរើនឈាន ទើបព្រះបរមសាស្តាទ្រង់តាំងក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងជាងពួកឧបាសិកាដែលចំរើនឈាន ។

ចប់ប្រវត្តិសង្ខេបរបស់នាងខុជ្ជុត្តរាឧបាសិកា តែប៉ុណ្ណេះ ។

## ៦ សុប្បវាសា–កោលិយធីតា

កើតក្នុងខត្តិយត្រកូល ក្នុងកោលិយនគរ មានព្រះនាមថា សុប្បវាសា កាលទ្រង់ព្រះចំរើនវ័យ បានអភិសេកសមរសនឹងសក្យកុមារ ១ អង្គ សម័យមួយបានស្ដាប់ព្រះធម្មទេសនា របស់ព្រះបរមសាស្តា បានសម្រេចសោតាបត្តិផល តមកប្រសូតព្រះឱរស ១ អង្គ ទ្រង់តាំងនាមថា សីវលី (ដូចមានរឿងពិស្តារក្នុងប្រវត្តិព្រះសីវលិត្ថេរ ក្នុងអនុពុទ្ធប្រវត្តិ ៨០ អង្គ) ។

សម័យមួយព្រះនាងសុប្បវាសា បាននិមន្តព្រះភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រមុខឲ្យមកទទួលបង្ហាន់ក្នុងដំណាក់របស់ខ្លួនបានថ្វាយអាហារគោជនយ៉ាងផ្ចិតផ្ចង់ មានឱជារសដ៏លើសលុបមានចំនួនជាច្រើនមុខផង ។ កាលព្រះបរមសាស្តា ទ្រង់សោយស្រេចហើយ ទើបទ្រង់អនុមោទនា បានទ្រង់សំដែងធម៌ ដល់ព្រះនាងសុប្បវាសា មានសេចក្ដីថា ព្រះអរិយ-

សាវកទុកជាទាយកយ៉ាងឧត្តម តែងប្រគេនដោយគោរព ចាត់ជាវិធីដ៏ឧត្តម ភោជនមានឱជារសដ៏ឧត្តម បានថ្វាយដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រមុខ ទុកជាបដិគ្គាហកដ៏ឧត្តម រមែងបានទទួលផលដ៏ឧត្តម ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ ។

ដោយអាស្រ័យហេតុនេះ ទើបព្រះបរមសាស្តាទ្រង់តាំងព្រះនាងសុប្បវាសា-កោលិយធីតាក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងពួកឧបាសិកាដែលថ្វាយបង្អាន់ដ៏ផ្ចិតផ្ចង់ ។

ចប់ប្រវត្តិសង្ខេបរបស់ព្រះនាងសុប្បវាសា-កោលិយធីតា តែប៉ុណ្ណេះ ។

# រឿងព្រះបាទអសោក

(តមក)

រាជបុរោហិតក្រាបបង្គំទូលថា «បពិត្រព្រះសម្មតិទេព! សូមព្រះអង្គនាំព្រះរាជកុមារទាំងអស់ទៅកាន់រាជសួនសុវណ្ណឧទ្យានឯណោះ ខ្ញុំព្រះអង្គនឹងពិចារណាមើលនូវព្រះរាជកុមារទាំងអស់នោះ ក្នុងទីនោះ ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះរាជានុញ្ញាត ឲ្យនាំព្រះរាជកុមារទៅកាន់សួននោះហើយ ខណៈនោះ ព្រះរាជជននីបានត្រាស់នឹងអសោកកុមារថា «ម្នាលកូន ព្រះរាជាកំពុងទ្រង់ពិនិត្យមើលទំនាយព្រះរាជឱរសទាំងឡាយរបស់ព្រះអង្គនៅក្នុងសុវណ្ណឧទ្យាន ព្រះអង្គស្តេចយាងទៅមុនហើយ ចូរបាឯងទៅនឹងគេទៅ កូន» ។ អសោករាជកុមារតបថា «ស្តេចមិនទ្រង់ប្រោសប្រាណខ្ញុំទេ ព្រះអង្គនឹងមិនទតមកត្រង់ខ្ញុំឡើយ ទឹងទៅក្នុងទីនោះតើមានប្រយោជន៍អ្វី?» ។ ព្រះមាតាត្រាស់ថា «បើទុកជាយ៉ាងណាក៏ត្រូវតែឯងទៅ» ។ អសោករាជកុមារទូលថា «បើដូច្នោះ ខ្ញុំទៅហើយព្រះមាតាឲ្យគេយកអាហារទៅឲ្យខ្ញុំផង» ។

គ្រានោះ អសោករាជកុមារបានលាព្រះមាតាហើយ ស្តេចចេញចាកព្រះនគរបាដលិបុត្រ ទតឃើញរាធគុប្តកុមារជាបុត្រនៃសេនាបតីទី ១ នៅកណ្តាលផ្លូវ រាធគុប្តកុមារទូលសួរថា «ព្រះអង្គម្ចាស់ស្តេចយាងទៅណាហ្នឹង?» អសោករាជកុមារតបថា «ព្រះរាជបិតាទ្រង់ប្រជុំព្រះឱរស

ទាំងឡាយនៅវិសុវណ្ណឧទ្យាន ឥឡូវនេះខ្ញុំក៏ទៅក្នុងទីនោះដែរ" ។ កាលនោះរាធគុប្តកុមារជិះលើកុញ្ជរចាស់ជរាមួយ ក៏ក្រាបទូលអសោករាជកុមារថា "ពេលនេះ ខ្ញុំព្រះអង្គក៏ទៅក្នុងទីនោះដែរ សូមព្រះអង្គម្ចាស់ទ្រង់លើកុញ្ជរនេះជាមួយនឹងខ្ញុំទៅ" ព្រោះដូច្នោះ អសោករាជកុមារទ្រង់ឡើងគង់លើដំរីជាមួយនឹងរាធគុប្តកុមារ ស្ដេចយាងទៅកាន់ព្រះរាជឧទ្យាននោះ លុះដល់ហើយក៏ចុះចាកកុញ្ជរយាត្រាទៅដោយព្រះបាទាចូលទៅ ប្រថាប់លើផែនពសុធា នាទីជិតរាជកុមារទាំងឡាយ ។ ក៏ពួករាជកុមារទាំងនោះ នាំគ្នាសោយអាហារដ៏ឧត្ដមប្រសើរប្លែកៗ គ្រប់យ៉ាង ឯអសោកកុមារនោះ សោយបាយបាយាសលាយដោយទឹកដោះគោជាក់ក្នុងភាជនដីហើយនឹងទឹកសុទ្ធជាធម្មតា ។

គ្រានោះ ព្រះរាជាមានព្រះបន្ទូលនឹងបុរោហិតថា "លោកអាចារ្យ ខ្ញុំសូមឲ្យលោកពិចារណាមើលពិនិត្យពិច័យព្រះរាជកុមារឲ្យជាក់ច្បាស់ថា អ្នកណាអាចនឹងបានជាស្ដេចគ្រប់គ្រងរាជអាណាចក្រ ក្នុងកាលជាអំណោះតតអំពីខ្ញុំទៅ?" ។

រាជបុរោហិត ទើបពិចារណាមើលលក្ខណៈព្រះរាជកុមារទាំងឡាយ រំពឹងក្នុងចិត្តថា "ប្រាកដជាអសោកកុមារនេះឯង នឹងបានជាព្រះរាជា ប្រសិនបើអញក្រាបទូលថា អសោកកុមារនឹងបានជាស្ដេច ព្រះអង្គមិនសព្វព្រះរាជហឫទ័យចំពោះកុមារនោះសោះឡើយ ក៏នឹងអន្តរាយដល់

ជីវិតរបស់អាត្មាអញមិនខាន" លុះរិះគិតដូច្នោះហើយ បុរោហិតទើបក្រាបទូលព្រះរាជាថា "សូមទេជះ ខ្ញុំព្រះអង្គនឹងទាយដោយមិនចំពោះព្រះនាមព្រះកុមារអង្គណាមួយឡើយ ខ្ញុំទាយទៅតាមឫកពាថា "ដោតដួងជាតារាជកុមារឯណាដែលប្រើប្រាស់វត្ថុដ៏ឧត្តមប្រសើរជាងគេបំផុត រាជកុមារនោះនឹងបានជាស្តេច" ។

ព្រះរាជកុមារគ្រប់ព្រះអង្គ គិតស្មានតែក្នុងចិត្តរបស់ខ្លួនៗ មួយអង្គគិតថាអញមានពាហនៈប្រសើរ អញនឹងបានជាស្តេច, មួយអង្គគិតថា អញអង្គុយលើអាសនៈដ៏ប្រសើរ អញនឹងបានជាស្តេច, មួយអង្គគិតថា អញបរិភោគអាហារដ៏ប្រសើរ អញនឹងបានជាស្តេច, មួយអង្គគិតថា អញប្រើប្រាស់ភាជនៈដ៏ប្រសើរ អញនឹងបានជាស្តេច, មួយអង្គទៀតគិតថា អញផឹកទឹកដ៏ប្រសើរ អញនឹងបានជាស្តេច ។ ឯអសោករាជកុមារត្រិះរិះក្នុងចិត្តថា "អញនឹងត្រូវបានជាស្តេច ព្រោះកុញ្ជរជាពាហនៈដ៏ប្រសើរបំផុត ពសុធាជាអាសនៈដ៏ប្រសើរបំផុត បាយាសជាអាហារដ៏ប្រសើរបំផុត ភាជនៈដីជាវត្ថុដ៏ប្រសើរបំផុត ទឹកដោះគោជាព្រះស្ងោយដ៏ប្រសើរបំផុត ទឹកសុទ្ធជាបានៈដ៏ប្រសើរបំផុត ខ្លួនអញហ្នឹងឯងនឹងបានជាស្តេច ព្រោះត្រូវសមគ្រប់វត្ថុទាំងអស់នេះ" ។

រាជបុរោហិតក្រាបទូលទំនាយនេះស្រេចហើយ ព្រះរាជាក៏បញ្ជូនព្រះរាជកុមារទាំងអស់អង្គ ឲ្យស្តេចត្រឡប់មកព្រះនគរវិញ ។

រាជបុរោហិតបានចូលទៅគាល់ព្រះមាតារបស់អសោករាជកុមារហើយ ទូលព្រះនាងថា "ប្រាកដជាអសោកកុមារនឹងបានជាស្តេច" ។ ព្រះមាតាអសោករាជកុមារត្រាស់ថា "ចូរអ្នកបិទរឿងនេះឲ្យជិត កុំនិយាយប្រាប់អ្នកណាមួយសោះឡើយ បើមិនថ្ងៃណាក៏ថ្ងៃណាមួយ ព្រះករុ-ណាជាម្ចាស់ជីវិត នឹងត្រាស់ហៅអ្នកទៅសួរដំណើរនេះទៀតមិនខាន ហើយអ្នកនឹងត្រូវអន្តរាធានដល់ជីវិត ព្រោះដូច្នោះ ត្រូវអ្នកចេញចាករដ្ឋ-សីមាមណ្ឌលនេះទៅលាក់ខ្លួនពួនអាត្មានៅឲ្យឆ្ងាយផុតអាណាខេត្តរបស់ព្រះអង្គ ដើម្បីនឹងរក្សាជីវិតរបស់អ្នក បើបានឮដំណឹងថាអសោករាជកុមារបានរាជសម្បត្តិហើយ សូមអ្នកត្រឡប់មកវិញក្នុងពេលនោះចុះ ។

គ្រាខាងក្រោយមក នគរតក្កសិលា កើតបះបោរក្បត់កាប់សម្លាប់គ្នាជាចលាចលវឹកវរ ព្រះបាទពិន្ទុសារៈទើបទ្រង់ចាត់ឲ្យអសោករាជកុមារទៅបង្ក្រាបរៀបចំទីនោះ ទ្រង់ត្រាស់ថា "ម្នាលកូន ឯងចូរទៅរៀបចំនគរតក្កសិលា" តែព្រះរាជាទ្រង់ព្រះរាជទានចំពោះតែកងទ័ពព្រមដោយចតុ-រង្គនីសេនា មិនបានព្រះរាជទានគ្រឿងសស្ត្រាវុធនឹងរថសង្គ្រាមឡើយ ។

ខណៈដែលអសោករាជកុមារបានទទួលព្រះរាជឱង្ការហើយលើករេហ៍ពលចេញចាកនគរបាដលីបុត្រ គ្រានោះពួកពលដែលជាប់តាមព្រះអង្គទៅ បានទូល[illegible]ថា "ពួកយើងមិនមានសស្ត្រាវុធទេ យើងនឹងធ្វើចម្បាំងតយុទ្ធនឹងពួកខ្មាំងដូចម្តេចបាន ?" ។

អសោករាជឱរសមានព្រះបន្ទូលថា "ប្រសិនបើបុញ្ញានុភាពដែលបណ្ដាលឲ្យយើងខ្ញុំបានរាជសម្បត្តិមែន ខ្ញុំសូមឲ្យគ្រឿងសស្ត្រាវុធដែលយើងត្រូវការនោះកើតមានឡើងឯង ៗ ក្នុងកាលឥឡូវនេះ" ។ ត្រាស់មិនទាន់ផុតពីព្រះឱស្ឋ ក៏ពួកភុម្មទេវតាជ្រែកមហាប្រថពីស្ទុះស្ទាចេញមកនាំយកគ្រឿងសស្ត្រាវុធរាល់ដៃមកថ្វាយ ។

គ្រានោះ ព្រះរាជឱរសព្រមដោយចតុរង្គសេនា ស្ដេចយាត្រាចូលកាន់ក្រុងតក្កសិលាជាទីឡារ៉ក់ក្ខរស្សែង ពួកអ្នកនគរនោះ កាលបានឮដំណឹងថា អសោករាជកុមារយាងមកដល់ ក៏នាំគ្នារម្ងាប់អធិករណ៍នោះទៅឯង ត្រឡប់ជានាំគ្នារៀបចំតាក់តែងកំពែងបុរីស្អិតស្អាងដល់ប្រដាប់ទៅដោយគ្រឿងសម្ភារៈដ៏ស្អាតល្អ ហើយនាំគ្នាយកភាជនៈដ៏ពេញទៅដោយគ្រឿងបណ្ណាការនិងផ្កា ចេញមកទទួលព្រះរាជកុមារដើម្បីសំដែងសេចក្ដីចុះចូលនឹងព្រះអង្គ កាលទៅដល់ក្នុងទីចំពោះព្រះភក្ត្រចំនួនចម្ងាយកន្លះយោជន៍ ក៏នាំគ្នាស្រែកបន្លឺសំឡេងដ៏ស្រទន់ពីរោះក្រាបទូលថា "ពួកខ្ញុំព្រះអង្គនឹងបានគិតជាសត្រូវខ្មាំងតតាំងនឹងស្ដេចក៏ទេ ពួកខ្ញុំព្រះអង្គនឹងគិតតតាំងជាខ្មាំងនឹងព្រះរាជឱរសក៏ទេដែរ តែពួកខ្ញុំព្រះអង្គបះបោរតទល់នឹងអាមាត្យកំណាចឯណោះ" ថាហើយក៏នាំគ្នាហែហមចោមរោមអសោករាជកុមារ ថ្វាយគ្រឿងបណ្ណាការដោយសេចក្ដីគោរព ហើយស្ដេចយាងចូលទៅកាន់ក្រុងតក្កសិលាជាសុខសួស្ដី ដោយព្រះកិត្តិ-

យសយ៉ាងធំអស្ចារ្យ ។ អ្នកនគរទាំងនោះ ក៏ចុះចូលជារបៀបរៀបរយ សាន្តត្រានស្រួលបួលហើយ ទ្រង់ក៏ត្រឡប់ទៅក្នុងនគរព្រះអង្គវិញ ។

ព្រះបាទពិន្ទុសារៈ បានបញ្ជូនអសោករាជកុមារឲ្យទៅបង្ក្រាបនគរខសៈម្តងទៀត ពួកអ្នកនគរនោះ ក៏បាក់បបខ្លបខ្លាចព្រះបេស្តា ចុះចូលដោយអាការដូចគ្នានឹងលើកមុន ហើយទ្រង់ត្រឡប់ទៅក្នុងនគរព្រះអង្គវិញ ។ មានអ្នកចំបាប់ខ្លាំងពូកែពីរនាក់ ចូលមកសូមនៅអាស្រ័យបម្រើអសោករាជកុមារ ទ្រង់ប្រទានមុខការឲ្យត្រួតត្រារក្សាអាណាខេត្តរបស់ព្រះអង្គជាប់ដោយឡែក ។

ពេលនោះឯង ទេវតានឹងភូមិទេវតាទាំងឡាយដែលជាអ្នកគ្រប់គ្រងព្រះរាជដាននោះ បានប្រកាសសេចក្តីឲ្យឮប្រាកដដូច្នេះថាៈ

"ចូរអ្នកពលគ្នាកុំបះបោរឡើយ ព្រោះអសោករាជកុមារនឹងបានជាស្តេចចក្រពត្តិ ជាម្ចាស់នៃទ្វីបមួយ ក្នុងទ្វីបទាំងបួន មិនមានមនុស្សណាអាចហ៊ានតតាំងនឹងព្រះបេស្តាបាន ព្រះអង្គនឹងពង្រីកអាណាខេត្តឲ្យដល់ទីបំផុតនៃផ្ទៃប្រថពី ទៅទល់នឹងព្រំមហាសមុទ្រទាំងបួនឲ្យតាំងនៅក្រោមអំណាចព្រះអង្គ" ។

ថ្ងៃមួយ ព្រះរៀមនៃអសោករាជកុមារ ព្រះនាមសុសិមៈ ស្តេចត្រឡប់មក (អំពីការប្រពាតឧទ្យាន) ចូលទៅកាន់ក្រុងបាដលិបុត្រ ។

មានអគ្គមហាសេនាបតីម្នាក់ឈ្មោះខល្លាតកៈ[១] កំពុងដើរចេញទៅអំពីក្រុងទៅជួបនឹងសុសិមរាជកុមារនៅកណ្ដាលផ្លូវ សុសិមរាជកុមារឃើញក្បាលទំពែករលីងយ៉ាងដូច្នោះ ទ្រង់តាំងព្រះរាជហឫទ័យនឹងសើចកំសាន្តលេងសប្បាយ ក៏វាយក្បាលអគ្គមហាសេនាបតីនោះនឹងព្រះហស្ត សេនាបតីនោះឃើញដូច្នោះហើយគិតថា :

"ថ្ងៃនេះ ព្រះអង្គម្ចាស់មិនទាន់បានរាជាភិសេកនៅឡើយ ហ៊ានទះក្បាលយើងទៅហើយ ក៏កាលបើបានរាជាភិសេកហើយសមជាស្ដេចនឹងកាត់ក្បាលយើងដោយព្រះខ័នមិនខាន" ។ ចាប់ដើមតាំងតែពីត្រឹមនោះមក ក៏អគ្គមហាសេនាបតីនោះ នាំរឿងកំហុសអាក្រក់របស់សុសិមរាជកុមារមកនិយាយបរិហារប្រាប់ពួកសេនាបតីទាំង ៥០០ នាក់ថា "សុសិមរាជ-កុមារមិនសមគួរជាស្ដេចសោយរាជ្យទេ ហោរាចារ្យបានទាយថា អសោក-រាជកុមារនឹងបានជាស្ដេចចក្រពត្តិ ជាធម្មិករាជព្រះអង្គគ្រប់គ្រងលើទ្វីបមួយក្នុងទ្វីបទាំងបួន ពួកយើងទាំងអស់គ្នាត្រូវលើកព្រះអង្គនោះឲ្យបានរាជបល្ល័ង្ក" ។

ខណៈនោះ ពួកអ្នកស្រុកក្នុងនគរតក្កសិលា កើតក្បត់បះបោរឡើងទៀត ដោយតាំងនៅក្រោមបង្គាប់សេនាបតីកាចអាក្រក់ ក៏ព្រះរាជបិតាបញ្ជូនសុសិមរាជកុមារឲ្យទៅបង្ក្រាបស្រុកទៀតក្នុងនគរនោះតែមិនអាច

១ ខល្លាតកៈនេះ មានក្បាលទំពែករលីង ។

នឹងសម្លាប់ឲ្យរៀបរយទៅបាន ។ ព្រះបាទពិន្ទុសារៈទ្រង់ជ្រាបដូច្នោះ ក៏ព្រួយព្រះរាជហឫទ័យខ្លាំងទៅជាប្រឈួន ទ្រង់ត្រាស់បង្គាប់ដល់ពួកសេនាបតីឲ្យប្រគល់រាជសម្បត្តិរបស់ព្រះអង្គទៅសុសិមរាជឱរស ហើយឲ្យអសោករាជកុមារទៅសម្លាប់ពួកខ្មាំងនៅនគរតក្កសិលានោះទៀត។ តែពួកសេនាបតីទាំងនោះ មានសេចក្ដីពេញចិត្តនឹងអសោករាជកុមារ ក៏ប្រើកលឧបាយយកល័ខលឿងមកលាបស្រឡាបដងខ្លួនអសោករាជកុមារ ហើយលាយល័ខលឿងទុំដាក់ក្នុងភាជនៈដើម្បីសំដែងឲ្យឃើញប្រាកដគ្រប់គ្នា ទើបទៅក្រាបទូលបំភាន់ព្រះរាជាថា "អសោករាជឱរសប្រឈួនជាទម្ងន់ណាស់ ក្អួតឈាមចេញមកពីព្រះឱស្ឋស្រស់ៗ មិនសមនឹងទ្រង់ចាត់ឲ្យទៅទទួលការនោះទេ" ។

ពេលនោះ ព្រះបាទពិន្ទុសារៈប្រឈួនរឹងរឹតតែចំរើនខ្លាំងឡើង មានព្រះកាយពលថយណាស់ហើយ ព្រះអង្គយល់ច្បាស់ថា មិនទ្រង់គង់ព្រះជន្មនៅបានតទៅទៀតទេ ក៏ពួកសេនាបតីឃើញដូច្នោះ នាំគ្នាតាក់តែងអសោករាជកុមារ ដោយគ្រឿងរាជឥស្សរិយយសគ្រប់ប្រការ ហើយនាំស្ដេចទៅគាល់ព្រះរាជា ក្រាបទូលថា៖

"យើងខ្ញុំសូមឲ្យព្រះអង្គតាំងអសោករាជកុមារឲ្យទ្រង់គ្រងរាជបល្ល័ង្កបណ្ដោះអាសន្នមុនសិន កាលបើព្រះសុសិមកុមារនឹងត្រឡប់មកអំពីក្រុងតក្កសិលាហើយ យើងខ្ញុំនឹងប្រគល់រាជសម្បត្តិថ្វាយជាក្រោយ" ។

អសោកពោលទៅសេវកថា "បើកជបល្ល័ង្កនឹងបានជារបស់ខ្ញុំដោយពិតមែនហើយ សូមឲ្យទេវតាបំពាក់មកុដរាជ្យលើក្បាលខ្ញុំចុះ" ។ ពួកទេវតាបានឮពាក្យនោះក៏ធ្វើយតបមកព្រះអង្គវិញហើយ ទើបយកមកុដរាជ្យបំពាក់ព្រះសិរសាក្នុងខណៈនោះ ។ កាលឃើញសេចក្ដីអស្ចារ្យរបស់អសោករាជកុមារដូច្នោះ ព្រះរាជាក៏ទ្រង់ព្រះក្រោធពិរោធខ្លាំង បណ្ដាលឲ្យព្រះលោហិតស្រស់ៗ ពុះពោរហូរចេញមកតាមព្រះនាសិកព្រះអង្គ ហើយស្ដេចទ្រង់សោយទិវង្គតក្នុងពេលនោះទៅ (១) ។

លុះព្រះបាទអសោកបានរាជសម្បត្តិហើយ បានតាំងរាធគុប្តៈឲ្យធ្វើជាអគ្គមហាសេនាបតីទី ១ របស់ព្រះអង្គ (២) ។

ពួកយក្សបាននាំគ្រឿងពលិការរាជាភិសេកប្រកាសឡើងទៅលើប្រថពីបានមួយយោជន៍ ចំណែកនាគក៏ប្រកាសចុះទៅខាងក្រោមប្រថពីបានមួយយោជន៍ដូចគ្នា ហេតុការណ៍ទាំងនេះ បណ្ដាលឲ្យឮគ្រប់តំបន់ថា "ថ្ងៃនេះ រាជ្យនៃព្រះបាទពិន្ទុសារៈអស់ហើយ ព្រះបាទអសោកស្ដេចឡើងប្រថាប់លើបល្ល័ង្ករាជ្យហើយ" ។

---

១ សៀវភៅពុទ្ធសាសនារបស់លោកល្វី-ហ្វីណូត៍ ដែលលោកម៉ៅ ប៊ុជាខ្មែរថា កាលក្នុងរាជព្រះបាទពិន្ទុសារៈជាបិតានោះ អសោកនៅជាឧបរាជនៅស្រុកអវន្តី តាំងព្រះដំណាក់នៅឧជ្ជេនី អសោកបានយកធីតាសេដ្ឋី ១ នៅស្រុកវិទិសា សព្វថ្ងៃនេះហៅភិស្សាទាខ ជាព្រះជាយា ហើយបានព្រះរាជបុត្រ ១ ឈ្មោះមហេន្ទ្រ និងព្រះធីតា ១ ឈ្មោះសង្ឃមិត្រា ដែលទៅមុខទៅនឹងបានជាសាស្ដាចារ្យទៅក្នុងស្រុកសីឡង់ (កោះលង្កា) ។ ២ មហាវង្សៈបានតាំងព្រះតិស្សរាជកុមារដែលរួមឧទរជាមួយនឹងព្រះអង្គឲ្យជាព្រះឧបរាជ ។

ព្រះសុសិមរាជឱរសកាលទ្រង់ស្ដាប់ថា ព្រះបិតាទិវង្គតហើយ អសោករាជកុមារបានមុទ្ធាភិសេកហើយដូច្នោះ ក៏ពិរោធខ្លាំង ស្ដេចត្រ-ឡប់ចូលទៅកាន់នគរបាដលិបុត្រដោយប្រញាប់ប្រញាល់ ៗ ព្រះបាទអសោកទ្រង់ជ្រាបថា សុសិមៈត្រឡប់មក ក៏ចាត់ឲ្យអ្នករក្សាព្រះអង្គដាក់អ្នកចំបាប់ម្នាក់ឲ្យឈរចាំនៅទ្វារទី ១ ម្នាក់ទៀតឲ្យឈរចាំនៅទ្វារទី ២ ម្នាក់ទៀតឲ្យឈរចាំនៅទ្វារទី ៣ ជាមួយនឹងរាធគុប្ដៈសេនាបតី, ចំណែកទ្វារខាងកើត ព្រះអង្គឯងស្ដេចគង់ចាំនៅទីនោះនៅត្រង់មុខទ្វារទិសខាងកើតនោះ ស្ដេចបានឲ្យធ្វើរូបដំរីសអំពីយន្តមួយឲ្យធ្វើរូបចម្លាក់ស្ដេចអសោកជិះលើខ្នងនោះ ទីជុំវិញដំរីនោះបានឲ្យជីកគូធំ ១ ក្នុងទិសទាំងបួន ខាងក្នុងដាក់ពេញទៅដោយរងើកភ្លើង ហើយពីខាងក្រៅគេបិទបាំងដោយស្មៅនិងសម្រាមជិតជិតល្អ រហូតទាល់តែភ្នែកមនុស្សធម្មតាមើលមិនយល់ ៗ

សុសិមរាជឱរសយាងសំដៅទៅទ្វារទី ៣ ក៏រាធគុប្តសេនាបតីក្រាបទូលថា "ឥឡូវនេះ ព្រះបាទអសោកកំពុងទ្រង់គង់នៅទិសខាងកើត សូមព្រះអង្គយាងទៅតាមទ្វារទិសនោះចុះ ប្រសិនបើព្រះអង្គយាងទៅបានដូចសេចក្ដីប្រាថ្នា ខ្ញុំព្រះអង្គសូមដេកកោនក្រោមម្លប់ព្រះបារមីផង ប្រសិនបើព្រះអង្គមិនអាចនឹងបង្ក្រាបព្រះបាទអសោកបានទេ ព្រះអង្គនឹងមិនអាចយាងចូលតាមទ្វារនេះបានទេ" ៗ

លុះព្រះសុសិមរាជកុមារទ្រង់ជ្រាបដូច្នោះ ក៏ស្តេចយាងទៅកាន់ទ្វារទិសខាងកើត ទតឃើញដំរីនិងរូបចម្លាក់នោះហើយក៏ខំប្រឹងរុកទន្ទ្រានចូលទៅ ដើម្បីនឹងឡើងលើដំរីហើយចាប់រូបចម្លាក់ព្រះបាទអសោកនោះ ក៏ធ្លាក់ចុះក្នុងរណ្ដៅគូដែលពេញទៅដោយរងើកភ្លើង ទ្រង់ក៏អស់ព្រះជន្មក្នុងទីនោះទៅ ។

កាលបើសុសិមកុមារអស់ព្រះជន្មហើយ យក្សជាបរិវាររបស់ព្រះអង្គឈ្មោះកទ្រាយុធ ព្រមដោយពួកពលជាច្រើនពាន់ បានចូលបួសក្នុងព្រះពុទ្ធសាសនាហើយបានសម្រេចមគ្គផលព្រះអរហត្តគ្រប់ៗអង្គទៅ ។

ខាងក្រោយអំពីព្រះបាទអសោកស្តេចទ្រង់រាជ្យ ពួកសេនាបតីក៏កើតសេចក្ដីមើលងាយដល់ព្រះអង្គ ទើបទ្រង់រិះរកហេតុឧបាយកលដោយការស្ទាត់ដើម្បីនឹងផ្ចាញ់ផ្ចាលអស់ពួកអ្នកទាំងនោះ ។ ពេលនោះ ទ្រង់ត្រាស់បង្គាប់ឲ្យពួកសេនាបតី កាប់ដើមឈើមានផ្លែនិងឈើមានផ្កាទាំងឡាយ យកមកស្រាស់ព័ទ្ធធ្វើជារបងនៃឈើមានបន្លាជាការផ្ទុយគ្នាយ៉ាងនេះ ។

ពួកសេនាបតី ទូលជំទាស់ព្រះឱង្ការថា " តាំងតែពីដើមរហូតមកដល់ពេលនេះហើយ យើងដែលឮតែគេថា ស្រាស់ព័ទ្ធគុម្ពឈើមានផ្លែដោយឈើមានបន្លា មិនដែលឮថា អ្នកណាស្រាស់ព័ទ្ធឈើមានបន្លាដោយឈើមានផ្លែផ្កានោះសោះ " ។

ពួកសេនាបតី ទទឹងតាស់មិនគោរពតាមព្រះរាជឱង្ការរហូតដល់ ៣ លើក ។

គ្រានោះឯងព្រះបាទអសោក ទ្រង់ព្រះពិរោធដ៏លើសលុប ក៏ដកព្រះខ័នឡើងប្រហារជីវិតពួកសេនាបតីទាំងប្រាំរយនាក់នោះទៅ ។

លំដាប់តមក ក្នុងរដូវផ្កាឈើ ដល់វេលាព្រឹក្សជាតិបញ្ចេញផ្ការីកស្គុះស្គាយគ្រប់ដើម ក៏ព្រះបាទអសោកមាននាងព្រះស្នំហោមរោមជាបរិវារស្តេចយាងយាត្រាទៅក្រសាលក្នុងរាជឧទ្យាន នៅក្នុងឧទ្យាននោះមានដើមឈើមួយដើមឈ្មោះអសោក កំពុងតែផ្កាមានក្លិនកេសរក្រអូបឈ្ងុយឈ្ងប់ ទើបព្រះបាទអសោកទ្រង់សព្វព្រះរាជហឫទ័យនឹងដើមឈើនោះ ព្រោះឈើនោះមានឈ្មោះត្រូវនឹងនាមព្រះអង្គ ។ បានពោលមកហើយថា ព្រះសរីរកាយៈរបស់ព្រះបាទអសោកមានសម្បុររើងគ្រោតគ្រាត ហេតុនោះបានជាមិនពេញចិត្តពួកស្រីព្រះស្នំដែលជាអ្នកត្រូវការដោយសម្ផស្ស លុះព្រះរាជាកំពុងផ្ទុំលក់នៅទីព្រះពន្លាក្នុងឧទ្យាននោះ ក៏ពួកស្រីព្រះស្នំដែលគាល់នៅខាងក្នុងនាំគ្នាត្រេចដើរលេងសប្បាយតាមអំពើចិត្តទៅក្នុងឧទ្យាន បានឃើញដើមអសោកនោះក៏បេះបោចផ្កា កាច់ទាំងមែកឈើនោះផង កាលព្រះរាជាទ្រង់តើនឡើងចាកព្រះបន្ទំទតឃើញដូច្នោះ ទើបត្រាស់សួរថា "អ្នកណាធ្វើបំផ្លាញដើមឈើនុះអស់ ? រាជបរិពារក្រាបទូលថា "សូមទ្រង់ព្រះមេត្តា

ប្រាសពួកស្រីព្រះស្នំ" ។ កាលព្រះរាជាទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ទើបទ្រង់ព្រះពិរោធខ្លាំង ត្រាស់ឲ្យចាប់ពួកស្រីព្រះស្នំរបស់ព្រះអង្គទាំងប្រាំរយ យកទៅផ្ទៀបជុំវិញដើមឈើនោះហើយដុតភ្លើងទាំងរស់ស្លាប់ទាំងអស់គ្នាទៅ ។ ពួកអ្នកនគរទាំងអស់បានឃើញព្រះអង្គមានព្រះរាជហឫទ័យខ្លាំងដូច្នោះ ទើបនាំគ្នាហៅព្រះអង្គថា "ចណ្ឌាសោក (អសោកកាច)" ។

ខណៈនោះ រាជគុប្តជាសេនាបតីទី ១ ទើបទូលតឿនព្រះរាជាថា "សូមព្រះរាជតេជះមិនជាការសមគួរដល់ព្រះអង្គ ជាស្តេចដែលទ្រង់ធ្វើកម្មដូច្នោះដោយផ្ទាល់នឹងព្រះហស្តព្រះអង្គទេ ព្រះអង្គគួរតាំងបុរសឲ្យមាននាទីជាអ្នកពិឃាតមនុស្ស ដែលព្រះអង្គបានដាក់ព្រះរាជអាជ្ញា ហើយត្រូវពេជ្ឈឃាតនោះធ្វើតាមការពិភាក្សារបស់ព្រះអង្គ ។

ព្រះបាទអសោកក៏យល់ព្រមតាមពាក្យសូមនោះ ទើបមានព្រះឱង្ការចាត់ឲ្យរកបុរសម្នាក់មានចិត្តក្លាហាន ដែលល្មមតាំងឲ្យធ្វើជាពេជ្ឈឃាតបាន ។

គ្រានោះ មានជាងដម្បាញម្នាក់ តាំងផ្ទះនៅក្នុងបច្ចន្តព្រាមជិតជើងភ្នំ ជាងដម្បាញនោះមានកូនប្រុសមួយឈ្មោះ គិរិកៈ[1] មនុស្សនេះកាចជាទីបំផុត វាតែងធ្វើទុក្ខបុកម្នេញដល់ពោលម្តាយឪពុកជានិច្ច

១ គិរិកៈ ជាឈ្មោះរបស់មនុស្សអ្នកនៅភ្នំ ។

ក៏កាន់លប់ទៅដៃក៏ដោតដង់ ក៏លាបថ្នាំពុលនៅលើស្មៅនិងស្លឹកឈើទាំង-ឡាយ ពួកសត្វដើរទៅប៉ះពាល់ថ្នាំនោះពុលស្លាប់វិនាសជាអនេក ៗ ពួកអ្នកស្រុកទាំងអស់គេប្រកាសប្រាប់គ្នាថា បុរសនោះកាចណាស់ ហើយក្នុងស្រុកទាំងមូលគេតែងហៅគិរិកៈនោះថា "ចណ្ឌគិរិកៈ ( គិរិកកាច[១] )" ។

រាជបុរសបានទៅជួបនឹង គិរិកៈ ហើយនិយាយថា "អ្នកឯងហ៊ានធ្វើជាពេជ្ឈឃាតរបស់ស្តេចអសោកឬទេ ?". គិរិកៈឆ្លើយតបថា "ប្រសិនបើឲ្យខ្ញុំធ្វើទោសផ្ចាញ់ផ្ចាលមនុស្សខូចកាចក្នុងទ្វីបមួយទាំងមូល ក៏ខ្ញុំធ្វើបានដែរ មិនជាការសំខាន់អ្វីនឹងធ្វើជាពេជ្ឈឃាតទទួលការសម្រាប់ស្តេចអសោកមួយប៉ុណ្ណោះ" ។ រាជបុរសបានស្តាប់ពាក្យនោះហើយ ទើបត្រឡប់ទៅក្រាបទូលព្រះមហាក្សត្រិយ៍ ព្រះអង្គទ្រង់ឲ្យទៅនាំគិរិកៈនោះមក ។ រាជបុរសក៏ត្រឡប់ទៅដល់គិរិកៈវិញ និយាយប្រាប់ថា "មក គិរិកៈ ព្រះរាជាត្រាស់ឲ្យហៅអ្នកទៅ" ។

ចណ្ឌគិរិកៈ ដឹងដូច្នោះហើយ ក៏ម៉ូម៉ាទៅសូមអនុញ្ញាតអំពីមាតាបិតា តែមាតាបិតាមិនព្រមបើកឲ្យ , បានព្យាយាមហាមប្រាម់ឃាត់មិនឲ្យធ្វើក្នុងដំណែងនេះ ក៏ចណ្ឌគិរិកៈសម្លាប់មាតាបិតាទាំងពីរនោះទៅ ទើបស្ទុះចុះពីលើផ្ទះមក ខណៈនោះរាជបុរសសួរថា " ហេតុដូចម្តេច បាន

១ មហ.វង្ស: មិនមាននិយាយដល់រឿងរ៉ាវ គិរិក; នេះទេ ។

ជាយឺតយូរម៉្លេះ?" ចណ្ឌគិរិកៈតបថា "មែនខ្ញុំគាត់មិនព្រមអនុញ្ញាតឲ្យខ្ញុំមកសោះ តែខ្ញុំសម្លាប់គាត់ទាំងពីរនាក់នោះទៅហើយ ហេតុនេះបានជាខ្ញុំយឺតយូរបន្តិច" ។

ចណ្ឌគិរិកៈ និយាយរឿងរ៉ាវគ្រប់ប្រការឲ្យស្តាប់ហើយ ទើបចូលទៅគាល់ស្តេច លុះដល់ហើយក្រាបថ្វាយបង្គំទូលថា "សូមព្រះអង្គសាងគុកមួយទុកជាមន្ទីរយុត្តិធម៌ដាក់ជារបៀបល្អយ៉ាងសំខាន់ឲ្យមានរូបរាងខាងក្រៅគួរជាទីសប្បាយរីករាយនៃចិត្តអ្នកផងទាំងពួង កាលបើសាងមន្ទីរនោះរួចហើយ សូមឲ្យឈ្មោះថា "គុកជាទីសុខសម្រាន្ត(១)" ។

គ្រានោះ ចណ្ឌគិរិក ទូលសូមពរព្រះរាជាថា "សូមទេជះព្រះអង្គប្រព្រះរាជទានពរមួយដល់ខ្ញុំព្រះអង្គ គឺបើអ្នកណាមួយក៏ដោយតែចូលមកកាន់មន្ទីរនេះ សូមទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គថា មិនត្រូវឲ្យអ្នកនោះចេញទៅវិញជាដាច់ខាត" ។ ព្រះបាទអសោកក៏ទ្រង់ព្រោសប្រទានពរឲ្យតាមសេចក្តីសូមនោះ ។

ខាងក្រោយពីនោះមក ចណ្ឌគិរិក បានចូលទៅកាន់វត្តកុក្កុដារាម កាន់វត្តនោះ មានភិក្ខុមួយរូបកំពុងស្វាធ្យាយពាលបណ្ឌិតសូត្រថា:

"ពួកសត្វដែលចូលចិត្តនឹងទឹកពុះនៅក្នុងខ្ទះ ត្រូវគេបុកក៏នោះកំទេចដោយអង្រែ ៗ ពួកសត្វដែលចូលចិត្តគេបុកក្នុងត្បាល់ ត្រូវគេបំអិនក្នុង

(1) prison-agréable ។

ខ្ទះ ។ ពួកសត្វដែលនៅក្នុងនរកលេបដុំដែកចំហួល ហើយនាយនិរយ-បាលបន្ថែកទឹកទង់ដែងក្តៅៗ ចាក់ក្នុងមាត់(១)" ។ កាលបើបានឮសេចក្តីនៃព្រះសូត្រនោះហើយចណ្ឌគិរិកៈទើបត្រិះរិះថា "គុកអញត្រូវឲ្យមានវិធីរបបនេះចុះ" ។

---

១ ពាលបណ្ឌិតសូត្រសំស្ក្រឹត សេចក្តីប្រហែលគ្នានឹងទេវទូតសូត្របាលី ក្នុងគម្ពីរមជ្ឈិមនិកាយ ។ ទេវទូតសូត្របាលីថា. . . . ពួកនិរយបាលសួរថា "ឯងប្រាថ្នាអ្វី" សត្វនរកតបថា "ព្រះគុណអើយ ខ្ញុំឃ្លានណាស់ ។ ពួកនិរយបាលយកដែកស្រួចដំក្តៅកំពុងឆេះច្រាលក្តៅភ្លើងទ្វាលចកទល់មាត់សត្វនរកនោះហើយ ញាត់ដុំទង់ដែងដែលភ្លើងកំពុងឆេះសន្ធោសន្ធៅនៅក្នុងមាត់. . . ។ ពួកនិរយបាលនឹងសួរទៀត សត្វនរកតបថា "ព្រះគុណអើយ ស្រេកណាស់" ។ ពួកនិរយបាលយកដែកស្រួចដំក្តៅកំពុងឆេះច្រាលក្តៅភ្លើងទ្វាលចកទល់មាត់សត្វនរកនោះ ហើយបង្ហូរទឹកទង់ដែងដែលភ្លើងកំពុងឆេះសន្ធោសន្ធៅទៅក្នុងមាត់ ។

(នៅមានត)

# ពង្សាវតារក្រុងរោម

(តមកនិងចប់)

១- ទទួលយកសាសនាគ្រិស្ទានមកថែទាំទុកជាសាសនារបស់រោម ។

២- បានតាក់តាំងទីក្រុងឡើងជាថ្មី តាមព្រះនាមរបស់ទ្រង់ ហៅថា កុងស្តង់ទីណោប៉្លឹ (Corstantinoble) ។

៣- ទ្រង់តាក់តែងបែបត្រួតត្រាស្រុកតាមរបៀបចក្រភពអាជ្ញាសិទ្ធិ-កជ ។

សាសនាគ្រិស្តបានផ្សាយចូលមកក្នុងក្រុងរោម តាំងអំពីសម័យនេរ៉ុងមុននោះទៅទៀត មុននឹងចូលមកដល់ក្រុងរោមនេះ សាសនានោះបានរាយកាយចេញទៅច្រើនហើយៗ នៅប្រទេសក្រិកតាំងមូល ស៊ើរតែមានកាន់សាសនានោះយ៉ាងមាំមួនហើយ ការផ្សាយសាសនាគ្រិស្តក្នុងស្រុកក្រិក ទំបស់ម្រេចបានដោយស្រួល ព្រោះគោលធម៌សំខាន់ៗនឹងគំនិតគតិគូររបស់ក្រិក ប្រហែលនឹងសាសនាគ្រិស្តនេះដែរ ។ តែការផ្សាយសាសនានេះចូលមកក្រុងរោម បែរជាលំបាកយ៉ាងខ្លាំង ព្រោះក្រុងរោមសម័យដែលមានព្រះរាជាធិរាជនេះ ពួកព្រះរាជាធិរាជប្រកាន់ទ្រង់ថាខ្ពង់ខ្ពស់បំផុត តែខាងសាសនាគ្រិស្តប្រដៅថាមានព្រះជាម្ចាស់ខ្ពង់ខ្ពស់ជាងព្រះរាជាធិរាជទៅទៀត ទើបពួកព្រះរាជាធិរាជក្រុងរោមបាន

ធ្វើទុក្ខទោសជាទម្ងន់ ដល់ពួកអ្នកផ្សាយសាសនានិងពួកអ្នកកាន់សាសនា នេះដូចជាចាប់ដុតទាំងរស់, វាយបោះដែកគោលឆ្កាង, ចាប់បញ្ចូលទៅក្នុងទ្រុងខ្លាជាអាហារសត្វព្រៃ, ឲ្យគោកាចវ័ធទាល់តែធ្លាយពោះវៀន, ចាប់ឲ្យអង្គុយលើកៅអីដែកដែលដុតក្តៅឆេះក្រហមព្រាល ៗ ទោសទាំងនេះត្រូវធ្វើកងទីប្រជុំជន ពួកអ្នកដែលឈរមើលនាំគ្នាសប្បាយរីករាយដូចជាមើលល្ខោនសព្វ ៗ យើងបានដឹងខ្លះមកហើយថា ពួកគ្រិស្ត-សាសនិកជនមានមានះខ្មីខ្មាតកងការផ្សាយសាសនាជាចំហុត បើកាន់តែត្រូវគេធ្វើបាបខ្លាំងឡើង ក៏កាន់តែខំផ្សាយខ្លាំងឡើងដែរ ដរាបមកដល់សម័យផែនដីព្រះបាទកុងស្តង់តាំងនេះ ទើបសាសនានេះក្លាយទៅជាសាសនាប្រចាំជាតិរ៉ូម៉ាំង ដោយមហាក្សត្រអង្គនេះទ្រង់ឧបត្ថម្ភ ៗ

ការដែលព្រះបាទកុងស្តង់តាំង ទ្រង់តាំងទីក្រុងនៃរាជអាណាចក្ររ៉ូមឡើងថ្មីនេះ ដោយហេតុផលច្រើនប្រការ ព្រោះប្រការទី ១ សត្រូវសំខាន់របស់ក្រុងរ៉ូម គឺពួកកុត្សនិងពួកពែរ្ស ទើបត្រូវតែបន្ទយទីក្រុងឲ្យថយចូលមកជិតទន្លេដានុប (Danube) និងទន្លេអឺប្រាត (Euphrate) ដើម្បីទទួលមុខសឹកទាន់ការ ៗ ប្រការទី ២ ព្រោះសាសនាចាស់របស់ក្រុងរ៉ូមមានទេវរូបជាចំនួនច្រើនលើសលប់គណនា ដូចយើងបានពោលពីខាងដើមមកហើយថា ការដើរកូលៈទៅក្រុងរ៉ូមនោះ នឹងបានឃើញទេវរូបផ្សេងៗ ច្រើនជាងមនុស្សទៅទៀត ៗ កាលព្រះអង្គទទួល

ប្រកាសសាសនាគ្រិស្តចូលមកជាសាសនាប្រចាំក្រុងរ៉ូមហើយ គាត់តែវៀសវាងកុំឲ្យមានការរម៉ិលញាយប្រមាថទេវរូបចាស់ៗ គស់នោះម្នាស់ពេក ទើបទ្រង់ផ្លាស់ទីក្រុងជាថ្មី ៗ មួយវិញទៀត ក្រុងកុងស្តង់ទីនោប៉ូ ជាទីសមគួរជាងទីក្រុងរ៉ូមដោយប្រការទាំងពួង ពោលគឺជាស្រុកភ្ជាប់តទ្វីបអឺរ៉ុបនឹងទ្វីបអាស៊ី ហើយជាទីការពារស្រួលបានជាចំណាប់ផងហើយ ជាកំពង់ជំនួញយ៉ាងល្អផង ។ ព្រះបាទកុងស្តង់ទីនោប៉ូ ទ្រង់កសាងស្រុកនេះឡើងតាមបែបរ៉ូមទាំងអស់ ហើយទ្រង់នាំប្រជាជនអភិជនយ៉ាងដែលមានត្រកូលខ្ពង់ខ្ពស់ៗទៅនៅ និងនាំប្រជាជនជិតខាងក្រុងរ៉ូមឲ្យទៅនៅក្រុងថ្មីនោះ ។ ទ្រង់តាំងព្រះរាជបណ្ណាល័យដែលមានពាសពេញទៅដោយសៀវភៅ ដែលរឹបយកមកពីពួកក្រិក ហើយទ្រង់បង្គាប់ឲ្យប្រទេសអេស៊ីប្ត៍បញ្ជូនស្បៀងទៅចិញ្ចឹមប្រជាជននៅក្រុងថ្មីនោះ ព្រោះពួករាស្ត្រមិនទាន់បានត្រៀមខ្លួនធ្វើរបរកសិកម្មជាមាំមួន ។

យើងបានពោលពីខាងដើមរួចមកហើយថា ព្រះបាទឌិយោក្លេទៀន ទ្រង់ព្យាយាមនឹងលើកដំកើងអំណាចមហាក្សត្រឲ្យខ្ពស់ត្រដែតឡើង តែធ្វើមិនសម្រេច ព្រោះប្រជាជនថ្នឹកផ្ទុតជាប់នឹងរបៀបប្រជាធិបតេយ្យ នឹងសភាសេណាត់ និងសភាតំណាងរាស្ត្រ ជាវេលាយូរមកហើយ ។ ការដំកើងអំណាចមហាក្សត្រឲ្យខ្ពស់បំផុតនេះ មិនមែនជាការធ្វើបានដោយងាយស្រួលទេ គ្រាតែមកដល់សម័យព្រះបាទកុងស្តង់ទីនោប៉ូ

ទើបទ្រង់ធ្វើការនេះបានសម្រេច គឺទ្រង់លុបសភាសេណាត់ ទាំងសភារាស្ត្រចេញ ហើយទ្រង់ប្រមូលអំណាចផែនដីទាំងមូលមកទុកក្នុងព្រះហស្ត បានដោយងាយ ៗ តាំងអំពីនោះមកក្រុងរោមទើបមានរបស់សំខាន់ ៣ យ៉ាង គឺព្រះរាជាធិរាជ, រដ្ឋបាល, និងបណ្ដារាស្ត្រ ៗ ព្រះបាទកុងស្តង់ទីនោប៉្ល គួរតាត់ជាមហាក្សត្រអង្គ ១ របស់រោម ទ្រង់មានសភាពសមជាស្តេចពិត ៗ ទ្រង់ជាទីគោរពនៃប្រជាជនទូទៅ ទុកដូចជាព្រះ ១ ព្រះអង្គ ទ្រង់ពាក់មកុដមាស ហើយប្រជាជនយកកំទេចមាសរោយព្រះបាទវេលាក្រាបបង្គំទូលការអ្វី ៗ គោងលុតជង្គង់ អស់ទាំងគ្រឿងក-ដូបភោគក៏គង់តែគោរពពកប់ភាន ទុកជារបស់ស័ក្តិសិទ្ធិដែរ ឯពួកអ្នករាជការក៏ទ្រង់តាំងឲ្យមានយសសក្តិតាមសមគួរ ហើយត្រូវមានគ្រឿងសំគាល់សម្រាប់ខ្លួនផង ៗ មានអ្នកប្រាជ្ញពង្សាវតាររ៉ូម៉ាំងម្នាក់ពោលទុកថា ពួកអ្នករាជការដែលពាក់គ្រឿងសំគាល់នេះមានចំនួនច្រើនជាងរុយក្នុងរដូវក្តៅទៅទៀត ៗ

តែព្រះបាទកុងស្តង់ទីនោប៉្លទ្រង់ជ្រាបច្បាស់ នៅវេលាក្រោយថា បើអស់បុណ្យទ្រង់ទៅហើយ គង់តែមិនមានអ្នកឯណាមួយ អាចគ្រប់គ្រងមហាអាណាចក្ររោមដូចជាព្រះអង្គ ដល់វេលាជិតក្ស័យព្រះជន្ម ទើបទ្រង់បែងមហាអាណាចក្រនេះជា ៣ ភាគ ប្រគល់ឲ្យព្រះរាជបុត្រទាំង ៣ អង្គគ្រប់គ្រង ៗ

ស្រុកទេសក្តី កិច្ចការផ្ទាល់ខ្លួនក្តី បីបំបែកមតិកឲ្យបែកគ្នាទៅហើយ រមែងតែឲ្យទោសច្រើនជាងគុណ បើជាត្រកូលធំៗ ដូចជាត្រកូលមហា-សេដ្ឋីមានកូនច្រើន ហើយបែងមតិកបែកបន្តិចម្នាក់ៗទៅគ្រប់គ្នា មិនឲ្យមានអ្នកទទួលដំណែងជានាយកក្នុងត្រកូលហើយ ត្រកូលនោះទៀងតែទីងអប្បទុនសាបសូន្យទៅជាមិនខាន ៗ ឯស្រុកទេសក៏មានទំនងដូចគ្នាដែរ តាមពង្សាវតារលើងមានសំដែងឲ្យឃើញច្បាស់ថា ការបែងអាណាចក្រឲ្យពួកពងរសេត្រួតត្រាស្រុក មានអំណាចដាច់ស្រេចតែរៀងខ្លួនហើយ មានតែនាំមកនូវសេចក្តីវិនាសសាបសូន្យជានិច្ចមិនសូវដែលខាន ៗ ហេតុនេះហើយ បានជាកាលព្រះបាទកុងស្តង់ទីនោប៉ូក្ស័យព្រះជន្មទៅហើយ ក៏កើតចម្បាំងក្នុងស្រុកឡើងយ៉ាងសំបើម អាណាចក្រក្រុងរោមក៏ថយខ្សោយចុះទៅ ឯពួកមនុស្សព្រៃ ក៏លុកលុយចូលតាំងលំនៅៗក្នុងដែនអាណាចក្រ ខាងផ្លូវសាសនាសោតទៀត ក៏កើតចលាចលវរើកពោលគឺព្រះបាទស៊ុលលីយាង (Julien) ជាព្រះរាជនត្តារបស់ព្រះបាទកុង-ស្តង់តាំងបានព្យាយាម បង្ខំឲ្យក្រុងរោមបែរមកកាន់លទ្ធិសាសនាចាស់វិញ ហើយសេចក្តីព្យាយាមនេះក៏ធ្មើងសម្រេច ព្រះបាទស៊ុលលីយាងក៏ទិ-វង្គតទៅ គ្មានអ្នកទទួលស៊ើបរាជសម្បត្តិ ទើបពួកទាហានជ្រើសរើសក្សត្រសោយរាជ្យម្តងទៀត មានក្សត្រដែលតាំងឡើងតាមទំនងនេះតៗមកទៀតដល់ ៣ អង្គ ៗ ក្នុងក្រោយបង្អស់ទ្រង់ព្រះនាម ថេអូដោស៍ (Théodose) ៗ

មហាក្សត្រអង្គនេះ ទ្រង់មានព្រះទ័យជ្រះថ្លាទីងសាសនាក្រេចៀង ជាខ្លាំង ។ កាលគ្រាមុននេះយើងបានពោលមកហើយថា ពួកដែលនាំសាសនាក្រេចៀងមកផ្សាយក្នុងរ៉ោមនេះត្រូវទុកទោសជាមុន តែកដល់សម័យព្រះបាទថេអូដោស៍នេះ បែរជាចាប់ពួកអ្នកប្រទូស្តក៏យសាសនាក្រេចៀង យកទៅប្រហារជីវិតមុខគ្នាឲ្យស្ងប់ស្ងៀង ដូចជាទ្រង់ឲ្យសម្លាប់មនុស្សជាចំនួនដល់ ៧០០០ នាក់ ។ ការធ្វើទុក្ខទោសតាមទំនងនេះ ទុកជាពួកគ្រិស្តសាសនិកជនក៏មានចិត្តទោមនស្សជាច្រើនដែរ ដូចជាថ្ងៃ ១ ព្រះបាទថេអូដោស៍ ស្តេចយាងចូលក្នុងវិហារស្រុកមីឡង់ ព្រះរាជាគណៈ (évêque) នៅវិហារនោះហាមឃាត់មិនឲ្យស្តេចយាងចូលទៅ ហើយមានថេរដីកាឲ្យព្រះបាទថេអូដោស៍សុំខមាទោសចំពោះមុខប្រជាជន ។ ទ្រង់ក៏ព្រមប្រតិបត្តិតាម គ្រានេះជាគ្រាដំបូងក្នុងប្រវត្តិនៃសាសនាគ្រិស្ត ដែលមហាក្សត្រទ្រង់ស្តាប់បង្គាប់គណសង្ឃក្នុងព្រះសាសនា ។

តាំងអំពីនោះ ពួកលោកសង្ឃបាកាំងក៏ចាប់ផ្តើមមានអំណាចក្នុងស្រុកទេស ហើយព្រះសង្ឃរាជនៅក្រុងរ៉ោម ជាអ្នកមានអំណាចខ្ពង់ខ្ពស់បំផុត ក្នុងសម័យកណ្តាលតាមអាយុកាលនៃសាកលប្រវត្តិសាស្ត្រនេះ ។

តាមដោយពិត ព្រះបាទថេអូដោស៍ទ្រង់រួបរួមក្រុងរ៉ោមមកទុកក្នុងព្រះហស្ត ទ្រង់ធ្វើក្រុងរ៉ោមឲ្យមានកម្លាំងរឹងប៉ឹងឡើងវិញបានទៀត លុះដល់ទ្រង់ទិវង្គតទៅ ទ្រង់បានបែងចែកអាណាចក្រជា ២ ភាគ គឺទិស

ខាងកើត ១ ភាគ ទិសខាងលិច១ ភាគ ទ្រង់ប្រគល់ឲ្យព្រះកជខរស ២ អង្គទ្រង់គ្រប់គ្រង ១ ភាគមួយអង្គ ៗ ព្រះបាទថេអូដោសឺទិវង្គតក្នុងពុទ្ធសករាជ ៩៣៨ (គ.ស.៣៩៥) ហើយការដែលទ្រង់បែងអាណាចក្រជា២ភាគ ក្នុងគ្រានេះជាបច្ច័យនាំឲ្យក្រុងរោមឈមមុខទៅកាន់សេចក្តីសាបសូន្យ លុះតមកទៀតមិនទាន់ដល់ ១០០ឆ្នាំ រាជអាណាចក្រនៅចំណែកទិសខាងកើតក៏គ្មានឈ្មោះ ឯរាជអាណាចក្រនៅទិសខាងលិចក៏តាំងនៅយូរបានតទៅទៀតបន្តិច តែមិនមានរឿងសំខាន់ ៗ ដែលគួរនិយាយកើតឡើងទេ ហើយនៅទីបំផុតរាជអាណាចក្រនេះ ក៏ធ្លាក់ទៅក្រោមអំណាចរបស់ទុរគី កាលពីពុទ្ធសករាជ១៩៩៦ (គ.ស.១៤៥៣)។

ចប់ពង្សាវតារភេទសម័យដើមដោយសង្ខេបតែប៉ុណ្ណេះ ។

---

# ភូមិសាស្ត្រសង្ខេបនៃទ្វីបអូស្ត្រាលី

**ទីតាំង** — ទ្វីបអូស្ត្រាលីតាំងនៅទិសខាងត្បូងរវាង ១១$^0$ និង ១៩$^0$ និងតាំងនៅទិសខាងកើតរវាង ១១៣$^0$ និង ១៥៣$^0$ ទើបឃើញថាទ្វីបនេះតាំងនៅក្នុងតំបន់ក្តៅពាក់កណ្តាល តំបន់ត្រជាក់ពាក់កណ្តាល ។

**អាណាខេត្ត** -- អាណាខេត្តទិសខាងជើងទល់នឹងសមុទ្រអារ៉ាហ្វ៊ូរ៉ានឹងសមុទ្រទីម័រ ទិសខាងកើតទល់នឹងសមុទ្រគូរ៉ាល់និងមហាសមុទ្រប៉ាស៊ីហ្វិក, ទិសខាងលិចនិងខាងលិចឆៀងខាងត្បូងទល់មហាសមុទ្រឥណ្ឌា ទិសខាងត្បូងទល់នឹងសមុទ្រខាងត្បូង (Mer du sud) ។

**ខ្នាត** — បណ្តោយទ្វីបរាប់ពីទិសខាងកើតទៅដល់ទិសខាងលិចប្រមាណ ៦២១៦ គីឡូម៉ែត្រ ឯទទឹងប្រមាណ ៥១៨០ គីឡូម៉ែត្រ ទំហំទាំងមូលប្រមាណ ៧.៦៣៦,២៦៨ គីឡូម៉ែត្រក្រឡា បើយកទំហំកោះតាស្មានីមករួមផង ជាទំហំដីទាំងអស់ប្រមាណ ៧.៧០៤.២៦៨ គីឡូម៉ែត្រក្រឡា ទ្វីបនេះទុកជាទ្វីបតូចបំផុត ។

**មាត់ច្រាំងសមុទ្រ** — វែង ១៩.៥៣៦ គីឡូម៉ែត្រលក្ខណៈច្រាំងសមុទ្រមានទំនងប្រហែលនឹងទ្វីបអាហ្វ្រិក មិនសូវមានឈូងលុកចូលទៅក្នុងទ្វីបជ្រៅដូចជាទ្វីបអឺរ៉ុបទេ ។ តែអូស្ត្រាលីមានឈូងធំៗច្រើនជាទ្វីបអាហ្វ្រិក ឯឈូងសំខាន់ៗ គឺឈូងគ្រែង់បេអូស្ត្រាលីយែន ឈូងកាប៉េនតារី, ឈូងកាមព្រឹតស៍, ឈូងប៉័រតភីលិប ។ ឯជ្រោយដែលសំខាន់ៗ

គឺជ្រោយយ៉ក (នៅទិសខាងជើង), ជ្រោយ'បណារត៍ដូអេស្ត (នៅទិស ខាងលិច), ជ្រោយព្រំ-វ៉ិលសុន (ទិសខាងត្បូង) ។

ផ្ទៃផែនដី — ទីដីកបទំនាបនឹងដីកបខ្ពស់ក្នុងទ្វីបអូស្ត្រាលីមានខ្នាត ប្រហែលៗគ្នា តាមមាត់ច្រាំងសមុទ្រជុំវិញទ្វីបជាដីកៈជាទីទំនាបទួទៅ ពីមាត់ច្រាំងចូលទៅក្នុងទ្វីបបន្តិចបន្តួច ផ្ទៃផែនដី ក៏ចាប់ផ្តើមខ្ពស់ឡើងៗ ទៅជាទីទួលខ្ពស់ (៣០០ម៉ែត្រ) ឯទីកបទំនាបខាងមហាសមុទ្រប៉ាស៊ីហ្វិក ជាទីវៀវតូចបង្អៀតហើយចោតឡើងទៅទល់នឹងជួរភ្នំយ៉ាងធំវែង ដែលតាំងនៅតាមមាត់ច្រាំងសមុទ្រហូតទៅតាំងពីរដ្ឋក្វីនឡង់ហូតដល់រដ្ឋវិកតូរីយ៉ា ផុតពីជួរភ្នំអស់នោះទៅ ដីខ្ពស់ក៏សន្សឹមៗលាតទាបចុះទៅ ត្រាតែកើតជាទីកបយ៉ាងធំទូលាយបំផុតក្នុងទ្វីប ។ ផ្ទៃផែនដីដែលកបនេះក៏ខ្ពស់ចោតឡើងទៀត ទាល់តែទៅជាទីកបខ្ពស់យ៉ាងធំសំបើម ផ្ទៃដីចំណែកនេះក្រមានទឹកភ្លៀងនឹងជ្រោះជ្រលងដងអូរជាទីបំផុត មានតែអាកាសស្ងួតក្រៀមខ្លួទៅ តំបន់ខ្លះជាសមុទ្រខ្សាច់ ។

ភ្នំ — នៅទិសខាងកើតមានភ្នំជាច្រើនដូចជាភ្នំអែលតិ៍, ភ្នំដេនហាម, ភ្នំឡាំងសៃ, ភ្នំធលីវ៉ែរប៊ូរ៉ៈ, ភ្នំៈប៊ូស៍, ភ្នំប៊ូរេន, ភ្នំនូវ៉ែល អង់ក្លែរវ៉ា ដើម រួមហៅថា ការឌីយែរអូស្ត្រាលីយ៉ែន ។

នៅទិសខាងត្បូង មានភ្នំស្តូនខៀ, ភ្នំហ៊ីងដែរ, ភ្នំការលៃរ... ។

ទិសខាងលិច មានភ្នំដាលិង, នឹងវិកតូរីយ៉ាជាដើម ។

នៅកណ្ដាលទ្វីប មានភ្នំសម, និងម៉ាកដូនណែលជាដើម ។ កំពូលភ្នំដែលខ្ពស់បំផុតកំពស់ ២២០៥ម៉ែត្រ នៅជង់ភ្នំការឆៃយ៉ែរ-អូស្ត្រាលីយ៉ែន ។

សមុទ្រខ្សាច់-នៅលើទឹកដីពបខ្ពស់ភាគខាងលិចមានសមុទ្រខ្សាច់ធំ ២ អន្លើ គឺគ្រែងដេសេរត៍ជីសាប់ ១ គ្រែងដេសេរត៍វិកតូរីយ៉ា ១ ហើយមានសមុទ្រខ្សាច់ខាតតូច ១ ទៀតនៅទិសខាងជើង ។

ទន្លេសាប — ទន្លេសាបក្នុងទ្វីបនេះ ភាគច្រើនជាទន្លេសាបទឹកប្រៃ ហើយច្រើនតែជាទន្លេសាបរាក់ៗ មានទឹកតែក្នុងរដូវភ្លៀង ដល់រដូវប្រាំងហែងហួតអស់ទៅ ទន្លេសាបមានច្រើននៅអូស្ត្រាលីខាងលិច និងអូស្ត្រាលីខាងត្បូង ដែលសំខាន់គឺ ភាលេក្សង់ដ្រ, អ៊ែយ៍, តូរ៉ង់, កាកណែរ, អាម៉ាដឹស, អូស្ទាំងជាដើម ។

ទន្លេ — ទន្លេស្ទឹងផងអស់ក្នុងទ្វីបអូស្ត្រាលីមានចំនួនតិចពេក ហើយច្រើនហែងហួតក្នុងរដូវប្រាំងផង មានផ្លូវទឹកជាច្រើនដែលហូរធ្លាក់ទៅក្នុងត្រពាំងបឹងបួរ និងទន្លេសាប មិនសូវមានផ្លូវទឹកហូរធ្លាក់ទៅក្នុងសមុទ្រទេ ។ ការខ្វះខាតទឹកនេះមកពីហេតុ ២ ប្រការ ប្រការ ១ ភ្នំនៅទ្វីបនេះមិនសូវខ្ពស់ល្មមឲ្យមានហិមៈ ចាប់នៅកំពូលភ្នំបានគ្រាស់ៗ ប្រការ ១ ទៀតមិនសូវមានភ្លៀងធ្លាក់សព្វគ្រប់អន្លើ មានធ្លាក់ច្រើនតែតាមភ្នំដែល

នៅជិតៗ នឹងមាត់សមុទ្រខាងជើងដែលមានអាកាសក្តៅ នឹងតាមដងកំផ្ទំ តាមមាត់សមុទ្រខាងចំណែកមហាសមុទ្រប៉ាស៊ីហ្វិក ។

ក្លូនឡុងប៉ិ — មានទន្ទេហ៊្វូនដែរ, តុមស៊ុង, ឌីយ៉ាម៉ង់ទីណា ។

នូវ៉ែល-គ្លូស្ទ-មានផ្ទៃទឹកបរិបូណ៌ជាងរដ្ឋឯទៀតៗ ស៊ឹងសំខាន់ គឺជារលិង, (ជាស៊ឹងដែលមានខ្នាតវែងបំផុតក្នុងអូស្ត្រាលី ស៊ឹងឡាចឡង់, មៀរុមប៉ិតស៊ី ។

អូស្ត្រាលីខាងត្បូង មានទន្ទេមៀរ៉ៃយហូរចេញទៅឈូងជីឡូរង់-កុងត្រ៍ ទន្ទេនេះមិនសូវជ្រៅទេ ទាំងមានល្បប់ដុះឡើងនៅមាត់ពាមសមុទ្រផង កប៉ាល់បើកចូលទៅពុំរួច ។

ដែនអូស្ត្រាលីខាងជើង - មានផ្ទៃទឹកជាច្រើនដែរ តែជាស៊ឹងតូចៗ ដែលសំខាន់គឺស៊ឹងវិកតូរិយ៉ានឹងពៅប៉ែរ ។

ដែនអូស្ត្រាលីខាងលិច មានស៊ឹងមៀរគីសុង, អាសបៀរតុងជាដើម ។

ខ្យល់អាកាស — នៅតំបន់ក្តៅទិសខាងជើងៗ មានអាកាសក្តៅប្រហែលៗ នឹងភ្នំស៊ុនៈនះដែរ ដល់មកដល់កណ្តាលទ្វីបកំដៅក៏អន់ថុះទៅដល់អាកាសត្រជាក់ល្មមនៅតំបន់ទិសខាងត្បូងៗ នៅតំទវទិកបត្តស់មានអាកាសក្តៅច្រើន ព្រោះជាទីវាលស្រឡះ ទទួលកំដៅថ្ងៃពេញទី

ទណ្ហាកូម៉ុនៅភាគខាងជើង ក្រៀនកាំស់អាកាសរហូត ១ឆ្នាំបាន ៨៥ ដឺក្រេ ហើយថយចុះទៅដល់ជាប់នៅសល់ត្រឹម ៥៥ ដឺក្រេនៅភាគខាងត្បូង ។

ក្នុងរដូវក្តៅ មានខ្យល់សមុទ្របក់មកពីទិសខាងជើងទិសខាងលិចឆៀងខាងជើង បាននាំភ្លៀងមកបង្អុរនៅភាគផែនដីខាងជើងទ្វីបជាចំនួនច្រើន ហើយមានខ្យល់បក់យកទឹកភ្លៀងពីទិសខាងកើតឆៀងខាងត្បូងមក បង្អុរចុះនៅភាគខាងកើត តែភ្លៀងធ្លាក់នៅក្នុងជាច្រើនជិតអស់ទៅមិនសូវមានធ្លាក់ភ្លៀងទៅដល់កណ្តាលទ្វីប ទុកជាមានខ្យល់បក់ភ្លៀងឆ្លងភ្នំទាបៗនិងដីរាបខ្ពស់ក្លួសចូលទៅដល់កណ្តាលទ្វីបបាន ប៉ុន្តែអាកាសដែលនៅនាកណ្តាលទ្វីបនោះក្តៅខ្លាំងពេកធ្វើឲ្យចំហាយទឹកដែលខ្យល់បក់ចូលមកនោះហែងហួតស្ងួតទៅបាន ។ ដល់រដូវរងានៅភាគខាងលិចនិងខាងត្បូង តែងបានទទួលទឹកភ្លៀងមកពីទិសខាងលិច ទើបមានភ្លៀងធ្លាក់ក្នុងរដូវនេះ ។ ឯភាគខាងជើងនិងភាគខាងកើតត្រឡប់ជាមិនសូវមានភ្លៀងធ្លាក់ទេ ។

ភ្លៀងធ្លាក់ច្រើនបំផុតនៅតំបន់ខាងជើង ហើយតិចបំផុតនៅផែនដីកណ្តាលទ្វីប ។ នៅតំបន់ទិសខាងកើតឆៀងខាងត្បូងនៃទួរ៉ែល- កល្និងទិសខាងកើតវិកតូរីយ៉ា មានភ្លៀងធ្លាក់រហូតពេញមួយឆ្នាំៗ ។

សម្បត្តិផែនដី — ១ ដំណាំដែលដុះលូតលាស់ល្អនៅភាគខាងជើងនិងភាគខាងកើតលើដីរាបជាទីទួលខ្ពស់ច្រើនតែជាទីវាលស្មៅនិងព្រៃ

ល្បោះ ជាទីសមគួរដល់ការចិញ្ចឹមចៀមពពែ ឯព្រៃឈើមានដំឡៃច្រើន តែព្រៃឈើអ៊ុយជាការលិចទុស, ស្រល់, និងជាតិឈើដែលដុះតាមបន្ទេះភ្នំ នៅភាគខាងកើតនិងភាគខាងត្បូងភាគខាងលិច មានតែដើមឈើទាបៗ ដោយច្រើន ។

ដំណាំដែលដាំច្រើន គឺស្រូវមេ្ស, និងស្រូវជ្យេង, អំពៅ, ពោត, ដំឡូងបារាំង, ទំពាំងបាយជូរជាដើម ។

២ - លោហធាតុ - លោហធាតុសំខាន់របស់អូស្ត្រាលី គឺធ្យូងថ្ម, និងមាស លោហធាតុបន្ទាប់មកគឺប្រាក់, សំណ, ទង់ដែងនិងសំណ-ប៉ាហាំង, ហ្វូសហ្វាត, សាំង្កស៊ី, នីកែល, ដែកជាដើម ។

៣ - សត្វ - ចៀមកែះនិងគោជាសត្វដែលចិញ្ចឹមច្រើនបំផុត ធ្វើឲ្យកើតជាជំនួញលក់ចេញយ៉ាងសំខាន់ឡើង ៣ យ៉ាងគឺរោមកែះ, សាច់គោនិងបៀរ ។

ក្នុង ព.ស. ២៤៧៧ មានចំនួនកែះ ១១៤,០៩៩,៤៩០ គោ ១៣,៥១២,១៥៦ សេះ ១,៧៦៣,២២៥ ជ្រូក ១,០៤៦,៨៦៧ ។

ជំនួញលក់ចេញ — អូស្ត្រាលីជាប្រទេសដែលចំរើនខាងផ្លូវពាណិជ្ជកម្មច្រើន ធ្វើការលក់ដូរនិងនានាប្រទេសទូទៅក្នុងលោក ជំនួញដ៏សំខាន់បំផុតនេះរបស់ប្រទេសនេះមាន ៣ យ៉ាង (ព.ស. ២៤៧៤) គឺរោមកែះ (៣២ លានលីវស្ទែរឡាំង) ស្រូវមេ្ស (១៤ លាន) មាស (១២

លាន) ជំនួញសំខាន់បន្ទាប់មកគឺបៀរ, សាច់សត្វ, ស្បែកសត្វ, ម្រេច, ផ្លែឈើ, សំណ, ស្ករ, ប្រាក់, សាំងស៊ី ខ្លាញ់សត្វនិងឈើ ផ្សេងៗ ។

ប្រទេសដែលទិញជំនួញអូស្ត្រាលីច្រើន គឺអង់គ្លេស, ជប៉ុន, ចិន, បារាំងសែស, សហរដ្ឋអាមេរិក, និងអាល្លឺម៉ង់ ។ ឯប្រទេសដែលលក់ជំនួញឲ្យអូស្ត្រាលីច្រើន គឺអង់គ្លេស, សហរដ្ឋអាមេរិក, ឥណ្ឌា, ពួកកោះអាំងនេអៀឡង់ដេស, ជប៉ុននិងអាល្លឺម៉ង់ ។

ជំនួញលក់ចូល — ក្នុង ព.ស. ២៤៧៤ ជំនួញលក់ចូលដែលសំខាន់បំផុតមាន ៤ យ៉ាង គឺសំពត់អំបោះ, ប្រេងកាត, សំពត់ព្រែ, គ្រឿងថ្នាំនិងគ្រឿងស៊ុម, គ្រឿងអគ្គិសនី ។ ជំនួញបន្ទាប់មកគឺធុង, បារី, ស្ករកៅ, សៀវភៅ, គ្រឿងសរសេរ, ក្រដាស, ថ្នាំជក់, ដែកនិងគ្រឿងម៉ាស៊ីន ។

ផ្លូវគមនាគម — ក្នុង ព.ស. ២៤៧៣ ផ្លូវរថភ្លើងដែលបើកប្រើហើយ មានខ្នាតវែង ៤៤,៥៦៨ គីឡូម៉ែត្រ របស់ឯកជនប្រមាណ ៦៩៧៦ គីឡូម៉ែត្រ មានផ្លូវរថអែ ១០២៦ គីឡូម៉ែត្រ ។ ខ្សែអាកាសប្រៃសនីយ៍វែង ១២.៣៨៤ គីឡូម៉ែត្រ ។

ប្រជាជន — ជាជាតិអង់គ្លេសស្ទើរតែទាំងអស់ ចំនួនអ្នកស្រុកកាយមានតិចណាស់ (ប្រមាណ ១ សែននាក់) ។ ចំនួនប្រជាជនទាំងអស់ក្នុង ព.ស. ២៤៧៨ មាន ៦,៧២៤,០០០ នាក់ ច្រើនតែកាន់

សាសនាគ្រិស្ទកាយប្រូតែស្តង់ ហើយមានមនុស្សនៅច្រើនតែក្នុងរដ្ឋវិកតូរិយ៉ា និងនូវែល-គល្ស ។

របៀបរដ្ឋបាល— ទ្វីបអូស្ត្រាលីជាស្រុកចំណុះអង់គ្លេសទាំងមូល ទើបមានវិធីគ្រប់គ្រងទ្វីបនេះ ដូចជាប្រទេសតែមួយ ប្រទេសអូស្ត្រាលីប្រកបដោយរដ្ឋកូលូនី ៦ គឺរដ្ឋវិកតូរិយ៉ា ១ នូវែល-គល្ស ១ គ្វីនស្លង់ ១ អូស្ត្រាលីខាងត្បូង ១ អូស្ត្រាលីខាងលិច ១ កោះតាស្មានី និងខែត្រអូស្ត្រាលីខាងជើង ១ ។

កូលូនីទាំង៦នេះ កាលដាន់ដើមញែកបំបែកការរដ្ឋបាលជាប្រទេសនីមួយៗដោយឡែកពីគ្នា តមកក្នុង ព.ស. ២៤៤៤ រាជការអង់គ្លេស ចាត់បង្រួមជាប្រទេសតែមួយ ដើម្បីឲ្យបានស្រួលក្នុងការត្រួតត្រានិងសេចក្ដីចំរើនរបស់ប្រទេសដោយចាត់ឲ្យមានអ្នកសំរេចរាជការ ជាដំណាងអង្គព្រះមហាក្សត្រអង់គ្លេសជាប្រមុខ ហើយជាអ្នកប្រើអំណាចត្រួតត្រាស្រុកទេសជាមួយនឹងគណៈរដ្ឋមន្ត្រី ។ ឯសភាការផែនដីដែលមានអំណាចចេញច្បាប់បាននោះ ប្រកបដោយសភាជាន់ខ្ពស់និងសភាដំណាងរាស្ត្រ សមាជិកក្នុងសភាជាន់ខ្ពស់មានចំនួន ៣៦ នាក់ (ក្នុងរដ្ឋនិមួយៗ មានចំនួន៦ នាក់) នៅក្នុងដំណែងម្នាក់ ៦ ឆ្នាំ ហើយមានការជួសជុលសមាជិកចំនួនពាក់កណ្ដាលគ្រប់ៗបីឆ្នាំ ឯសមាជិកសភាដំណាងរាស្ត្រមានចំនួន ៧៦ នាក់ នៅក្នុងដំណែងកំណត់ ៣ ឆ្នាំ ។